unicef

ដើម្បីកុមារគ្រប់រូប

# ស្ថិតិស្តីពីកិច្ចការពារកុមារ នៅកម្ពុជា



រក្សាសិទ្ធិ © ដោយមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ ( យូនីសេហ្វ ) ប្រចាំប្រទេសកម្ពុជា និងផ្នែកទិន្នន័យ ស្រាវជ្រាវ និង គោលនយោបាយ នៃការិយាល័យយូនីសេហ្វប្រចាំទីក្រុងញូយ៉ក ឆ្នាំ 2017។

ការផលិតផ្នែកណាមួយនៃឯកសារបោះពុម្ពផ្សាយនេះ ត្រូវមានការអនុញ្ញាត។ ការអនុញ្ញាតនឹងត្រូវផ្តល់ដោយមិនគិតថ្លៃដល់គ្រឹះស្ថានអប់រំ ឬអង្គការមិនរកប្រាក់ចំណេញ។

ដើម្បីស្នើសុំការអនុញ្ញាត និងទទួលបានព័ត៌មានផ្សេងទៀតពីឯកសារបោះពុម្ពផ្សាយនេះ សូមទាក់ទង៖

ការិយាល័យយូនីសេហ្វប្រចាំប្រទេសកម្ពុជា
អគារ Exchange Square ជាន់ទី 5 អគារលេខ 19 និង 20 ផ្លូវលេខ 106 សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ប្រទេសកម្ពុជា
ប្រអប់សំបុត្រលេខ 176
ទូរស័ព្ទ៖ +855 (0)23 260 204
អ៊ីម៉ែល៖ phnompenh@unicef.org
គេហទំព័រ៖ https://www.unicef.org/cambodia/

ឈ្មោះដែលប្រើប្រាស់នៅក្នុងឯកសារបោះពុម្ពផ្សាយនេះ និងការបង្ហាញពីព័ត៌មាននានា មិនមែនមានន័យថាយូនីសេហ្វបង្ហាញពីការយល់ឃើញអ្វីមួយ ពាក់ព័ន្ធជាមួយស្ថានភាពស្របច្បាប់របស់ប្រទេស ឬដែនដីណាមួយ ឬអាជ្ញាធររបស់ប្រទេស ឬដែនដីនោះឡើយ ឬការកំណត់ព្រំដែនរបស់ប្រទេស ឬដែនដីនោះឡើយ។

ឈ្មោះឯកសារនេះ ក្នុងនាមជាឯកសារយោង៖ UNICEF Cambodia and Division of Data, Research and Policy, UNICEF New York, A Statistical Profile of Child Protection in Cambodia, United Nations Children's Fund, New York, September 2017

**សេចក្តីថ្លែងអំណរគុណ**

ការរៀបចំរបាយការណ៍នេះ ត្រូវបានផ្តួចផ្តើម និងសម្របសម្រួលដោយលោក Bruce Grant ( ប្រធានផ្នែកការពារកុមារនៃយូនីសេហ្វប្រចាំប្រទេសកម្ពុជា ) និងលោកស្រី Lucia Soleti ( អ្នកឯកទេសផ្នែកការពារកុមារនៃយូនីសេហ្វកម្ពុជា ) Claudia Cappa ( អ្នកឯកទេសផ្នែកស្ថិតិនៃការិយាល័យកណ្តាលរបស់យូនីសេហ្វ ) និង Nicole Petrowski ( ទីប្រឹក្សាការិយាល័យកណ្តាលយូនីសេហ្វ ) បានរួមចំណែកដល់ការរៀបចំរបាយការណ៍នេះ និងជាអ្នកទទួលខុសត្រូវចំពោះការវិភាគទិន្នន័យពីការបកស្រាយលទ្ធផល និង ការសរសេររបាយការណ៍ រួមជាមួយនឹង Suman Khadka ( ទីប្រឹក្សាយូនីសេហ្វកម្ពុជា ) Colleen Murray ( អ្នកឯកទេសផ្នែកស្ថិតិ ការិយាល័យកណ្តាលយូនីសេហ្វ ) បានចូលរួមធ្វើការវិភាគទិន្នន័យ និងរៀបចំរូបភាពបង្ហាញពីស្ថិតិនៅក្នុងឯកសារនេះ។

អ្នកជួយពិនិត្យផ្នែកបច្ចេកទេស៖ Stephen Blight ( ទីប្រឹក្សាថ្នាក់តំបន់ ផ្នែកការពារកុមារនៃការិយាល័យយូនីសេហ្វប្រចាំតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិច ) Augustine Botwe ( អតីតទីប្រឹក្សាផ្នែកពិនិត្យតាមដាន និងវាយតម្លៃថ្នាក់តំបន់ការិយាល័យយូនីសេហ្វប្រចាំតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិច ) Liliana Carvajal ( អ្នកឯកទេសផ្នែកស្ថិតិនៃការិយាល័យកណ្តាលរបស់យូនីសេហ្វ ) Maun ChanSarak ( ប្រធាននាយកដ្ឋានផែនការសង្គម និងជាអ្នកគ្រប់គ្រងប្រព័ន្ធទិន្នន័យនៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៃក្រសួងផែនការនៃប្រទេសកម្ពុជា ) Kimsong Chea ( អ្នកឯកទេសផ្នែកគាំពារសង្គមនៃយូនីសេហ្វប្រចាំប្រទេសកម្ពុជា ) Maki Kato ( ប្រធានផ្នែកគោលនយោបាយសង្គមនៃយូនីសេហ្វកម្ពុជា ) Anne Lubell ( អ្នកឯកទេសផ្នែកអភិវឌ្ឍន៍សហគមន៍នៃយូនីសេហ្វកម្ពុជា ) Christina Misunas ( មន្រ្តីស្ថិតិការិយាល័យកណ្តាលនៃយូនីសេហ្វ ) ផ្លុង ឆាយយ៉ា ( អ្នកឯកទេសផ្នែកការពារកុមារនៃយូនីសេហ្វកម្ពុជា ) Etienne Poirot ( ប្រធានផ្នែកសុខភាព យូនីសេហ្វកម្ពុជា ) សូ សេរីវឌ្ឍនា ( មន្ត្រីការពារកុមារយូនីសេហ្វកម្ពុជា ) និង Peter Williams ( បេសកកម្មយុត្តិធម៌អន្តរជាតិ កម្ពុជា )។

ពិនិត្យកែសម្រួល និងសរសេរអត្ថបទដោយ៖ Lois Jensen ( ទីប្រឹក្សាខាងក្រៅ ) និង Joan Ross Frankson ( ទីប្រឹក្សាខាងក្រៅ )។

រចនាដោយ៖ Era Porth ( ទីប្រឹក្សាខាងក្រៅ )។



# អារម្ភកថា

របាយការណ៍ប្រភេទនេះ គឺជារបាយការណ៍ដំបូងបង្អស់ ដែលនឹងជួយបំពេញចំណុចខ្វះខាតដ៏សំខាន់មួយនៅកម្ពុជា៖ ខណៈពេលដែលកម្ពុជាមានទិន្នន័យយ៉ាងច្រើនអំពីកិច្ចការពារកុមារ ទិន្នន័យទាំងនេះនៅរាយប៉ាយតាមវិស័យ និងក្នុងឯកសារសិក្សាស្រាវជ្រាវជាច្រើន។ លើសពីនេះ ប្រទេសកម្ពុជាក៏នៅមិនទាន់មានប្រព័ន្ធគ្រប់គ្រងព័ត៌មានស្តីពីកិច្ចការពារកុមារ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនោះដែរ។ ខ្ញុំសង្ឃឹមថារបាយការណ៍នេះ នឹងត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ជួយដល់ការប្រមូលទិន្នន័យ និងការអនុវត្តសកម្មភាពបន្ថែមទៀត ក្នុងវិស័យការពារកុមារ។ ជាពិសេស របាយការណ៍នេះមានគោលបំណងជួយដល់អ្នកតាក់តែងគោលនយោបាយ និងមន្ត្រីកម្មវិធីក្នុងការវិភាគវឌ្ឍនភាព និងរៀបចំគោលនយោបាយ និងកម្មវិធីនានា ដោយប្រើប្រាស់ភស្តុតាងនានាជាគោល។

ខ្លឹមសារនៃឯកសារនេះត្រូវបានរៀបចំឡើង ផ្អែកទៅតាមការវិភាគទិន្នន័យ ដែលប្រមូលបានពីការស្រាវជ្រាវ និងការសិក្សានានា ស្តីពីប្រទេសកម្ពុជា។ ឯកសារនេះផ្តោតលើប្រធានបទស្នូល និងសូចនាករសំខាន់ៗជាច្រើន ក្នុងទម្រង់សង្ខេបងាយស្រួលយល់ អំពីស្ថានភាព និងនិន្នាការបច្ចុប្បន្ន នៃវិស័យការពារកុមារ។ ឯកសារនេះត្រូវបានរៀបចំឡើង ជុំវិញប្រធានបទចំនួន 14 ដោយប្រធានបទនីមួយៗមានការពិពណ៌នាដោយសង្ខេបៗ និងមានការបង្ហាញលំអិតអំពីសូចនាករនានា ដើម្បីឱ្យគេយល់កាន់តែច្បាស់ពីទិដ្ឋភាពសំខាន់ៗនៃជីវិតរបស់កុមារ។

លក្ខណៈសំខាន់មួយនៃរបាយការណ៍នេះគឺ ការវិភាគនិន្នាការនៃទិន្នន័យសំខាន់ៗមួយចំនួន ដែលទិន្នន័យខ្លះមានតាំងពីឆ្នាំ 2000 មកម្ល៉េះ និងមានការធ្វើចំណោល រហូតដល់ឆ្នាំ 2030។ ការវិភាគបែបនេះមានតម្លៃ សម្រាប់ការរៀបចំផែនការកម្មវិធី ក៏ដូចជាសម្រាប់ពិនិត្យតាមដានវឌ្ឍនភាព ឆ្ពោះទៅសម្រេចរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ 2030 និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ទាំង 17។ គោលដៅ SDGs ដែលជាគោលដៅថ្មីជំនួសឱ្យក្របខ័ណ្ឌអភិវឌ្ឍន៍សកល ដែលកន្លងមក ហៅថាគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) ជាការត្រួសត្រាយផ្លូវ ក្នុងការឈានទៅសម្រេចគោលដៅប្រកបដោយមហិច្ឆិតានៅឆ្នាំ 2030។

ខុសពីគោលដៅ MDGs គោលដៅ SDGs រំលេចកិច្ចការពារកុមារ ថាជាផ្នែកដែលត្រូវយកចិត្តទុកដាក់ជាពិសេស។ នេះគឺជាសមិទ្ធផលដ៏ធំធេងមួយ ក្នុងការជម្រុញលើកកម្ពស់ឱ្យមានការទទួលស្គាល់វិស័យនេះ។ ប៉ុន្តែ ចំណុចដៅពាក់ព័ន្ធនឹងកិច្ចការពារកុមារ នៅរាយប៉ាយ ក្នុងគោលដៅ SDGs ជាច្រើន។ ក្នុងរបាយការណ៍នេះ មានផ្នែកមួយ ដែលរៀបរាប់ពីចំណុចដៅ និងសូចនាករ SDGs ដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ និងបង្ហាញពីទិន្នន័យដើមគ្រាសម្រាប់កម្ពុជា ក្នុងករណីដែលមានទិន្នន័យទាំងនោះ។ ផ្នែកចុងក្រោយបង្ហាញពីគម្លាត និងចំណុចខ្វះខាតផ្នែកទិន្នន័យ និងវិធានការជាក់លាក់ ដើម្បីឆ្លើយតបចំពោះបញ្ហានេះ។

វិសាលភាពនៃរបាយការណ៍នេះ នៅមានកំណត់នៅឡើយ ដោយសារតែកង្វះទិន្នន័យ ដូចរៀបរាប់ខាងលើ។ យើងសង្ឃឹមថា ការលើកឡើងពីបញ្ហាទាំងនេះ នឹងជម្រុញឱ្យមានការពង្រឹងប្រព័ន្ធនេះបន្ថែមទៀត ដើម្បីឱ្យនាពេលអនាគត វិស័យការពារកុមារអាចទទួលបានប្រយោជន៍ពីការមានទិន្នន័យទៀងទាត់ ទាន់ពេលវេលា អាចជឿទុកចិត្តបាន និងឆ្លើយតប ដែលអាចឱ្យគេរៀបចំកម្មវិធីការពារកុមារកាន់តែប្រសើរជាងមុននៅកម្ពុជា។

ខ្ញុំសូមឆ្លៀតឱកាសនេះថ្លែងអំណរគុណដល់ បុគ្គលិក និងទីប្រឹក្សាយូនីសេហ្វនៅការិយាល័យកណ្តាល ការិយាល័យតំបន់ និងការិយាល័យក្នុងប្រទេស ដែលបានចូលរួមរៀបចំរបាយការណ៍នេះឡើង។ យើងសូមថ្លែងអំណរគុណផងដែរ ចំពោះដៃគូរបស់យើង ជាពិសេសទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ដែលបានបន្តផ្តល់ការគាំទ្រដល់ការអនុវត្តកម្មវិធី និងការប្រមូលចងក្រងទិន្នន័យ និងភស្តុតាងនានា ឱ្យមានលក្ខណៈរឹងមាំបន្ថែមទៀត។

**Debora Comini**
នាយិកាអង្គការយូនីសេហ្វនៅកម្ពុជា

# មាតិកា


សេចក្តីផ្តើម ១

ប្រជាសាស្ត្រកុមារ ៣

កុមារពុំមានឪពុកម្តាយបង្កើតរស់នៅជាមួយ ៥

កុមារដែលពុំមានចុះសំបុត្រកំណើត ៩

កូនក្រមុំវ័យកុមារ ១១

ការមានផ្ទៃពោះរបស់ក្មេងជំទង់ និងការឆាប់មានកូន ១៣

អំពើហិង្សាលើកុមារ ១៥

ការជួញដូរកុមារ ១៩

កុមាររងផលប៉ះពាល់ដោយសារមេរោគអេដស៍/ជម្ងឺអេដស៍ ២០

ពលកម្មកុមារ និងកុមារធ្វើការងារ ២១

កុមារដែលរស់នៅ ឬធ្វើការងារតាមផ្លូវ ២៥

កុមាររស់នៅក្នុងភាពក្រីក្រ ២៦

កុមារពិការ និងកុមារដែលរងគ្រោះដោយសារសំណល់សង្គ្រាម ២៧

កុមារដែលមានទំនាស់ជាមួយច្បាប់ ២៩

ប្រព័ន្ធការពារកុមារ ៣០

បូកសរុប និងបោះជំហានទៅមុខ៖ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ៣១

បំពេញចន្លោះខ្វះខាតសំខាន់ៗនៃទិន្នន័យ ៣៣

កំណត់សម្គាល់បច្ចេកទេសស្តីពីទិន្នន័យដែលប្រើប្រាស់ក្នុងរបាយការណ៍នេះ ៣៥

ប្រភពទិន្នន័យ ៣៦

ឯកសារយោងបន្ថែម កំណត់សម្គាល់ចុងក្រោយ ៣៧

ឧបសម្ព័ន្ធទិន្នន័យ ៤១



# អក្សរកាត់

| | | |
|---|---|---|
| **ADB** | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| **AARC** | Average annual rate of reduction | អត្រាថយចុះគិតជាមធ្យមប្រចាំឆ្នាំ |
| **CDHS** | Cambodia Demographic and Health Survey | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា |
| **CMAA** | Cambodian Mine Action Authority | អាជ្ញាធរមីនកម្ពុជា |
| **CSES** | Cambodia Socio-Economic Survey | ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា |
| **CVACS** | Cambodia Violence Against Children Survey | ការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា |
| **ERWs** | Explosive remnants of war | កាកសំណល់សង្គ្រាមមិនទាន់ផ្ទុះ |
| **GDP** | Gross domestic product | ផលិតផលសរុបក្នុងស្រុក |
| **ILO** | International Labour Organization | អង្គការពលកម្មអន្តរជាតិ |
| **MoSVY** | Ministry of Social Affairs, Veterans and Youth Rehabilitation | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| **NIS** | National Institute of Statistics | វិទ្យាស្ថានជាតិស្ថិតិ |
| **OVC** | Orphans and vulnerable children | កុមារកំព្រា និងងាយរងគ្រោះ |
| **RCI** | Residential care institution | មណ្ឌលថែទាំកុមារ |
| **SDGs** | Sustainable Development Goals | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| **TIP** | Trafficking in persons | ការជួញដូរមនុស្ស |
| **TIP** | Trafficking in persons | ការជួញដូរមនុស្ស |
| **USAID** | **United States Agency for International Development** | ភ្នាក់ងារអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ |

# សេចក្តីផ្តើម

កុមារគ្រប់រូប មានសិទ្ធិចម្រើនវ័យក្នុងបរិយាកាស ដែលផ្តល់ឱ្យពួកគេនូវសុវត្ថិភាព និងការទំនុកបំរុង គ្មានអំពើហិង្សា និងការកេងប្រវ័ញ្ច។ កុមារនៅកម្ពុជា កាន់តែទទួលបានការការពារ តាមរយៈច្បាប់ជាតិ និងការផ្តល់សេវាកាន់តែប្រសើរជាងមុនជាមួយនឹងការផ្តល់ជំនួយសប្បុរសធម៌ពីដៃគូអភិវឌ្ឍន៍នានា ក្នុងវិស័យនេះ។ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ និងកំណត់ពន្យល់អំពីច្បាប់នេះ, ច្បាប់ស្តីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ, ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលទើបតែនឹងទទួលបានការអនុម័តកាលពីពេលថ្មីៗនេះ គឺជាសមិទ្ធផលធំៗមួយចំនួន ក្នុងចំណោមសមិទ្ធផលធំៗដែលសម្រេចបានកន្លងមក។

ការផ្លាស់ប្តូរជាប្រព័ន្ធនៃការផ្តល់ការថែទាំជំនួស គឺជាចំណុចដែលគួរកត់សម្គាល់ជាពិសេស។ រដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវកំណែទម្រង់ច្បាប់ ទិន្នន័យ និងកម្មវិធី ដើម្បីត្រួតពិនិត្យការកើនឡើងយ៉ាងឆាប់រហ័សនូវចំនួនកុមាររស់នៅតាមមណ្ឌលថែទាំ ដែលគ្មានការគ្រប់គ្រងត្រឹមត្រូវ នៅកម្ពុជា។ ឧទាហរណ៍ អនុក្រឹតស្តីពីការគ្រប់គ្រងមណ្ឌលថែទាំ ត្រូវបានអនុម័តកាលពីឆ្នាំ 2015 ដើម្បីគ្រប់គ្រងវិស័យ "ថែទាំកុមារតាមមណ្ឌល" ហើយការកំណត់ទីតាំងគ្រប់មណ្ឌលថែទាំទាំងអស់នៅក្នុងប្រទេសនេះ ក៏ត្រូវបានធ្វើឡើងផងដែរ។ ផ្អែកទៅតាមសកម្មភាពទាំង 2 ខាងលើនេះ ផែនការសកម្មភាពកែលំអការថែទាំកុមារ ត្រូវបានចុះហត្ថលេខាកាលពីឆ្នាំ 2016 និងប្រកាសឱ្យអនុវត្តក្នុងឆ្នាំ 2017។ ផែនការនេះមានគោលបំណង កាត់បន្ថយចំនួនកុមារ ដែលរស់នៅក្រៅការថែទាំរបស់គ្រួសារ ឱ្យបាន 30 ភាគរយ ពីឆ្នាំ 2016 ដល់ឆ្នាំ 2018។

តម្រូវការទិន្នន័យពាក់ព័ន្ធ និងត្រឹមត្រូវអំពីការការពារកុមារ គឺជាតម្រូវការបន្ទាន់ សម្រាប់ពិនិត្យតាមដាននិន្នាការទិន្នន័យនានា សម្រាប់គោលបំណងរៀបចំផែនការនិងការធ្វើការតស៊ូមតិ និងតាមដានវឌ្ឍនភាព ឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) និងចំណុចដៅនៃគោលដៅនេះ។ បើទោះបីជាកម្ពុជាមានទិន្នន័យស្តីពីការការពារកុមារយ៉ាងច្រើនយ៉ាងណាក៏ដោយ រហូតមកដល់បច្ចុប្បន្ននេះ ព័ត៌មានទាំងនេះនៅរាយប៉ាយនៅឡើយ។ លើសពីនេះ ប្រទេសនេះក៏ខ្វះដំណើរការ ដែលមានលក្ខណៈជាប្រព័ន្ធ សម្រាប់ផ្សព្វផ្សាយព័ត៌មានឱ្យបានទាន់ពេលវេលា និងអាចជឿទុកចិត្តបានអំពីការងារសំខាន់ៗ ដែលពាក់ព័ន្ធ និងកិច្ចការពារកុមារក្នុងទម្រង់រួម ដែលងាយស្រួលទាញទិន្នន័យយកមកប្រើប្រាស់ផងដែរ។

របាយការណ៍ប្រភេទនេះ ដែលជារបាយការណ៍ដំបូង មិនធ្លាប់មានកន្លងមកនៅកម្ពុជា ធ្វើការប្រមូលផ្តុំទិន្នន័យដែលនៅរាយប៉ាយទាំងនេះឱ្យនៅផ្តុំគ្នា ដើម្បីបង្ហាញពីស្ថានភាពរួមនៃកិច្ចការពារកុមារនៅកម្ពុជា។ ឯកសារនេះបែងចែកជាប្រធានបទស្នូលចំនួន 14 និងសូចនាករសំខាន់ៗ បែងចែកជាផ្នែកៗដែលសង្ខេបពីស្ថានភាព និងនិន្នាការបច្ចុប្បន្ន។ ផ្នែកនីមួយៗមានការពិពណ៌នាបែបសង្ខេប និងការបង្ហាញលំអិតពីទិន្នន័យ និងក្រាហ្វពាក់ព័ន្ធមួយចំនួន។ ផ្នែកចុងក្រោយ បង្ហាញពីទិន្នន័យដើមគ្រា ស្តីពីកិច្ចការពារកុមារនៅកម្ពុជា ពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (ក្នុងករណីដែលមាន) ទិន្នន័យ និងបង្ហាញពីគម្លាត និងចំណុចខ្វះខាតផ្នែកទិន្នន័យ អមដោយវិធានការជាក់លាក់ ដើម្បីឆ្លើយតបចំពោះបញ្ហានេះ។ របាយការណ៍នេះមានគោលបំណងជួយដល់អ្នកតាក់តែងគោលនយោបាយ អ្នកអនុវត្តកម្មវិធី និងអ្នកវាយតម្លៃ ក្នុងការវិភាគវឌ្ឍនភាព និងរៀបចំគោលនយោបាយកម្មវិធី ដោយប្រើប្រាស់ភស្តុតាងជាគោល។ ឯកសារនេះក៏គោលបំណងជួយពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ការពារកុមារនៅកម្ពុជាផងដែរ។



# ប្រជាសាស្ត្រកុមារ[1]



**រូបភាព** 1.1 **ប្រជាជននៅកម្ពុជា បែងចែកតាមក្រុមអាយុ និងបែងចែកតាមភេទ** 2017




ប្រភព៖ ចំនួនប្រជាជនក្នុងសកលលោក៖ កែសម្រួលឆ្នាំ 2015 សំណៅ DVD ឆ្នាំ 2015 ផលិតដោយនាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមកិច្ច ផ្នែកប្រជាជនរបស់សហប្រជាជាតិ

ប្រទេសកម្ពុជាមានប្រជាជនសរុប 16,1 លាននាក់ នៅក្នុងនោះ 5,9 លាននាក់ (37 ភាគរយ) គឺជាកុមារ (អាយុ 0 - 17 ឆ្នាំ) កុមារក្នុងក្រុមអាយុក្រុម 0 ទៅ 4 ឆ្នាំមានចំនួន 1,8 លាននាក់ ក្រុមអាយុ 5 ទៅ 9 ឆ្នាំ មាន 1,7 លាននាក់ និងក្មេងជំទង់អាយុ 10 ទៅ 17 ឆ្នាំ មាន 2,5 លាននាក់ (រូបភាព 1.1)។ ផលធៀបរបស់កុមារអាយុក្រោម 5 ឆ្នាំ គឺស្ថិតក្នុងកម្រិតដែលរំពឹងទុក ពោលគឺក្មេងប្រុស103នាក់ និង ក្មេងស្រី100នាក់។

កាលពីពេលថ្មីៗនេះ ចំនួនកុមារបាននៅថេរ ក្រោយពេលដែលចំនួននេះ មានការកើនឡើងជាច្រើនទសវត្សរ៍កន្លងមកនេះ (លើកលែងតែការធ្លាក់ចុះខ្លាំង នៅដើមទសវត្សរ៍ 1980)។ មូលហេតុសំខាន់ជាងគេមួយ ដែលនាំឱ្យអត្រាមរណភាពកុមារ មានកម្រិតខ្ពស់ក្នុងរយៈពេលនេះ គឺសង្គ្រាម និងរបបប្រល័យពូជសាសន៍ ដែលកើតឡើងក្នុងប្រទេសកម្ពុជា នៅសម័យកាលនោះ។ គេរំពឹងថា ចំនួនកុមារបន្តនៅថេរប្រហាក់ប្រហែលនឹងបច្ចុប្បន្ននេះ ក្នុងទសវត្សរ៍ខាងមុខ (រូបភាព 1.2)។

ជាមធ្យម ចាប់តាំងពីទសវត្សរ៍ 1980 មក ក្នុងមួយឆ្នាំ មានកុមារកើតជាង 300,000 នាក់។ គេរំពឹងថាចំនួននេះនឹងថយចុះតិចតួចនាពេលអនាគតខាងមុខនេះ។ កុមារដែលកើតក្នុងឆ្នាំ 2012 មានអាយុកាលរំពឹងទុក 70 ឆ្នាំ ពោលគឺ 10 ឆ្នាំយូរជាងកុមារដែលកើតក្នុងឆ្នាំ 2000។ អាយុកាលរំពឹងទុក មានការថយចុះកាលពីកំឡុងទសវត្សរ៍ទី 80 ដោយសារសង្គ្រាម និងរបបប្រល័យពូជសាសន៍ (រូបភាព 1.3)។

គិតត្រឹមឆ្នាំ 2017 ប្រជាជនកម្ពុជាដែលរស់នៅទីក្រុងមាន 21 ភាគរយ នៃចំនួនប្រជាជនសរុប។ ភាគរយនៃប្រជាជនរស់នៅតំបន់ប្រជុំជន មានការកើនឡើងជាបន្តបន្ទាប់ ហើយគេរំពឹងថាចំនួននេះ នឹងឡើងដល់ 1 ភាគ 3 មុនឆ្នាំ 2050 (រូបភាព 1.4)។

### រូបភាព 1.2 ចំនួនប្រជាជនជាកុមារនៅកម្ពុជា បែងចែកតាមក្រុមអាយុ 1950 ដល់ 2050




ប្រភព៖ ចំនួនប្រជាជនក្នុងសកលលោក៖ កែសម្រួលឆ្នាំ 2015 សំណៅ DVD ឆ្នាំ 2015 ផលិតដោយនាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមកិច្ច ផ្នែកប្រជាជនរបស់សហប្រជាជាតិ

### រូបភាព 1.3 អាយុកាលរំពឹងទុកនៅកម្ពុជានៅពេលកើត 1950 - 2030




ប្រភព៖ ចំនួនប្រជាជនក្នុងសកលលោក៖ កែសម្រួលឆ្នាំ 2015 សំណៅ DVD ឆ្នាំ 2015 ផលិតដោយនាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមកិច្ច ផ្នែកប្រជាជនរបស់សហប្រជាជាតិ

### រូបភាព 1.4 ភាគរយនៃប្រជាជនកម្ពុជាដែលរស់នៅតំបន់ប្រជុំជន 1990 - 2050




ប្រភព៖ ចំនួនប្រជាជនក្នុងសកលលោក៖ កែសម្រួលឆ្នាំ 2015 សំណៅ DVD ឆ្នាំ 2015 ផលិតដោយនាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមកិច្ច ផ្នែកប្រជាជនរបស់សហប្រជាជាតិ

# កុមារពុំមានឪពុកម្តាយបង្កើតរស់នៅជាមួយ



## កុមារដែលមាន ឬគ្មានឪពុកម្តាយបង្កើតរស់នៅជាមួយក្នុងគ្រួសារ

កុមារភាគច្រើននៅកម្ពុជា រស់នៅជាមួយឪពុកម្តាយបង្កើតរបស់ពួកគេ។ ក្នុងឆ្នាំ 2014 កុមារ 89 ភាគរយ រស់នៅជាមួយឪពុកម្តាយយ៉ាងហោចណាស់ម្នាក់។ ក្នុងចំណោមកុមារទាំងនេះ ជាង 3 ភាគ 4 រស់នៅជាមួយឪពុកម្តាយទាំងពីរ។ ប៉ុន្តែ ភាគរយនៃកុមារដែលពុំមានឪពុកម្តាយបង្កើតរស់នៅជាមួយកាន់តែមានការកើនឡើង បើទោះបីជាភាគច្រើននៃកុមារទាំងនេះ មានយ៉ាងហោចណាស់ឪពុកឬម្តាយម្នាក់នៅរស់យ៉ាងណាក៏ដោយ (រូបភាព 2.1)។

ក្នុងឆ្នាំ 2014 កុមារ 9 ភាគរយ រស់នៅតែជាមួយម្តាយរបស់ពួកគេតែប៉ុណ្ណោះ បើធៀបជាមួយនឹង 2 ភាគរយដែលរស់នៅតែជាមួយឪពុក (តារាង 2.1)។ ប៉ុន្តែ គួរកត់សម្គាល់ថា កុមារដែលបាត់បង់ឪពុក (5 ភាគរយ) មានចំនួនច្រើនជាងកុមារដែលបាត់បង់ម្តាយ (2 ភាគរយ)។ ចាប់តាំងពីឆ្នាំ 2005 មក មានកុមារតិចជាងមុន ដែលត្រូវបានរកឃើញថារស់នៅតែជាមួយម្តាយ នៅក្នុងស្ថានភាពដែលឪពុករបស់ពួកគេបានបាត់បង់ជីវិត។

ការរៀបចំការរស់នៅរបស់កុមារ ផ្តល់នូវព័ត៌មានសំខាន់អំពីសុខមាលភាព និងភាពងាយរងគ្រោះ ដែលពួកគេអាចប្រឈម។[2] ជាទូទៅមានការទទួលស្គាល់ថា កុមារទទួលបានការថែទាំល្អបំផុតពីគ្រួសាររបស់ពួកគេ។ នៅពេលដែលកុមារពុំអាចទទួលបានការថែទាំពីគ្រួសារផ្ទាល់របស់ពួកគេ ជម្រើសដែលល្អបំផុតគឺការរៀបចំឱ្យមានការផ្តល់ការថែទាំក្នុងគ្រួសារ ដូចជាការថែទាំដោយឪពុកម្តាយធម៌ និងការថែទាំដោយសាច់ញាតិជាដើម។ ការដាក់កុមារក្នុងកន្លែង ឬមណ្ឌលថែទាំ គួរប្រើប្រាស់ជាជម្រើសចុងក្រោយ ឬត្រឹមតែបណ្តោះអាសន្នតែប៉ុណ្ណោះ។ មានការស្រាវជ្រាវ និងភស្តុតាងជាសកលជាច្រើន បង្ហាញពីផលប៉ះពាល់ជាអវិជ្ជមាន ពីការថែទាំតាមមណ្ឌលមកលើការអភិវឌ្ឍសង្គម កាយសម្បទា បញ្ញាស្មារតី និងផ្លូវចិត្តរបស់កុមារ ដែលខុសពីការថែទាំដោយគ្រួសារផ្ទាល់ និងការថែទាំតាមគ្រួសារ។[3]

**តារាង 2.1 ភាគរយនៃកុមារអាយុ 0 ទៅ 17 ឆ្នាំ រស់រាននៅតែជាមួយឪពុក ឬម្តាយម្នាក់ បែងចែកទៅតាមស្ថានភាពរបស់ឪពុកម្តាយ**

| | កុមាររស់នៅតែជាមួយម្តាយប៉ុណ្ណោះ (ឪពុកនៅរស់) | កុមាររស់នៅតែជាមួយម្តាយប៉ុណ្ណោះ (ឪពុកស្លាប់) | កុមាររស់នៅតែជាមួយឪពុកតែប៉ុណ្ណោះ (ម្តាយនៅរស់) | កុមាររស់នៅតែជាមួយឪពុកប៉ុណ្ណោះ (ម្តាយស្លាប់) |
|---|---|---|---|---|
| 2005 | 6 | 6 | 1 | 1 |
| 2010 | 6 | 4 | 1 | 1 |
| 2014 | 6 | 3 | 1 | 1 |

ប្រភព៖ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) 2005 2010 2014

**រូបភាព 2.1 របាយកុមារអាយុ 0 ទៅ 17 ឆ្នាំ គិតជាភាគរយ បែងចែកទៅតាមការរៀបចំការរស់នៅ**

■ រស់នៅជាមួយឪពុកម្តាយបង្កើតយ៉ាងហោចណាស់ម្នាក់ ■ មិនរស់នៅជាមួយឪពុកម្តាយបង្កើត




ប្រភព៖ CDHS 2005 2010 2014

ការកើនឡើងនូវភាគរយកុមារមិនរស់នៅជាមួយឪពុកម្ដាយបង្កើតរបស់ខ្លួន គាប់ជួននឹងការកើនឡើងនូវចំនួនគ្រួសារដែលទទួលយកកូនគេមកចិញ្ចឹម និងចំនួនកុមារដែលរស់នៅតាមមណ្ឌលថែទាំ។ ភាគរយគ្រួសារដែលទទួលយកកុមារមកចិញ្ចឹម[4] គឺ 9 ភាគរយ ក្នុងឆ្នាំ 2000 ប្រមាណជា 12 ភាគរយក្នុងឆ្នាំ 2005 និង 2010 កើនឡើងដល់ 13 ភាគរយក្នុងឆ្នាំ 2014 (រូបភាព 2.2)។ មានភាពខុសប្លែកគ្នាតិចតួចតែប៉ុណ្ណោះ រវាងទីជនបទ និងទីប្រជុំជន។

ក្នុងឆ្នាំ 2014 មានកុមារ (អាយុ 0 ទៅដល់ 17 ឆ្នាំ) តិចជាង 1 ភាគរយនៅកម្ពុជា ដែលបាត់បង់ទាំងឪពុកទាំងម្ដាយ និង 5 ភាគរយបាត់បង់ឪពុក ឬម្ដាយ (រូបភាព 2.3)។ ភាគរយកុមារដែលបាត់បង់ឪពុកឬម្ដាយយ៉ាងហោចណាស់ម្នាក់ បែងចែកទៅតាមភេទរបស់កុមារ ឬតំបន់ប្រជុំជន ឬតំបន់ជនបទដែលកុមាររស់នៅ ពុំមានភាពខុសគ្នាឡើយ (រូបភាព 2.4)។ ប៉ុន្តែចំនួនកុមារកំព្រាមកពីគ្រួសារ ដែលស្ថិតនៅក្នុងបញ្ចភាគទ្រព្យសម្បត្តិទាបជាងគេ ហាក់បីដូចជាមានចំនួនច្រើនជាងកុមារមកពីគ្រួសារដែលមានបញ្ចភាគទ្រព្យធនខ្ពស់ជាងគេតិចតួច។ ដោយសារតែហានិភ័យងាយបាត់បង់ជីវិតរបស់ឪពុកម្ដាយ មានការកើនឡើងទៅតាមពេលវេលា (បើទោះបីជាម្ដាយងាយនឹងប្រឈមហានិភ័យបែបនេះ ច្រើនជាងកំឡុងពេលសម្រាលកូនយ៉ាងណាក៏ដោយ) ភាគរយនៃកុមារដែលបាត់បង់ឪពុក ឬម្ដាយ ឬទាំងឪពុកទាំងម្ដាយ មានការកើនឡើងនៅពេលដែលអាយុរបស់ពួកគេកាន់តែច្រើន ពោលពី 2 ភាគរយក្នុងចំណោមកុមារដែលមានអាយុ 5 ឆ្នាំ រហូតដល់ 13 ភាគរយក្នុងចំណោមក្មេងជំទង់អាយុពី 15 ទៅ 17 ឆ្នាំ។ ភាគរយកុមារដែលបានបាត់បង់ឪពុក ឬក៏ម្ដាយ ឬទាំងឪពុកទាំងម្ដាយមានការប្រែប្រួលខុសគ្នា ពីខេត្តមួយទៅខេត្តមួយទៀត៖ ក្នុងខេត្តចំនួន 5 (កំពង់ចាម កំពង់ឆ្នាំង សៀមរាប ព្រះវិហារ/ស្ទឹងត្រែង និងតាកែវ) ភាគរយនេះគឺខ្ពស់ជាង 6 ភាគរយ ដែលជាអត្រាមធ្យមទូទាំងប្រទេស។ ទិន្នន័យក៏បង្ហាញឱ្យឃើញពីទំនាក់ទំនងយ៉ាងជាក់ច្បាស់ រវាងការរស់រានរបស់ឪពុកម្ដាយ និងការចូលរៀនរបស់កុមារផងដែរ៖ កុមារអាយុ 10 - 14 ឆ្នាំ ដែលឪពុកម្ដាយទាំងពីរ បានស្លាប់ មានលទ្ធភាពចូលរៀនតិចជាងកុមារដែលឪពុកម្ដាយនៅរស់ទាំងពីរនាក់ និងកុមារដែលរស់នៅជាមួយឪពុកឬម្ដាយ។

**រូបភាព 2.2 ភាគរយគ្រួសារដែលមានកូនចិញ្ចឹម**




ប្រភព៖ CDHS 2000 2005 2010 2014

**រូបភាព 2.3 ភាគរយនៃកុមារអាយុ 0 ទៅ 17 ឆ្នាំ បែងចែកទៅតាមស្ថានភាពរស់រានរបស់ឪពុកម្ដាយ**




ប្រភព៖ CDHS 2005 2010 2014

**រូបភាព 2.4 ភាគរយកុមារអាយុ 0 ទៅ 17 ឆ្នាំ ដែលបាត់បង់ឪពុកឬម្ដាយ ឬបាត់បង់ទាំងឪពុកទាំងម្ដាយ បែងចែកទៅតាមសាវតា**




ប្រភព៖ CDHS 2014



ខណៈពេលដែលពាក្យថា "កុមារកំព្រា" ជារឿយៗត្រូវបានគេប្រើសំដៅលើកុមារ ដែលឪពុកម្ដាយបាត់បង់ជីវិត នៅបរិបទផ្សេងៗក៏ដូចជានៅកម្ពុជា ពាក្យនេះត្រូវបានប្រើសំដៅទៅលើកុមារដែលបាត់បង់តែឪពុក ឬក៏ម្ដាយ។ ក្រៅពីភាពមិនត្រឹមត្រូវ ការហៅកុមារដែលមានឪពុក ឬម្ដាយនៅរស់ថាជា "កុមារកំព្រា" អាចជាការប្រមាថ និងជះឥទ្ធិពលដល់ប្រភេទនៃសេវាកម្មដែលត្រូវផ្ដល់ជូន។ នេះជាករណីពាក់ព័ន្ធពិសេសនៅក្នុងបរិបទរបស់ប្រទេសកម្ពុជា ដែលកុមារជាច្រើននាក់ បើទោះបីជាមានឪពុក ឬម្ដាយម្នាក់នៅរស់យ៉ាងណាក៏ដោយ ក៏នៅត្រូវបានគេយកទៅដាក់នៅតាមមណ្ឌលថែទាំដែរក្រោមមូលហេតុថាជាកុមារកំព្រា។ ចាំបាច់ត្រូវមានការទទួលស្គាល់ពីភាពងាយរងគ្រោះរបស់កុមារដែល បាត់បង់ឪពុក ឬក៏ម្ដាយ និងផ្ដល់ការយកចិត្តទុកដាក់បន្ថែម ដើម្បីរិះរកមធ្យោបាយគាំពារគ្រួសារដែលស្ថិតនៅក្នុងស្ថានភាពបែបនេះ ក្នុងគោលបំណងទប់ស្កាត់មិនឱ្យមានការបំបែកកុមារចេញពីគ្រួសាររបស់ពួកគេបើអាចទៅរួច និងធានាយ៉ាងណាឱ្យកុមារទទួលបានការការពារពីផលប៉ះពាល់ ដែលអាចបង្កគ្រោះថ្នាក់ដល់ពួកគេដោយសារតែការបាត់បង់ឪពុក ឬម្ដាយរបស់ខ្លួន។

## កុមារដែលរស់នៅតាមមណ្ឌលថែទាំ

ទិន្នន័យស្ដីពីមណ្ឌលថែទាំកុមារនៅកម្ពុជា អាចរកបានពីប្រភពធំៗចំនួន 2 គឺរបាយការណ៍អធិការកិច្ចប្រចាំឆ្នាំ[5] លើមណ្ឌលថែទាំដែលបានចុះបញ្ជីត្រឹមត្រូវ និងរបាយការណ៍ជាតិ កំណត់ពីទីតាំងមណ្ឌលថែទាំកុមារឆ្នាំ 2015 ដែលរៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានការគាំទ្រពីយូនីសេហ្វ និង USAID។ លើសពីនេះវិទ្យាស្ថានជាតិស្ថិតិ និងសកលវិទ្យាល័យកូឡុំប៊ៀបានធ្វើការសិក្សាមួយកាលពីឆ្នាំ 2015។[6] ទាំងរបាយការណ៍កំណត់ពីទីតាំងមណ្ឌលថែទាំ ទាំងការសិក្សារបស់វិទ្យាស្ថានជាតិស្ថិតិ សុទ្ធតែបានជួយបំពេញកង្វះទិន្នន័យស្ដីពីចំនួនមណ្ឌលថែទាំនៅក្នុងប្រទេសនេះ និងចំនួនកុមារដែលរស់នៅតាមមណ្ឌលថែទាំទាំងនោះ ប៉ុន្តែលទ្ធផលរកឃើញមួយចំនួនមានភាពខុសគ្នា ដោយសារការសិក្សាទាំងពីរនេះ ប្រើប្រាស់វិធីសាស្ត្រផ្សេងគ្នា។ របាយការណ៍នេះយកទិន្នន័យដែលបានពីការសិក្សាកំណត់ទីតាំងមណ្ឌលថែទាំដែលធ្វើឡើងក្នុងឆ្នាំ 2015 ដោយសារតែទិន្នន័យនេះមានលក្ខណៈលំអិតជាង និងប្រើប្រាស់និយមន័យមណ្ឌលថែទាំកុមារ ដែលស្នើឡើងដោយរដ្ឋាភិបាលកម្ពុជា និងត្រូវបានប្រើប្រាស់ជាផ្លូវការដោយរដ្ឋាភិបាល និងយូនីសេហ្វសម្រាប់កំណត់ទិន្នន័យដើមគ្រា សម្រាប់អនុវត្តកម្មវិធីផ្សេងៗ។

ការសិក្សាកំណត់ពីទីតាំងមណ្ឌលថែទាំកុមារ[7] បានបញ្ជាក់ថាមានមណ្ឌលថែទាំកុមារ ឬមណ្ឌលកុមារកំព្រានៅកម្ពុជា (406 កន្លែង) ច្រើនជាងចំនួន 254 កន្លែង ដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាធ្លាប់ដឹងកន្លងមក តាមរយៈរបាយការណ៍អធិការកិច្ចរបស់ខ្លួន (រូបភាព 2.5)។[8] ក្នុងកំឡុងពេលសិក្សាកំណត់ទីតាំងមណ្ឌលថែទាំទាំងនេះ មណ្ឌលថែទាំកុមារចំនួន 38 ភាគរយ ត្រូវបានរកឃើញថ្មី មានន័យថាមណ្ឌលថែទាំទាំងនេះមិនដែលត្រូវបានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាចុះធ្វើអធិការកិច្ចឡើយ ដូច្នេះមណ្ឌលទាំងនេះពុំត្រូវបានត្រួតពិនិត្យដោយរដ្ឋាភិបាលឡើយ។ កន្លែងថែទាំ 233 កន្លែងផ្សេងទៀត ពុំត្រូវបានចាត់ទុកជាមណ្ឌលថែទាំកុមារឡើយ ប៉ុន្តែគេដឹងថាកុមាររស់នៅតាមកន្លែងទាំងនោះ។ កន្លែងថែទាំទាំងនេះមាន ផ្ទះសំចត និងកន្លែងស្នាក់នៅបណ្ដោះអាសន្ន ផ្ទះស្នាក់នៅជាក្រុម វត្តអារាម និងមណ្ឌលថែទាំជាលក្ខណៈសាសនា និងសាលា/ផ្ទះទទួលសិស្សឱ្យស្នាក់នៅជាដើម។[9]

ក្មេងប្រុសដែលរស់នៅតាមមណ្ឌលថែទាំ មានភាគរយខ្ពស់ជាងក្មេងស្រី។ បើតាមរបាយការណ៍កំណត់ពីទីតាំងមណ្ឌលថែទាំកុមារដែលរស់នៅតាមមណ្ឌលថែទាំ មាន 53 ភាគរយជាក្មេងប្រុស។ របាយការណ៍អធិការកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បង្ហាញថាលើកលែងតែឆ្នាំ 2013 ចេញ ភាគរយរបស់ក្មេងប្រុស គឺខ្ពស់ជាងភាគរយក្មេងស្រីដែលរស់នៅតាមមណ្ឌលថែទាំ (រូបភាព 2.5)។

**រូបភាព** 2.5 **ចំនួនមណ្ឌលថែទាំ និងចំនួនក្មេងប្រុស និងក្មេងស្រីដែលរស់នៅតាមមណ្ឌលថែទាំទាំងនោះ**




| | 2005 | 2010 | 2011 | 2013 | 2014 | 2015 | 2016 |
|---|---|---|---|---|---|---|---|
| ក្មេងស្រី | 2561 | 5302 | 5030 | 6844 | 5217 | 5216 | 3807 |
| ក្មេងប្រុស | 3693 | 6643 | 6082 | 5523 | 6236 | 5955 | 4348 |
| ចំនួនមណ្ឌល | 154 | 269 | 216 | 225 | 228 | 254 | 254 |

ប្រភព៖ របាយការណ៍អធិការកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ 2005-2016។

ដោយសារតែមណ្ឌលថែទាំកុមារជាច្រើនស្ថិតនៅក្រៅក្របខ័ណ្ឌគតិយុត្តរបស់ក្រសួង គេមានការព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរចំពោះសុខុមាលភាពរបស់កុមារ ដែលរស់នៅតាមមណ្ឌលទាំងនេះ។ ពាក់ព័ន្ធនឹងមណ្ឌលថែទាំកុមារដែលត្រូវបានរកឃើញក្នុងរបាយការណ៍សិក្សាពីទីតាំងមណ្ឌលថែទាំកុមារ ក្នុងចំណោមមណ្ឌលចំនួន 8 មានប្រហែលមួយដែលពុំបានចុះបញ្ជីជាមួយស្ថាប័នណាមួយរបស់រដ្ឋាភិបាល ហើយក្នុងចំណោមមណ្ឌលថែទាំកុមារចំនួន 5 មានមួយពុំមានអនុស្សារណៈជាមួយនឹងរដ្ឋាភិបាល។

តាមរបាយការណ៍សិក្សាពីទីតាំងមណ្ឌលថែទាំ មានកុមារចំនួន 16,579 នាក់ (អាយុ 0 ទៅ 17 ឆ្នាំ ស្រី 47 ភាគរយ) កំពុងរស់នៅតាមមណ្ឌលថែទាំកុមារ 406 កន្លែងទូទាំងប្រទេសកម្ពុជា ហើយក្នុងនោះមាន 9,608 នាក់ (ស្រី 49 ភាគរយ) កំពុងរស់នៅតាមកន្លែងថែទាំដទៃទៀត។[10] ការសិក្សាកំណត់ទីតាំងមណ្ឌលថែទាំនេះ ក៏បានរកឃើញផងដែរថា របាយមណ្ឌលថែទាំនៅកម្ពុជា ពុំមានលក្ខណៈដូចៗគ្នាតាមគ្រប់ខេត្តនោះឡើយ។ មណ្ឌលថែទាំកុមារភាគច្រើនប្រមូលផ្តុំក្នុងខេត្តចំនួន 9 ស្មើនឹង 83 ភាគរយនៃចំនួនមណ្ឌលថែទាំសរុបទូទាំងប្រទេស។ រាជធានីភ្នំពេញ និងខេត្តសៀមរាបមានមណ្ឌលថែទាំកុមាររហូតដល់49ភាគរយនៃចំនួនមណ្ឌលថែទាំកុមារសរុប ខណៈដែលខេត្ត16ផ្សេងទៀតមានចំនួនមណ្ឌលថែទាំពី0ដល់9កន្លែងក្នុងមួយខេត្ត។ ស្រដៀងគ្នានេះដែរ កុមារភាគច្រើនដែលរស់នៅក្នុងមណ្ឌលថែទាំ (87 ភាគរយ ឬ 14,367 នាក់) ប្រមូលផ្តុំក្នុងខេត្តទាំង 9 ដែលមានចំនួនមណ្ឌលថែទាំច្រើនជាងគេ។ ចំនួនកុមារដែលរស់នៅក្នុងមណ្ឌលថែទាំ មានរហូតដល់ 51 ភាគរយ (ឬ 8,839 នាក់) តែក្នុងរាជធានីភ្នំពេញ និងខេត្តសៀមរាបប៉ុណ្ណោះ (រូបភាព 2.6)។ ប៉ុន្តែចំណុចគួរឱ្យកត់សម្គាល់នៅទីនេះ គឺថាខេត្តទាំង 9 ដែលមានភាគរយមណ្ឌលថែទាំកុមារខ្ពស់បំផុត ក៏ជាខេត្តដែលមានប្រជាជនរស់នៅរហូតទៅដល់ជិតពាក់កណ្តាលនៃចំនួនប្រជាជនសរុបរបស់ប្រទេសកម្ពុជាដែរ។ បណ្តុំនៃមណ្ឌលថែទាំកុមារក៏ត្រូវបានជះឥទ្ធិពលដោយកត្តាផ្សេងៗដូចជាលំហូរទេសចរ និងកម្រិតនៃច្បាប់ក្នុងតំបន់។

របាយការណ៍អធិការកិច្ច បើទោះបីជាពុំបានបង្ហាញពីរូបភាពទាំងស្រុងយ៉ាងណាក៏ដោយ ក៏មានប្រយោជន៍សម្រាប់ធ្វើការវាយតម្លៃពីនិន្នាការកន្លងមកដែរ។ បើតាមទិន្នន័យពីប្រព័ន្ធទិន្នន័យស្តីពីការថែទាំជំនួសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួនមណ្ឌលថែទាំកុមារដែលបានចុះបញ្ជីជាផ្លូវការ ព្រមទាំងចំនួនកុមារដែលរស់នៅតាមមណ្ឌលទាំងនោះមានការកើនឡើងពីចន្លោះពីឆ្នាំ 2005 និងឆ្នាំ 2016។ ចន្លោះពីឆ្នាំ 2005 ដល់ឆ្នាំ 2016 ចំនួនមណ្ឌលថែទាំកុមារកើនឡើង 75 ភាគរយ ( ពី 154 កន្លែងដល់ 269 កន្លែង ) ដែលក្នុងនោះចំនួនកុមារដែលរស់នៅតាមមណ្ឌលទាំងនេះកើនឡើង 91 ភាគរយ ( ពី 6,254 នាក់ដល់ 11,945 នាក់ ) ក្នុងរយៈពេលដូចគ្នានេះ។ ចន្លោះពីឆ្នាំ 2010 ដល់ឆ្នាំ 2016 ចំនួនកុមារ និងចំនួនមណ្ឌលថែទាំមានការថយចុះតិចតួច ប៉ុន្តែនៅតែខ្ពស់ ដែលក្នុងនោះមានកុមារចំនួន 8,155នាក់ ( ស្រី 47 ភាគរយ ) និងមណ្ឌលថែទាំកុមារ 254 កន្លែង ដែលបានចុះបញ្ជីផ្លូវការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គិតត្រឹមឆ្នាំ 2016 (រូបភាព 2.5)។ ប៉ុន្តែដូចបញ្ជាក់ជូនពីខាងដើម តួលេខនេះឆ្លុះបញ្ចាំងតែមណ្ឌលថែទាំកុមារ ដែលបានចុះបញ្ជីជាផ្លូវការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាតែប៉ុណ្ណោះ។

ការសិក្សាមួយដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ ក្នុងឆ្នាំ 2015 បានរកឃើញថា ក្នុងចំណោមកុមារអាយុ 13 ទៅ 17 ឆ្នាំ ដែលរស់នៅតាមមណ្ឌលថែទាំ មានរហូតដល់ 79 ភាគរយ មានឪពុកម្តាយនៅរស់យ៉ាងហោចណាស់ម្នាក់។ របកគំហើញនេះគឺដូចគ្នាទៅនឹងលទ្ធផលរកឃើញពីរបាយការណ៍អធិការកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្នុងឆ្នាំ 2013 ដែលបានរកឃើញថា ក្នុងចំណោមកុមារដែលរស់នៅតាមមណ្ឌលថែទាំទាំងអស់ យ៉ាងហោចណាស់ 77 ភាគរយមានឪពុកម្តាយដែលនៅរស់យ៉ាងហោចណាស់ម្នាក់។ ការសិក្សាដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិនេះ ក៏លើកឡើងផងដែរថា ក្នុងចំណោមកុមារ ដែលមានឪពុកម្តាយនៅរស់យ៉ាងហោចណាស់ម្នាក់ជិតពាក់កណ្តាល មានឪពុកម្តាយរស់នៅក្នុងខេត្តតែមួយនឹងមណ្ឌលថែទាំនេះដែរ។ លើសពីនេះការសិក្សាដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិនេះ បានបង្ហាញថា នៅពេលសាកសួរពីមូលហេតុចំបងដែលធ្វើឱ្យពួកគេមករស់នៅក្នុងមណ្ឌលថែទាំនេះ កុមារអាយុ 13 ដល់ 17 ឆ្នាំ 75 ភាគរយ បានឆ្លើយថា "រត់គេចពីភាពក្រីក្រ" ឬ "ដើម្បីទទួលបានឱកាសអប់រំ"។

ទាំងការសិក្សាកំណត់ពីទីតាំងមណ្ឌលថែទាំ ទាំងការសិក្សាធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ សុទ្ធតែបានរកឃើញថាកុមារភាគច្រើនលើសលុបដែលរស់នៅក្នុងមណ្ឌលថែទាំ គឺស្ថិតនៅក្នុងអាយុកំពុងចូលរៀន។ ការសិក្សាដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ បានរកឃើញថា ក្នុងចំណោមកុមារទាំងអស់ដែលរស់នៅក្នុងមណ្ឌលថែទាំ មានជាងពាក់កណ្តាល មានអាយុចន្លោះពី 13 ទៅ 17 ឆ្នាំ។ ស្រដៀងគ្នានេះដែរ ការសិក្សាកំណត់ពីទីតាំងមណ្ឌលថែទាំនៅទូទាំងប្រទេស បានរកឃើញថាកុមាររស់នៅក្នុងមណ្ឌលថែទាំក្នុងខេត្តចំនួន 20 មាន 67 ភាគរយ មានអាយុចន្លោះពី 11 ដល់ 17 ឆ្នាំ និង 32 ភាគរយ អាយុចន្លោះពី 4 ទៅ 10 ឆ្នាំ។ កុមារអាយុក្រោម 4 ឆ្នាំ មានត្រឹមតែប្រមាណ 2 ភាគរយប៉ុណ្ណោះនៃចំនួនកុមារសរុបដែលកំពុងរស់នៅតាមមណ្ឌលថែទាំ។ ការស្រាវជ្រាវបង្ហាញថា ការរស់នៅក្នុងមណ្ឌលថែទាំបង្កអន្តរាយដល់កុមារអាយុក្រោម 3 ឆ្នាំ។[11] ដូច្នេះ នេះគឺជាការព្រួយបារម្ភ សម្រាប់កុមារអាយុក្រោម 4 ឆ្នាំ ដែលត្រូវបានរកឃើញថាកំពុងរស់នៅរយៈពេលវែង នៅក្នុងមណ្ឌលថែទាំ។

**រូបភាពទី 2.2 ចំនួនមណ្ឌលថែទាំកុមារ និងចំនួនកុមារដែលរស់នៅតាមមណ្ឌលថែទាំកុមារ បែងចែកតាមភេទ និងខេត្ត**

| ខេត្ត | ចំនួនមណ្ឌល | ចំនួនក្មេង | | |
|---|---|---|---|---|
| | | ក្មេងស្រី | ក្មេងប្រុស | សរុប |
| ភ្នំពេញ | 117 | 3,164 | 3,077 | 6,241 |
| សៀមរាប | 80 | 1,019 | 1,129 | 2,148 |
| បាត់ដំបង | 35 | 691 | 777 | 1,468 |
| ព្រះសីហនុ | 15 | 334 | 735 | 1,069 |
| កណ្តាល | 20 | 399 | 463 | 862 |
| កំពង់ស្ពឺ | 15 | 365 | 465 | 830 |
| កំពត | 17 | 385 | 426 | 811 |
| កំពង់ធំ | 23 | 278 | 295 | 573 |
| កំពង់ឆ្នាំង | 16 | 184 | 181 | 365 |
| បន្ទាយមានជ័យ | 9 | 149 | 181 | 330 |
| កំពង់ចាម | 8 | 131 | 182 | 313 |
| ព្រៃវែង | 6 | 111 | 114 | 225 |
| តាកែវ | 7 | 93 | 103 | 196 |
| ក្រចេះ | 6 | 56 | 120 | 176 |
| ព្រះវិហារ | 3 | 75 | 87 | 162 |
| ពោធិ៍សាត់ | 5 | 73 | 79 | 152 |
| រតនគិរី | 3 | 62 | 85 | 147 |
| ស្វាយរៀង | 7 | 51 | 82 | 133 |
| ប៉ៃលិន | 4 | 49 | 74 | 123 |
| ឧត្តរមានជ័យ | 4 | 32 | 62 | 94 |
| មណ្ឌលគិរី | 1 | 33 | 21 | 54 |
| ស្ទឹងត្រែង | 3 | 28 | 26 | 54 |
| កែប | 1 | 13 | 28 | 41 |
| កោះកុង | 1 | 1 | 11 | 12 |
| ត្បូងឃ្មុំ | 0 | 0 | 0 | 0 |
| សរុប | 406 | 7,776 | 8,803 | 16,579 |

ប្រភព: MoSVY, 2017.

# កុមារដែលពុំមានចុះសំបុត្រកំណើត



ការចុះសំបុត្រកំណើតនៅកម្ពុជាមានការកើនឡើងតិចតួច ចាប់តាំងពីឆ្នាំ 2010 មក (រូបភាព 3.1)។ ទោះជាយ៉ាងណាក៏ដោយ កុមារអាយុក្រោម 5 ឆ្នាំ 27 ភាគរយ (ស្មើនឹងប្រមាណ 1.6 លាននាក់) ពុំទាន់បានចុះសំបុត្រកំណើតក្នុងឆ្នាំ 2014 ឡើយ។

កម្រិតនៃការចុះសំបុត្រកំណើតនៅកម្ពុជា បង្ហាញឱ្យឃើញពីគម្លាតមួយចំនួន លើកលែងតែការចុះសំបុត្រកំណើត បែងចែកតាមភេទ។ ការចុះសំបុត្រកំណើតមានការកើនឡើងទៅតាមអាយុ ស្ថានភាពទ្រព្យធនរបស់គ្រួសារ កម្រិតវប្បធម៌របស់ម្ដាយ និងទីកន្លែងរស់នៅក្នុងតំបន់ប្រជុំជន (រូបភាព 3.2)។ ភាពខុសប្លែកគ្នាក៏មានក្នុងកម្រិតគួរឱ្យកត់សម្គាល់ផងដែរ រវាងខេត្តមួយ និងខេត្តមួយទៀត ដោយខេត្តចំនួន 4 (ភ្នំពេញ ស្វាយរៀង កណ្ដាល និងឧត្តរមានជ័យ) មានការចុះសំបុត្រកំណើតជាង 80 ភាគរយ ខណៈពេលខេត្ត 2 ផ្សេងទៀត (ខេត្តក្រចេះ និងមណ្ឌលគិរី / រតនគិរី) មានការចុះសំបុត្រកំណើតតិចជាង 50 ភាគរយ (រូបភាព 3.3)។ ការចុះសំបុត្រកំណើតក្នុងចំណោមកុមារមកពីតំបន់ប្រជុំជន មានកម្រិតខ្ពស់ជាងការចុះសំបុត្រកំណើតរបស់កុមារនៅតំបន់ជនបទ។ ស្រដៀងគ្នានេះដែរ ការចុះសំបុត្រកំណើតរបស់កុមារ ដែលរស់នៅក្នុងគ្រួសារដែលមានជីវភាពធូរធាជាងគេ 20 ភាគរយ (វាស់វែងដោយសន្ទស្សន៍នៃការមានទ្រព្យសម្បត្តិរបស់គ្រួសារ ជាជាងការវាស់វែងដោយចំណូលរបស់គ្រួសារ) មានកម្រិតខ្ពស់ជាងកុមារមកពីគ្រួសារក្រីក្រជាងគេ 20 ភាគរយ (រូបភាព 3.4)។ ក្នុងរយៈពេលប្រមាណមួយទសវត្សរ៍នេះ គម្លាតនៃអត្រាចុះសំបុត្រកំណើតរវាងកុមារ មកពីបញ្ចភាគទ្រព្យសម្បត្តិខ្ពស់ជាងគេ និងទាបជាងគេ កើនឡើងបន្តិចបន្តួច។

ប្រសិនបើនិន្នាការដែលត្រូវបានអង្កេតឃើញចន្លោះពីឆ្នាំ 2010 និង 2014 នៅតែបន្តនោះ ប្រទេសកម្ពុជានឹងអាចសម្រេចបាននូវគោលដៅចុះសំបុត្រកំណើត សម្រាប់ប្រជាជនគ្រប់រូបត្រឹមឆ្នាំ 2025 (រូបភាព 3.5) ដែលជាចំណុចដៅ 16.9 នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។[12] ទិន្នន័យដែលអាចរកបានបង្ហាញថា វឌ្ឍនភាពបែបនេះគឺជាអ្វីដែលអាចសម្រេចទៅបាន។ អត្រានៃកំណើនចាប់ពីឆ្នាំ 2010 មកគឺលឿនជាងអត្រាមធ្យម ដែលសម្រេចបានក្នុងរយៈពេល 9 ឆ្នាំ ចាប់គិតពីឆ្នាំ 2005 ដល់ឆ្នាំ 2014។

**រូបភាព 3.1 ភាគរយកុមារអាយុក្រោម 5 ឆ្នាំ ដែលបានចុះសំបុត្រកំណើត បែងចែកទៅតាមថា តើពួកគេមានសំបុត្របញ្ជាក់កំណើតឬអត់**




ប្រភព៖ CDHS, 2005, 2010, 2014

ការចុះសំបុត្រកំណើតឱ្យកុមារនៅពេលកើត មានសារៈសំខាន់យ៉ាងខ្លាំង សម្រាប់ឱ្យកុមារទទួលបានសេវាសំខាន់ៗ ដូចជា កិច្ចការពារក្នុងករណីដែលកុមារត្រូវបានបំបែកចេញពីគ្រួសារ ត្រូវបានគេបោះបង់ចោល ឬទទួលរងការរំលោភបំពាន ជាដើម។ ការចុះសំបុត្រកំណើតក៏អាចការពារកុមារមិនទាន់គ្រប់អាយុពីការរៀបអាពាហ៍ពិពាហ៍ ពលកម្មកុមារ និងការជ្រើសរើសឱ្យបំពេញកាតព្វកិច្ចយោធាផងដែរ។ ការចុះសំបុត្រកំណើតគឺជាសិទ្ធិមួយផង និងជាវិធីសម្រាប់ធានាមិនឱ្យមានការបំពានសិទ្ធិដទៃទៀត ដើម្បីកុំឱ្យការរំលោភបំពានសិទ្ធិទាំងនោះកើតឡើងដោយគ្មានអ្នកណាសម្គាល់ដឹង។ មាតាបិតានៅកម្ពុជាមានកាតព្វកិច្ចចុះសំបុត្រកំណើតកូនរបស់ខ្លួន ក្រោមអនុក្រឹតលេខ 103 ស្ដីពីការចុះអត្រានុកូលដ្ឋាន។

**រូបភាព 3.2 ភាគរយនៃកុមារអាយុក្រោម 5 ឆ្នាំ ដែលបានចុះសំបុត្រកំណើត បែងចែកទៅតាមសាវតា**




សម្គាល់៖ ទិន្នន័យអប់រំ សំដៅលើកម្រិតវប្បធម៌/អប់រំរបស់ម្តាយ

ប្រភព៖ CDHS 2014

**រូបភាព 3.3 ភាគរយកុមារអាយុក្រោម 5 ឆ្នាំ ដែលបានចុះសំបុត្រកំណើត បែងចែកតាមខេត្ត**




ប្រភព៖ CDHS, 2014

**រូបភាព 3.4 ភាគរយកុមារអាយុក្រោម 5 ឆ្នាំ ដែលចុះសំបុត្រកំណើត បែងចែកទៅតាមសាវតា និងឆ្នាំនៃការអង្កេត**




ប្រភព៖ CDHS, 2005, 2010, 2014

**រូបភាព 3.5 ការធ្វើចំណោល ការចុះសំបុត្រកំណើត**




ប្រភព៖ ការវិភាគរបស់យូនីសេហ្វ ផ្អែកទៅតាម CDHS, 2005, 2010, 2014

# កូនក្រមុំវ័យកុមារ



ការរៀបអាពាហ៍ពិពាហ៍វ័យកុមារនៅកម្ពុជា មានការថយចុះជាបន្តបន្ទាប់។ ក្នុងឆ្នាំ 1989 ក្នុងចំណោមស្រ្តីអាយុ 20 ទៅ 24 ឆ្នាំ មាន 28 ភាគរយរៀបការមុនអាយុ 18 ឆ្នាំ បើធៀបនឹង 19 ភាគរយក្នុងឆ្នាំ 2014 (រូបភាព 4.1)។ មានការសម្រេចបានវឌ្ឍនភាពកាន់តែលឿនទៅទៀត ក្នុងករណីការរៀបអាពាហ៍ពិពាហ៍ក្មេងស្រីអាយុក្រោម 15 ឆ្នាំ ពោលគឺមានការថយចុះពី 7 ភាគរយក្នុងឆ្នាំ 1999 មកនៅ 2 ភាគរយក្នុងឆ្នាំ 2014។ ទោះជាយ៉ាងណាក៏ដោយ វឌ្ឍនភាពនៃការកាត់បន្ថយការរៀបអាពាហ៍ពិពាហ៍វ័យកុមារជារួម ហាក់បីដូចជានៅទ្រឹងក្នុងរយៈពេល 5 ឆ្នាំចុងក្រោយនេះ ហើយមានក្មេងស្រីជាច្រើននាក់នៅបន្តរៀបការក្នុងវ័យជំទង់។ អាយុមេដ្យានសម្រាប់ការរៀបការជាលើកដំបូងរបស់ស្រ្តីនៅកម្ពុជានៅបន្តថេរក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ពោលគឺស្រ្តីរៀបការនៅអាយុចន្លោះពី 20 ទៅ 21 ឆ្នាំ។

ការរៀបអាពាហ៍ពិពាហ៍វ័យកុមារ ត្រូវបានគេដឹងថាកើតមានជាទូទៅក្នុងក្រុមជនជាតិភាគតិចមួយចំនួន និងនៅតាមតំបន់មួយចំនួនរបស់ប្រទេសកម្ពុជា។ គួរឱ្យសោកស្តាយ ព័ត៌មានអំពីជាតិពន្ធុ ពុំត្រូវបានប្រមូលក្នុងការអង្កេតប្រជាសាស្រ្ត និងសុខភាពកម្ពុជាឆ្នាំ 2014 ឡើយ ដូច្នេះគេពុំអាចធ្វើការវិភាគអំពីការរៀបអាពាហ៍ពិពាហ៍វ័យកុមារបែងចែកទៅតាមជាតិ ពន្ធុបានឡើយ។ ទោះជាយ៉ាងណាក៏ដោយ ភាគរយនៃស្រ្តីវ័យក្មេងអាយុ 20 ទៅ 24 ឆ្នាំ ដែលរៀបការមុនអាយុ 18 ឆ្នាំ បង្ហាញឱ្យឃើញពីការប្រែប្រួលខ្លាំងតាមទីតាំងភូមិសាស្រ្ត ពោលគឺមានចាប់ពីកម្រិតខ្ពស់ដល់ទៅ 36 ភាគរយ ក្នុងខេត្តមណ្ឌលគិរី និងរតនគិរី មកនៅទាប 5 ភាគរយក្នុងរាជធានីភ្នំពេញ (រូបភាព 4.2)។

ប្រសិនបើអត្រានៃវឌ្ឍនភាពក្នុងការកាត់បន្ថយការរៀបអាពាហ៍ពិពាហ៍វ័យកុមារ ដែលអង្កេតឃើញក្នុងរយៈពេល 25 ឆ្នាំចុងក្រោយនេះ នៅតែបន្ត នោះភាគរយនៃស្រ្តីអាយុពី 20 ទៅ 24 ឆ្នាំ ដែលរៀបការពេលដែលខ្លួននៅជាកុមារនៅឡើយ អាចបន្តមានការថយចុះពី 28 ភាគរយក្នុងឆ្នាំ 1989 មក 19 ភាគរយក្នុងឆ្នាំ 2014 មក 14 ភាគរយក្នុងឆ្នាំ 2030 (រូបភាព 4.3)។[13] ប៉ុន្តែប្រសិនបើអាត្រាថយចុះនេះកើនឡើងទ្វេដង នោះប្រេវ៉ាឡង់នៃការរៀបអាពាហ៍ពិពាហ៍វ័យកុមារ អាចបន្តថយចុះទៀតត្រឹម 11 ភាគរយត្រឹមឆ្នាំ 2030។ ប៉ុន្តែ តួលេខនេះមានន័យថាមានស្រ្តីប្រមាណម្នាក់ក្នុងចំណោម ១០នាក់បានរៀបការពេលនៅវ័យកុមារ។

**រូបភាព 4.1 ភាគរយស្រ្តីអាយុ 20 ទៅ 24 ឆ្នាំ ដែលបានរៀបការ / រស់នៅជាមួយគូស្រកររបស់ខ្លួននៅមុនអាយុ 15 និង 18 ឆ្នាំ**




សម្គាល់៖ កម្រិតនៃការរៀបអាពាហ៍ពិពាហ៍វ័យកុមារកន្លងមក ដូចត្រូវបានវាស់វែងក្នុងឆ្នាំ 2014 ពឹងអាស្រ័យលើអាយុរៀបការ ដែលរាយការណ៍ដោយក្រុមស្រ្តីចំណាស់ៗ។ តួលេខទាំងនេះប្រែប្រួលទៅតាមភាពមិនប្រាកដប្រជាមួយចំនួន ជាពិសេស ដោយសារមរណភាពរបស់ស្រ្តី រវាងពេលដែលពួកគេរៀបអាពាហ៍ពិពាហ៍ និងពេលដែលធ្វើការអង្កេតនេះ។ ស្រ្តីដែលបាត់បង់ជីវិតនៅក្នុងក្រុមនេះ ច្រើនតែមកពីគ្រួសារដែលក្រីក្រ ឬគ្រួសារដែលជួបការលំបាក ដូច្នេះពួកគេងាយនឹងរៀបការនៅវ័យកុមារ។ កម្រិតនៃការរៀបអាពាហ៍ពិពាហ៍កុមារដែលរាយការណ៍ដោយស្រ្តីដែលនៅមានជីវិត អាចបង្ហាញពីតួលេខទាបជាងតួលេខជាក់ស្តែង

ប្រភព៖ CDHS, 2014

នៅកម្ពុជា ការរៀបអាពាហ៍ពិពាហ៍មុនអាយុ 18 ឆ្នាំគឺខុសច្បាប់ ប្រសិនបើពុំមានការយល់ព្រមពីមេបា។ ចាប់ពីអាយុ 16 ដល់អាយុ 18 ឆ្នាំ ក្មេងស្រី និងក្មេងប្រុសអាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បាន ប្រសិនបើមានការយល់ព្រមពីមេបា។ ក្នុងរបាយការណ៍នេះ "អាពាហ៍ពិពាហ៍វ័យកុមារ" ត្រូវបានឱ្យនិយមន័យថាជា ការរៀបអាពាហ៍ពិពាហ៍ ឬក៏ការរស់នៅជាមួយគ្នាមុនអាយុ 18 ឆ្នាំ ស្របទៅតាមទស្សនវិស័យផ្អែកសិទ្ធិ បើទោះបីជាការរៀបការចាប់ពីអាយុ 16 ឆ្នាំឡើងទៅជាទង្វើស្របច្បាប់ក្នុងប្រទេសកម្ពុជា នៅពេលមានការឯកភាពពីមេបាយ៉ាងណាក៏ដោយ។

**រូបភាព 4.2 ភាគរយស្ត្រីនៅអាយុ 20-24 ឆ្នាំ ដែលបានរៀបការ ឬរស់នៅជាមួយគូស្រករមុនអាយុ 18 ឆ្នាំ បែងចែកទៅតាមខេត្ត**




ប្រភព៖ CDHS, 2014

**រូបភាព 4.3 ភាគរយស្ត្រីអាយុ 20-24 ឆ្នាំ ដែលរៀបការ/នឹងរៀបការមុនអាយុ 18 ឆ្នាំ ផ្អែកតាមសេណារីយ៉ូចំនួន 2**




ប្រភព៖ ការវិភាគរបស់យូនីសេហ្វ ដោយផ្អែកទៅតាម CDHS, 2014 និងទិន្នន័យប្រជាជន ដែលបានពីបាយការណ៍ចំនួនប្រជាជនសកលលោក កែសម្រួលឆ្នាំ 2015 កំណែ DVD ដែលផលិតដោយផ្នែកប្រជាជន នៃនាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិ ទីក្រុងញូយ៉ក ឆ្នាំ 2015





# ការមានផ្ទៃពោះរបស់ក្មេងជំទង់ និងការឆាប់មានកូន

ការឆាប់មានកូនក្នុងវ័យជំទង់ អាចធ្វើឱ្យក្មេងស្រី និងកូនដែលទើបនឹងកើតរបស់ពួកគេ ប្រឈមនឹងការព្រួយបារម្ភ ពាក់ព័ន្ធនឹងសុខភាព និងកិច្ចការពារជាច្រើន។ ការសិក្សាដែលបានធ្វើឡើងកាលពីឆ្នាំ 2015 លើអ្នកដែលមានលទ្ធភាពសម្រាលកូន ដោយប្រើទិន្នន័យពីប្រទេសប្រេស៊ីល គ័រតេម៉ាឡា ឥណ្ឌា ហ្វីលីពីន និងអាហ្វ្រិកខាងត្បូង[14] បានរកឃើញថាអាយុវ័យក្មេងរបស់ម្តាយ (ក្រោម 20 ឆ្នាំ) មានទំនាក់ទំនងជាមួយនឹងកូនកើតមិនគ្រប់ទម្ងន់ កូនកើតមុនខែ ភាពក្រិនក្រេះ ក្នុងកំឡុងរយៈពេល 2 ឆ្នាំដំបូង និងការរៀនមិនចប់សាលាមធ្យមសិក្សារបស់កូន។

កុមារដែលមានម្តាយវ័យក្មេងក្នុងប្រទេសចំណូលទាប និងមធ្យម តែងជួបការលំបាកនៅពេលសម្រាល និងជួបប្រទះបញ្ហាអាហារូបត្ថម្ភ និងការរៀនសូត្រក្នុងវ័យកុមាររបស់ខ្លួន។

លើសពីនេះ ការឆាប់មានកូនក៏មានផលប៉ះពាល់ជាអវិជ្ជមានលើឱកាសការងារ និងអប់រំនាពេលអនាគតរបស់ម្តាយផងដែរ។ កិច្ចខិតខំប្រឹងប្រែង ទប់ស្កាត់មិនឱ្យក្មេងស្រីឆាប់មានកូន គួរពង្រឹងបន្ថែមទៀតតាមរយៈការរៀបចំផែនការគ្រួសារ និងការអប់រំ និងការផ្តល់ភាពអង់អាចដល់ស្ត្រី។

**រូបភាព 5.1 ភាគរយក្មេងស្រីអាយុ 15 - 19 ឆ្នាំ ដែលចាប់ផ្តើមមានកូន បែងចែកទៅតាមសាវតាររបស់ពួកគេ**




ប្រភព៖ CDHS, 2014

នៅកម្ពុជា ក្នុងចំណោមក្មេងស្រីអាយុ 15 ដល់ 19 ឆ្នាំចំនួន 8 នាក់ មានជិតម្នាក់ ដែលចាប់ផ្តើមមានកូន។ ភាគរយក្មេងជំទង់ដែលធ្លាប់សម្រាលកូន មានការប្រែប្រួលពីខេត្តមួយទៅខេត្តមួយ។ ភាគរយនេះគឺទាបជាងគេក្នុងខេត្តបាត់ដំបង/ប៉ៃលិន (4 ភាគរយ) និងខ្ពស់ជាងគេក្នុងខេត្តមណ្ឌលគិរី/រតនគិរី (34 ភាគរយ)។ ភាគរយនៃក្មេងស្រីជំទង់ដែលចាប់ផ្តើមមានកូនបានរកឃើញថា មានការកើនឡើងនៅពេលដែលអាយុរបស់ពួកគេកាន់តែច្រើន ប៉ុន្តែថយចុះទៅតាមកត្តាអ្នករស់នៅទីក្រុង ទ្រព្យសម្បត្តិរបស់គ្រួសារ និងការអប់រំ (រូបភាព 5.1)។

ពីឆ្នាំ 2000 ដល់ 2014 ការមានកូន ក៏មានការកើនឡើងផងដែរក្នុងចំណោមក្មេងស្រីជំទង់ (19 ឆ្នាំ) ខណៈពេលដែលការមានកូនក្នុងចំណោមក្មេងស្រីដែលមានអាយុតិចជាងនេះ (15 ទៅ 18 ឆ្នាំ) នៅប្រហាក់ប្រហែលគ្នា (រូបភាព 5.2)។ កំណើននៃការឆាប់មានកូនក្នុងចំណោមក្មេងស្រីជំទង់ ត្រូវបានសង្កេតឃើញថា មានប្រភពភាគច្រើនចេញពីតំបន់ជនបទ ពីអ្នកដែលពុំមានការអប់រំ ឬរៀនបានត្រឹមបឋមសិក្សា និងអ្នកមកពីបញ្ចភាគទ្រព្យសម្បត្តិកម្រិតទាបជាងគេ។ នៅក្នុងរយៈពេលដូចគ្នានេះ ការផ្លាស់ប្តូរមានតិចតួចតែប៉ុណ្ណោះ ក្នុងចំណោមក្មេងស្រីជំទង់អាយុច្រើនមកពីតំបន់ប្រជុំជន ក្មេងស្រីដែលបានទទួលការអប់រំកម្រិតមធ្យមសិក្សា និងក្មេងស្រីមកពីគ្រួសារដែលស្ថិតនៅក្នុងបញ្ចភាគទ្រព្យសម្បត្តិខ្ពស់ជាងគេ (រូបភាព 5.3)។

**រូបភាព 5.2 ភាគរយនៃក្មេងស្រីអាយុ 15 - 19 ឆ្នាំ ដែលចាប់ផ្តើមមានកូនបែងចែក ទៅតាមអាយុ និងឆ្នាំនៃការអង្កេត**




ប្រភព៖ CDHS, 2000 និង 2014

**រូបភាព 5.3 ភាគរយនៃក្មេងស្រីអាយុ 18 - 19 ឆ្នាំ ដែលចាប់ផ្តើមមានកូន បែងចែកទៅតាមលក្ខណៈសាវតា និងឆ្នាំអង្កេត**




ប្រភព៖ CDHS, 2000 និង 2014

**រូបភាព 5.4 ភាគរយស្ត្រីអាយុ 20 ទៅ 49 ឆ្នាំ ដែលធ្លាប់សម្រាលកូនមុនអាយុ 18 ឆ្នាំ បែងចែកតាមអាយុបច្ចុប្បន្ន**




ប្រភព៖ CDHS, 2000 និង 2014

**រូបភាព 5.5 ភាគរយស្ត្រីអាយុ 20 ទៅ 24 ឆ្នាំ ដែលធ្លាប់សម្រាលកូន / នឹងសម្រាលកូនមុនអាយុ 18 ឆ្នាំ**




ប្រភព៖ ការវិភាគរបស់យូនីសេហ្វ ផ្អែកតាម CDHS, 2014

នៅពេលពិនិត្យលើនិន្នាការនៃការឆាប់មានកូន ភាគរយស្ត្រីក្នុងក្រុមដែលមានអាយុក្មេងជាងគេ (20 ដល់ 29 ឆ្នាំ) ដែលសម្រាលកូនមុនអាយុ 18 ឆ្នាំ មានកម្រិតទាបជាងភាគរយរបស់ស្ត្រីអាយុច្រើន (30 - 49 ឆ្នាំ) តិចតួច។ នេះបង្ហាញពីនិន្នាការ ក្នុងការពន្យារពេលមានកូនរបស់ស្ត្រីវ័យក្មេង (រូបភាព 5.4)។

ប្រសិនបើអត្រានៃការពន្យារពេលមានកូន ដែលត្រូវបានអង្កេតឃើញក្នុងរយៈពេល 15 ឆ្នាំ ចន្លោះពីឆ្នាំ 1989 (13 ភាគរយ) និង 2014 (7 ភាគរយ) នៅបន្តមានទៀត នោះស្ត្រីអាយុ 20 ដល់ 24 ឆ្នាំ ដែលសម្រាលកូនក្រោមអាយុ 18 ឆ្នាំ អាចថយចុះមកនៅ 4 ភាគរយក្នុងឆ្នាំ 2030 (រូបភាព 5.5)។[15] ប៉ុន្តែប្រសិនបើអត្រាដែលអង្កេតឃើញនេះកើតឡើងទ្វេដង នោះប្រេវ៉ាឡង់នៃការឆាប់មានកូនអាចថយចុះមកនៅត្រឹម2ភាគរយ នៅឆ្នាំ 2030។

# អំពើហិង្សាលើកុមារ



ផ្អែកលើរបកគំហើញនៃការស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា[18] 53 ភាគរយនៃស្ត្រី និង 54 ភាគរយនៃបុរសអាយុ 18 ដល់ 24 ឆ្នាំ បានរាយការណ៍ពីការទទួលរងអំពើហិង្សាផ្លូវកាយ យ៉ាងហោចណាស់មួយដងមុនអាយុ 18 ឆ្នាំ។ ក្នុងចំណោមកុមារអាយុ 13 ដល់ 17 ឆ្នាំ ដែលទទួលរងអំពើហិង្សាផ្លូវកាយក្នុងរយៈពេល 12 ខែចុងក្រោយ មាន 15 ភាគរយជាក្មេងស្រី និង 13 ភាគរយជាក្មេងប្រុស។[19]

អំពើហិង្សាផ្លូវចិត្តក្នុងវ័យកុមារ ក៏កើតឡើងជាទូទៅផងដែរ៖ ក្នុងចំណោមអ្នកដែលមានអាយុ 18 ដល់ 24 ឆ្នាំ មានស្រី 19 ភាគរយ និងប្រុស 25 ភាគរយ ដែលបានរាយការណ៍ថាបានទទួលរងអំពើហិង្សាផ្លូវចិត្តមុនអាយុ 18 ឆ្នាំ។ ភាគរយ សម្រាប់អ្នកដែលមានអាយុពី 13 ដល់ 17 ឆ្នាំ មានកម្រិតទាបជាងនេះបន្តិចពោលគឺ ក្មេងប្រុស និងក្មេងស្រី 10 ភាគរយដូចគ្នា បាននិយាយថាពួកគេធ្លាប់ទទួលរងអំពើហិង្សាផ្លូវចិត្តក្នុងរយៈពេល 12 ខែចុងក្រោយនេះ។

មាន4%នៃស្ត្រី  និង៦%នៃបុរសដែលមានអាយុពី18ទៅ24ឆ្នាំដែលបានរាយការណ៍អំពីអំពើហិង្សាផ្លូវភេទក្នុងរូបភាពណាមួយមុនពួកគេមានអាយុ18ឆ្នាំ។ ក្នុងចំណោមអ្នកដែលមានអាយុ 15 ដល់ 17 ឆ្នាំ ក្មេងស្រី 3 ភាគរយ និងក្មេងប្រុសក្រោម 1 ភាគរយ ដែលបានរាយការណ៍ពីករណីអំពើហិង្សាផ្លូវភេទក្នុងរយៈពេល 12 ខែចុងក្រោយនេះ។

ខណៈពេលដែលការទទួលរងអំពើហិង្សាពេញមួយជីវិតមានកម្រិតខ្ពស់ មានកុមារតិចតួចតែប៉ុណ្ណោះដែលធ្លាប់ទទួលរងអំពើហិង្សានៅក្នុងរយៈពេល 12 ខែចុងក្រោយនេះ (រូបភាព 6.1)។

**រូបភាព 6.1 ភាគរយនៃក្មេងជំទង់អាយុ 13 ដល់ 17 ឆ្នាំ ដែលធ្លាប់ទទួលរងអំពើហិង្សានៅក្នុងរយៈពេល 12 ខែចុងក្រោយ បែងចែកតាមភេទ និងប្រភេទនៃអំពើហិង្សា**




ប្រភព៖ ការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា CVACS 2013

ការទទួលរងអំពើហិង្សាក្នុងវ័យកុមារ គឺកើតឡើងជាទូទៅនៅកម្ពុជា។ ក្នុងឆ្នាំ 2015 អត្រាមនុស្សឃាតលើកុមារ អាយុ 0 ដល់ 19 ឆ្នាំ មានប្រមាណជា 1 ករណី ក្នុង 100000 នាក់។[16] ក្រៅពីផលប៉ះពាល់មកលើបុគ្គលម្នាក់ៗ ផលប៉ះពាល់មកលើសង្គម និងសេដ្ឋកិច្ចរួមមាន ការដាក់បន្ទុកបន្ថែមលើប្រព័ន្ធថែទាំសុខភាព ដោយសារមានការប្រើប្រាស់សេវាច្រើនលើសលុប។ ក្នុងករណីធ្ងន់ធ្ងរ អំពើហិង្សាលើកុមារបែបនេះ អាចនាំឱ្យមានពិការភាព ឬការស្លាប់ ក៏ដូចជាបង្កើនកម្រិតនៃអំពើហិង្សា និងបទល្មើសព្រហ្មទណ្ឌ។[17] ការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា 2013 បានរកឃើញថា ផលប៉ះពាល់លើសុខភាពមួយចំនួន ដែលកើតឡើងដោយសារអំពើហិង្សាលើកុមារ មានកម្រិតស្មើនឹង 1 ភាគយ នៃផលិតផលសរុបក្នុងស្រុករបស់ប្រទេសកម្ពុជា ឬស្មើនឹង 168 លានដុល្លារអាមេរិច។ ការបាត់បង់ផលិតភាពដោយសារអំពើហិង្សាលើកុមារ ស្មើនឹង 0.55 ភាគរយនៃ ផ.ស.ស ឬ 83 លានដុល្លារអាមេរិច។

ការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារនៅក្នុងប្រទេសកម្ពុជា ទាំងការអង្កេតប្រជាសាស្រ្ត និងសុខភាពកម្ពុជា (CDHS) សុទ្ធតែបានលើកឡើងថា អ្នកប្រព្រឹត្តិអំពើហិង្សាលើកុមារ ភាគច្រើនគឺជាមនុស្សដែលជនរងគ្រោះស្គាល់ និងជាអ្នកនៅក្នុងគ្រួសារ ឬសហគមន៍តែមួយ។

ក្នុងចំណោមកុមារអាយុ 13 ទៅ 17 ឆ្នាំ ដែលបានរាយការណ៍ថា ធ្លាប់ទទួលរងអំពើហិង្សាផ្លូវភេទមុនអាយុ 18 ឆ្នាំ ជនដែលប្រព្រឹត្តិករណីបែបនេះដំបូង ញឹកញាប់ជាងគេគឺមិត្តភក្តិ (សម្រាប់ក្មេងស្រី) ឬសមាជិកគ្រួសារ (សម្រាប់ក្មេងប្រុស) (រូបភាព 6.2)។ អាយុជាមធ្យមនៃការទទួលរងអំពើហិង្សាផ្លូវភេទដំបូងមុនអាយុ 18 ឆ្នាំ ក្នុងចំណោមមនុស្សដែលមានអាយុពី 18 ទៅ 24 ឆ្នាំ គឺអាយុ15 ឆ្នាំសម្រាប់ស្រ្តី និង 10 ឆ្នាំ សម្រាប់បុរស។

ស្រដៀងគ្នានេះដែរ អ្នកឆ្លើយតបអាយុ 13 ដល់ 17 ឆ្នាំ ទំនងជាទទួលរងអំពើហិង្សាផ្លូវកាយពីឪពុកម្តាយ អ្នកផ្តល់ការថែទាំ ឬសាច់ញាតិជាមនុស្សពេញវ័យដទៃទៀត ឬពីសមាជិកសហគមន៍ណាម្នាក់ (រូបភាព 6.3)។ អ្នកឆ្លើយតបភាគច្រើនក្នុងក្រុមអាយុនេះ ពោលគឺ 64 ភាគរយនៃក្មេងស្រី និង 55 ភាគរយនៃក្មេងប្រុស បានរាយការណ៍ថា អ្នកដែលប្រព្រឹត្តិករណីអំពើហិង្សាផ្លូវកាយដំបូងគេមកលើពួកគេ គឺឪពុកម្តាយ ភាគច្រើនគឺម្តាយ ឬម្តាយចុង។ ឪពុក ឬឪពុកចុង គឺជាមនុស្សដែលទំនងជាប្រព្រឹត្តិអំពើហិង្សាដំបូងញឹកញាប់ជាងគេទី 2 សម្រាប់ទាំងក្មេងស្រី (19 ភាគរយ) ទាំងក្មេងប្រុស (36 ភាគរយ) ដោយក្មេងប្រុសរាយការណ៍ពីករណីទទួលរងអំពើហិង្សាពីឪពុក ឬឪពុកចុង មានច្រើនជាងក្មេងស្រីដល់ទៅ 2 ដង។ អ្នកប្រព្រឹត្តិអំពើហិង្សាក្នុងសហគមន៍ញឹកញាប់ជាងគេ គឺគ្រូបង្រៀន។ ក្នុងចំណោមអ្នកដែលមានអាយុ 13 ទៅដល់ 17 ឆ្នាំ មានជាងពាក់កណ្តាលសម្រាប់ទាំងក្មេងស្រី (59 ភាគរយ) ទាំងក្មេងប្រុស (52 ភាគរយ) ដែលបានរាយការណ៍ថាលោកគ្រូ គឺជាអ្នកដែលប្រព្រឹត្តិអំពើហិង្សាដំបូងមកលើពួកគេ បន្ទាប់មកគឺអ្នកគ្រូ។

ក្នុងចំណោមអ្នកឆ្លើយតបអាយុ 13 ទៅដល់ 17 ឆ្នាំ ដែលទទួលរងអំពើហិង្សាផ្លូវចិត្តពីឪពុកម្តាយ អ្នកផ្តល់ការថែទាំ ឬសមាជិកគ្រួសារផ្សេងទៀត ក្មេងស្រី និងក្មេងប្រុសប្រុសភាគច្រើនបានរាយការណ៍ថា ម្តាយ ឬម្តាយចុងរបស់ពួកគេ គឺជាអ្នកប្រព្រឹត្តិអំពើហិង្សាបែបនេះដំបូងមកលើពួកគេ (រូបភាព 6.4)។[20] ពុំមានព័ត៌មានអំពីដៃគូស្និទ្ធស្នាល ជាអ្នកប្រព្រឹត្តិករណីអំពើហិង្សាផ្លូវចិត្តដំបូងគេឡើយ។

**រូបភាព 6.2 ភាគរយនៃក្មេងជំទង់អាយុ 13 ទៅ 17 ឆ្នាំ ដែលទទួលរងអំពើហិង្សាផ្លូវភេទ បែងចែកតាមភេទ និងបែងចែកតាមអ្នកប្រព្រឹត្តិអំពើហិង្សាផ្លូវភេទដំបូងគេ**




ប្រភព៖ CVACS, 2013

**រូបភាព 6.3 ភាគរយក្មេងជំទង់អាយុ 13 - 17 ឆ្នាំ ដែលទទួលរងអំពើហិង្សាផ្លូវកាយ បែងចែកតាមអាយុ និងអ្នកប្រព្រឹត្តិអំពើហិង្សាផ្លូវកាយដំបូងគេ**




ប្រភព៖ CVACS, 2013

**រូបភាព 6.4 ភាគរយក្មេងជំទង់អាយុ 13 ដល់ 17 ឆ្នាំ ដែលទទួលរងអំពើផ្លូវចិត្តពីសមាជិកគ្រួសារ បែងចែកតាមភេទ និងបែងចែកតាមអ្នកប្រព្រឹត្តិករណីអំពើហិង្សាផ្លូវចិត្តដំបូងគេ**




ប្រភព៖ របាយការណ៍អធិការកិច្ច ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ 2016

ឥរិយាបទចំពោះការវាយដំប្រពន្ធ គឺជារង្វាស់ដ៏សំខាន់ សម្រាប់វាស់វែងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងបទដ្ឋានវប្បធម៌ ដែលជម្រុញឱ្យមានការប្រព្រឹត្តិអំពើហិង្សាលើស្ត្រី។ ឥរិយាបទទាំងនេះ ក៏បង្ហាញពីកម្រិតនៃអំពើហិង្សា ដែលប្រព្រឹត្តិដោយដៃគូស្និទស្នាល ក្នុងទម្រង់ជាអំពើហិង្សាផ្លូវចិត្ត ដែលកុមារក៏ប្រឈមនឹងអំពើហិង្សាបែបនេះផងដែរ។



**រូបភាព 6.5 ភាគរយនៃក្មេងស្រី និងស្ត្រីអាយុ 15 ដល់ 49 ឆ្នាំ ដែលយល់ស្របថា ប្តី/ដៃគូ មានហេតុផលសមស្រប ក្នុងការវាយដំប្រពន្ធ/ដៃគូរបស់ខ្លួន ក្រោមកាលៈទេសៈមួយចំនួន**




ប្រភព៖ CDHS, 2014

**រូបភាព 6.6 ភាគរយស្ត្រី និងក្មេងស្រី និងក្មេងប្រុស និងបុរស អាយុ 15 ដល់ 49 ឆ្នាំ ដែលយល់ស្របថា ប្តី/ដៃគូ មានហេតុផលសមស្រប ក្នុងការវាយដំប្រពន្ធ/ដៃគូរបស់ខ្លួន ក្រោមកាលៈទេសៈមួយចំនួន**




ប្រភព៖ CDHS, 2014

កុមារក៏អាចទទួលរងផលប៉ះពាល់ជាអវិជ្ជមានផងដែរ នៅពេលដែលពួកគេទទួលរងអំពើហិង្សាក្នុងផ្ទះដោយប្រយោល ឧទាហរណ៍ នៅពេលដែលពួកគេមើលឃើញផ្ទាល់ភ្នែក នូវការប្រព្រឹត្តិអំពើហិង្សាដាក់គ្នារវាងឪពុកម្តាយ ឬអ្នកផ្តល់ការថែទាំជាដើម។[21] ការវិភាគលើទិន្នន័យ ពីការអង្កេត CDHS ឆ្នាំ 2014 បង្ហាញថា ក្នុងចំណោមកុមារអាយុក្រោម 8 ឆ្នាំ 4 នាក់ មានប្រហែលជាម្នាក់ដែលរស់នៅជាមួយម្តាយ ដែលធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្ត ដែលប្រព្រឹត្តិដោយប្តី ឬដៃគូ ក្នុងរយៈពេល 12 ខែចុងក្រោយ។[22]

នេះគឺជាមូលហេតុដែលនាំឱ្យមានការព្រួយបារម្ភ ដោយហេតុថានៅកម្ពុជាក្នុងចំណោមស្ត្រី ដែលមានអាយុពី 15 ទៅ 19 ឆ្នាំ មានពាក់កណ្តាលដែលជឿថា ការវាយដំប្រពន្ធដែលធ្វើឡើងដោយប្តីគឺសមស្រប ដោយសារមូលហេតុយ៉ាងហោចណាស់មួយក្នុងចំណោមមូលហេតុចំនួន 6[23] (រូបភាព 6.5)។ នៅពេលដែលគេពិនិត្យនៅលើទិន្នន័យ បែងចែកតាមក្រុមអាយុ ស្ត្រីដែលមានអាយុកាន់តែច្រើនហាក់បីដូចជាកាន់តែលើកហេតុផលគាំទ្រដល់ការវាយដំប្រពន្ធ នៅក្នុងនោះ 57 ភាគរយនៃស្ត្រីស្ថិតនៅក្នុងក្រុមអាយុច្រើនជាងគេ (45 ដល់ 49 ឆ្នាំ) យល់ស្របថាការវាយដំប្រពន្ធពេលខ្លះជាទង្វើសមហេតុផល បើធៀបជាមួយនឹងតួលេខ 46 ភាគរយនៃស្ត្រី ដែលស្ថិតនៅក្នុងក្រុមដែលមានអាយុតិចជាងគេ (15 - 19 ឆ្នាំ)។

ទិន្នន័យអំពីឥរិយាបទចំពោះការវាយដំប្រពន្ធ ក៏ផ្តល់នូវគន្លឹះបង្ហាញពីការយល់ឃើញចំពោះក្មេងស្រី និងស្ត្រីនៅក្នុងសង្គមមួយផងដែរ។ ហេតុផលដែលលើកឡើងទាំងនេះ អាចចាត់ទុកថាជាការបង្ហាញពីវិសមភាពយេនឌ័រ ដែលគាំទ្រដល់ការប្រើអំពើហិង្សា នៅពេលដែលក្មេងស្រី និងស្ត្រីពុំបានបំពេញទៅតាមតួនាទីយេនឌ័រដែលគេរំពឹងថាពួកគេត្រូវបំពេញ។ ដូច្នេះដោយសារតែមានក្មេងស្រី និងស្ត្រីដល់ទៅពាក់កណ្តាល ដែលជឿថាការវាយដំប្រពន្ធពេលខ្លះគឺជាទង្វើសមហេតុសមផល គេអាចរំពឹងទុកផងដែរថា ការគាំទ្រដល់ការវាយដំប្រពន្ធនៅកម្ពុជារឹតតែមានកម្រិតខ្ពស់ទៅទៀត ក្នុងចំណោមបុរស បើធៀបជាមួយនឹងស្ត្រី។ ប៉ុន្តែទិន្នន័យដែលមានបង្ហាញថា នេះមិនមែនជាករណីបែបនេះឡើយ ដោយសារតែក្នុងចំណោមក្មេងប្រុស និងបុរស 4 នាក់ មានលើសម្នាក់តិចតួចប៉ុណ្ណោះដែលជឿថា ជួនកាលការវាយដំប្រពន្ធគឺជារឿងសមហេតុផល (រូបភាព 6.6)។ នេះក៏ជានិន្នាការចំពោះស្ត្រី និងបុរស ដែលមានអាយុច្រើន និងសម្រាប់ក្មេងស្រី និងក្មេងប្រុសជំទង់ផងដែរ។ នេះអាចបង្ហាញថាក្មេងស្រី និងស្ត្រីស៊ាំនឹងបទដ្ឋានយេនឌ័រ ដែលផ្តល់តម្លៃប្រពន្ធទាបជាងប្តី បើធៀបជាមួយនឹងក្មេងប្រុស និងបុរស។

# ការជួញដូរកុមារ



ដោយសារតែពុំមានទិន្នន័យគ្រប់ជ្រុងជ្រោយអំពីការជួញដូរ គេមិនអាចដឹងអំពីចំនួនជាក់លាក់នៃមនុស្ស រាប់បញ្ចូលទាំងកុមារផងដែរ ដែលទទួលរងផលប៉ះពាល់ឡើយ។ ខណៈពេលដែលការជួញដូរមនុស្ស អាចកើតឡើងសម្រាប់គោលបំណងអ្វីក៏បាន ដូចជាការបម្រើតាមផ្ទះ ឬការធ្វើការងារជាដើម នៅកម្ពុជា មានទិន្នន័យពាក់ព័ន្ធតិចតួចតែប៉ុណ្ណោះដែលផ្តោតលើការធ្វើអាជីវកម្មផ្លូវភេទ។ ការជួញដូរក្នុងទម្រង់ផ្សេងទៀត ដែលត្រូវបានគេដឹងឮថាពិតជាកើតមានពិតប្រាកដមែន រួមមានការជួញដូរមនុស្សដើម្បីគោលបំណងអាពាហ៍ពិពាហ៍ ពលកម្មដោយបង្ខំ ឬការបង្ខំឱ្យដើរសុំទានជាដើម។

> ការជួញដូរកុមារត្រូវបានគេឱ្យនិយមន័យថា ជាការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់ទីជម្រក ឬការទទួលកុមារ សម្រាប់គោលបំណងកេងប្រវ័ញ្ចលើកុមារ។[24]

មានការសិក្សាតូចៗជាច្រើន បានបង្ហាញឱ្យឃើញពីវិសាលភាពនៃការជួញដូរកុមារ សម្រាប់គោលបំណងធ្វើអាជីវកម្មផ្លូវភេទ។ ឧទាហរណ៍ ក្នុងចំណោមករណីជួញដូរដើម្បីធ្វើអាជីវកម្មផ្លូវភេទចំនួន 165 ករណីដែលបានរាយការណ៍ដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងឆ្នាំ 2007 - 2008 មាន 41 ភាគរយ ត្រូវបានរកឃើញថាជាប់ពាក់ព័ន្ធនឹងកុមារ ដែលកុមារអាយុតិចបំផុតគឺត្រឹមតែ 8 ឆ្នាំតែប៉ុណ្ណោះ។ ក្មេងស្រី និងស្ត្រីអាយុ 13 ដល់ 25 ឆ្នាំ គឺជាក្រុមដែលត្រូវបានគេជួញដូរញឹកញាប់ជាងគេ។[25]

បើតាមបេសកកម្មយុត្តិធម៌អន្តរជាតិ ការជួញដូរផ្លូវភេទនៅកម្ពុជា មានការថយចុះគួរឱ្យកត់សម្គាល់ក្នុងទសវត្សរ៍ចុងក្រោយនេះ។ វិធីសាស្ត្រដែលប្រើប្រាស់ក្នុងការសិក្សាប្រេវ៉ាឡង់ចំនួន 2 ដែលធ្វើឡើងដោយអង្គការនេះ ផ្តោតតែទៅលើទីកន្លែងធ្វើអាជីវកម្មផ្លូវភេទប៉ុន្មានប្រភេទ ដែលស្ថិតនៅតាមតំបន់ប្រជុំជនមួយចំនួនតែប៉ុណ្ណោះ។ ប៉ុន្តែការសិក្សាទាំងនេះបង្ហាញថា ការធ្វើអាជីវកម្មផ្លូវភេទលើកុមារ ថយចុះពី 8 ភាគរយក្នុងឆ្នាំ 2012[26] មកនៅត្រឹម 2 ភាគរយក្នុងឆ្នាំ 2015។[27] របកគំហើញនេះគួរតែត្រូវយកមកពិចារណាជាមួយនឹងការប៉ាន់ប្រមាណ ដែលធ្វើឡើងដោយកម្មវិធីអន្តរជាតិសម្រាប់លុបបំបាត់ពលកម្មកុមាររបស់អង្គការពលកម្មអន្តរជាតិនៅឆ្នាំ១៩៩៩ ដែលបានបង្ហាញថា អ្នករកស៊ីផ្លូវភេទនៅកម្ពុជាជាង 15 ភាគរយ មានអាយុចន្លោះពី 9 ដល់ 15 ឆ្នាំ។[28] ក្នុងឆ្នាំ 2014 នគរបាលប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា បានសង្គ្រោះជនរងគ្រោះដោយសារការជួញដូរមនុស្សដែលជាអនីតិជនចំនួន 101 នាក់ ហើយបានបញ្ជូនពួកគេទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខណៈពេលដែលក្រសួងផ្ទាល់បានរកឃើញ និងជួយជនរងគ្រោះចំនួន 336 នាក់ ក្នុងនោះមានអនីតិជនចំនួន 218 នាក់ ក្នុងចំណោមអ្នកដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃមកវិញ។[29]

បើទោះបីជាការជួញដូរផ្លូវភេទមានការថយចុះយ៉ាងណាក៏ដោយ ការជួញដូរកម្លាំងពលកម្មនៅតែជាការព្រួយបារម្ភដ៏ធំមួយនៅកម្ពុជា នេះបើតាមការលើកឡើងរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ។ ការអង្កេតដើរមើល (Walk Free Survey) ឆ្នាំ 2015 បានព្យាយាមកំណត់រកករណីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងពលកម្មដោយបង្ខំក្នុងចំណោមប្រជាជនទូទៅ។ ការអង្កេតនេះបានរកឃើញថាមានប្រជាជនកម្ពុជារហូតដល់ 256800 នាក់ (ឬ 1.65 ភាគរយនៃប្រជាពលរដ្ឋសរុប) រស់នៅក្នុងស្ថានភាពទាសភាពសម័យទំនើប ដែលក្នុងនោះជាង 75 ភាគរយគឺជាជនរងគ្រោះដោយសារការជួញដូរកម្លាំងពលកម្ម។[30] ពួកគេជាច្រើននាក់ត្រូវបានរកឃើញថាកំពុងធ្វើការងារក្នុងឧស្សាហកម្មនេសាទ និងឧស្សាហកម្មផលិតអាហារសមុទ្រ វិស័យកម្មន្តសាល ឬកំពុងរស់នៅក្នុងចំណងអាពាហ៍ពិពាហ៍បែបបង្ខំ។ ប៉ុន្តែពុំមានទិន្នន័យជាក់លាក់អំពីកុមារឡើយ។

បើតាមរបាយការណ៍ស្តីពីការជួញដូរមនុស្សឆ្នាំ 2015 របស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ប្រទេសកម្ពុជាគឺជាប្រទេសឆ្លងកាត់ និងប្រទេសគោលដៅសម្រាប់ករណីពលកម្មកុមារដោយបង្ខំ ការជួញដូរផ្លូវភេទលើកុមារ។ គ្រប់ខេត្តទាំងអស់របស់ប្រទេសកម្ពុជាគឺជាប្រភពនៃការជួញដូរមនុស្ស ខណៈពេលដែលតំបន់ដែលជាគោលដៅនៃការជួញដូរមនុស្សរួមមាន បណ្តាទីក្រុងមួយចំនួនក្នុងប្រទេសកម្ពុជា ក៏ដូចជាតំបន់ដទៃទៀត ជាពិសេស នៅអាហ្វ្រិក។ របាយការណ៍ក៏បង្ហាញផងដែរថា កុមារមកពីគ្រួសារក្រីក្រងាយរងគ្រោះខ្លាំង ដោយសារពលកម្មដោយបង្ខំ ហើយជារឿយៗ ឪពុកម្តាយក៏ជាអ្នកផ្សំគំនិតក្នុងករណីទាំងនេះផងដែរ។ តម្រូវការនៃការលក់ស្ត្រី និងក្មេងស្រីនៅព្រហ្មចារី បន្តជាបញ្ហានៅកម្ពុជា។ បុរសកម្ពុជាគឺជាប្រភពធំជាងគេនៃតម្រូវការពេស្យាកម្មកុមារ។ ប៉ុន្តែ បុរសមកពីតំបន់នេះក្នុងប្រទេសដទៃទៀត ក៏ជាប់ពាក់ព័ន្ធក្នុងទេសចរណ៍ផ្លូវភេទកុមារផងដែរ។

របាយការណ៍ស្តីពីការជួញដូរមនុស្សបានដាក់ប្រទេសកម្ពុជា "កម្រិតទី 2 នៃបញ្ជីឃ្លាំមើល" កាលពីឆ្នាំ 2015 បង្ហាញថាប្រទេសនេះពុំបានខិតខំប្រឹងប្រែងឱ្យបានហ្មត់ចត់ក្នុងកម្រិតជាទីពេញចិត្ត ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សឡើយ។ ប្រទេសកម្ពុជាស្ថិតនៅក្នុងចំណាត់ថ្នាក់ទី 2 និងទី 3 ក្នុងរយៈពេល 7 ឆ្នាំចុងក្រោយនេះ (ចំណាត់ថ្នាក់ទី 1 ត្រូវបានចាត់ទុកថាល្អជាងគេ ហើយចំណាត់ថ្នាក់ទី 3 គឺអាក្រក់ជាងគេ)។

# កុមាររងផលប៉ះពាល់ដោយសារមេរោគអេដស៍/ជម្ងឺអេដស៍





បើតាមការប៉ាន់ប្រមាណ ដែលធ្វើឡើងដោយកម្មវិធីអេដស៍របស់សហប្រជាជាតិ (UNAIDS) កាលពីឆ្នាំ 2015 មានកុមារអាយុ 0 ទៅ 14 ឆ្នាំ ចំនួន 4061 នាក់កំពុងរស់នៅជាមួយមេរោគអេដស៍នៅកម្ពុជា។ បច្ចុប្បន្ននេះ ពុំមានតួលេខប៉ាន់ប្រមាណអំពីចំនួនកុមារដែលរងផលប៉ះពាល់ដោយសារមេរោគអេដស៍ឡើយ។ ក្រុមការងារជាតិពហុវិស័យឆ្លើយតបចំពោះកុមារកំព្រា និងកុមារងាយរងគ្រោះ បានឱ្យនិយមន័យកុមារដែលរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ថាជាកុមារអាយុក្រោម 18 ឆ្នាំ ដែលកំពុងរស់នៅជាមួយមេរោគអេដស៍ បន្ថែមពីលើកុមារដែលសមាជិកគ្រួសារបានរងផលប៉ះពាល់ដោយសារមេរោគអេដស៍/ជម្ងឺអេដស៍ រាប់បញ្ចូលទាំងការបាត់បង់ជីវិតដោយសារជម្ងឺនេះផងដែរ។

ប្រេវ៉ាឡង់នៃមេរោគអេដស៍ ក្នុងចំណោមប្រជាជនទូទៅ (អាយុពី 15 ដល់ 49 ឆ្នាំ) បានថយបន្តិចម្តងៗនៅក្នុងទសវត្សរ៍ចុងក្រោយនេះពី 2 ភាគរយក្នុងឆ្នាំ 1998 មកនៅត្រឹម 0.7 ភាគរយក្នុងឆ្នាំ 2013[31] និង 0.6 ភាគរយក្នុងឆ្នាំ 2014[32] អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍បានប៉ាន់ប្រមាណថា នៅក្នុងឆ្នាំ 2014 នៅកម្ពុជាមានអ្នករស់នៅជាមួយមេរោគអេដស៍ប្រមាណជា 75000 នាក់។ ប្រទេសនេះមានគោលបំណងបញ្ចប់ការឆ្លងរាលដាលមេរោគអេដស៍ ក្នុងឆ្នាំ 2020។[33]

# ពលកម្មកុមារ និងកុមារធ្វើការខារ



ពាក្យថា "ពលកម្មកុមារ" ជារឿយៗ ត្រូវបានគេឱ្យនិយមន័យបែបទូលាយ សំដៅលើការងារទាំងឡាយណាដែលធ្វើឱ្យកុមារមិនអាចទទួលបានកុមារភាព សក្តានុពល និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ហើយដែលបង្កគ្រោះថ្នាក់ដល់ការអភិវឌ្ឍរបស់ពួកគេ។ មិនមែនរាល់ការងារទាំងអស់ដែលធ្វើឡើងដោយកុមារ សុទ្ធតែត្រូវបានដាក់ចំណាត់ថ្នាក់ថាជាពលកម្មកុមារនោះទេ។ កុមារដែលចូលរួមក្នុងពលកម្មកុមារ គឺជាក្រុមមួយក្នុងចំណោមក្រុមកុមារដែលកំពុងធ្វើការងារ។ ថាតើការងារក្នុងទម្រង់មួយត្រូវបានចាត់ទុកថាជា "ពលកម្មកុមារ" ដែរឬអត់ គឺអាស្រ័យទៅតាមអាយុរបស់កុមារ ប្រភេទ និងចំនួនម៉ោងធ្វើការ លក្ខខណ្ឌការងារ និងការកំណត់ក្នុងច្បាប់ជាតិ។ ដូច្នេះ និយមន័យពលកម្មកុមារ មានការប្រែប្រួលពីប្រទេសមួយទៅប្រទេសមួយទៀត និងពីវិស័យមួយទៅវិស័យមួយទៀតក្នុងប្រទេសតែមួយ។

នៅកម្ពុជា ច្បាប់ស្តីពីការងារ (ឆ្នាំ 1997) អនុញ្ញាតឱ្យកុមារអាយុត្រឹម 12 ឆ្នាំ អាចធ្វើការងារស្រាល និងគ្មានគ្រោះថ្នាក់ ដែលមិនរំខានដល់ការសិក្សារបស់ពួកគេ។ នីតិភាពអប្បបរមាសម្រាប់ការងារទូទៅនៅក្នុងប្រទេសនេះគឺ 15 ឆ្នាំ និង 18 ឆ្នាំសម្រាប់ការងារដែលមានគ្រោះថ្នាក់ (ដូចដែលចែងក្នុងច្បាប់នេះ)។ ពលកម្មកុមារអាចមានទម្រង់ច្រើនបែបច្រើនយ៉ាងខុសៗគ្នា។ ប៉ុន្តែ អាទិភាពសំខាន់គឺត្រូវលុបបំបាត់ចោលដោយមិនបង្អង់យូរ នូវទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដូចដែលចែងក្នុងមាត្រា 3 នៃអនុសញ្ញាលេខ 18 របស់អង្គការពលកម្មអន្តរជាតិ៖ ដែលសំដៅលើការងារទាំងឡាយណា ដែលបង្កមហន្តរាយដល់សុខមាលភាពផ្លូវកាយ ផ្លូវចិត្ត ឬសតិអារម្មណ៍របស់កុមារ ដោយសារតែលក្ខណៈរបស់ការងារនោះ ឬដោយសារតែលក្ខខណ្ឌនៃការធ្វើការងារនោះ (ដែលហៅម៉្យាងទៀតថា "ការងារគ្រោះថ្នាក់")។[34]

ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ពុំបានប្រមូលទិន្នន័យអំពីពលកម្មកុមារឡើយ។ ផ្នែកនេះប្រើប្រាស់ទិន្នន័យដែលបានពីការអង្កេតសង្គមសេដ្ឋកិច្ចឆ្នាំ 2014 និងការអង្កេតដោយធ្វើឡើងដោយអង្គការពលកម្មអន្តរជាតិ និងវិទ្យាស្ថានជាតិស្ថិតិឆ្នាំ 2012។

**រូបភាព 7.1 ភាគរយកុមារធ្វើការងារ ក្នុងចំណោមប្រជាជនជាកុមារ អាយុពី 5 ទៅ 17 ឆ្នាំ**




ប្រភព៖ ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា (CSES), 2014

ក្នុងចំណោមកុមារអាយុចន្លោះពី 5 ដល់ 17 ឆ្នាំ ជិត 4 លាននាក់នៅកម្ពុជា 19 ភាគរយ មានសកម្មភាពសេដ្ឋកិច្ចកាលពីឆ្នាំ 2014។[35] ពុំមានភាពខុសប្លែកគ្នាគួរឱ្យកត់សម្គាល់រវាងចំនួនក្មេងស្រី (19 ភាគរយ) និងក្មេងប្រុស (20 ភាគរយ) ដែលធ្វើសកម្មភាពសេដ្ឋកិច្ចនោះឡើយ។ ភាគរយនៃកុមារដែលធ្វើការងារ ថយចុះពីឆ្នាំ 2012 ដល់ 2013 ពុំមានការប្រែប្រួលគួរឱ្យកត់សម្គាល់ឡើយ ចាប់តាំងពីពេលនោះមក[36] (រូបភាព 7.1)។

របាយការណ៍ឆ្នាំ 2012 របស់អង្គការពលកម្មអន្តរជាតិ និងវិទ្យាស្ថានជាតិស្ថិតិ បានផ្តល់ព័ត៌មានជាក់លាក់បន្ថែមទៀតអំពីប្រភេទ និងលក្ខខណ្ឌនៃពលកម្មកុមារនៅកម្ពុជា។[37] ក្នុងឆ្នាំ 2012 កុមារអាយុ 5 ទៅ 17 ឆ្នាំ ភាគច្រើន 81 ភាគរយ មិនកំពុងធ្វើការងារ ឬស្វែងរកការងារធ្វើឡើយ ខណៈពេលដែលកុមារ 19 ភាគរយកំពុងធ្វើការងារ ឬមានសកម្មភាពសេដ្ឋកិច្ច (រូបភាព 7.2)។ ទិន្នន័យទាំងនេះ គឺស្រដៀងគ្នាជាមួយនឹងទិន្នន័យ ដែលត្រូវបានរាយការណ៍ ក្នុងការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជាផងដែរ។ ប៉ុន្តែបើតាមរបាយការណ៍របស់អង្គការពលកម្មអន្តរជាតិ/វិទ្យាស្ថានជាតិស្ថិតិ ក្នុងចំណោមកុមារអាយុ 5 ដល់ 17 ឆ្នាំ នៅកម្ពុជា មាន 11 ភាគរយ កំពុងចូលក្នុងពលកម្មកុមារ (6 ភាគរយក្នុងការងារដែលមានគ្រោះថ្នាក់ និង 5 ភាគរយក្នុងទម្រង់ផ្សេងទៀតនៃពលកម្មកុមារ) ខណៈពេលដែល 8 ភាគរយទៀត កំពុងធ្វើការងារដែរ តែពុំត្រូវបានចាត់ទុកថាជាពលករកុមារឡើយ។ ក្នុងចំណោមកុមារដែលកំពុងធ្វើការងារសរុប 57 ភាគរយ កំពុងប្រឡូកក្នុងពលកម្មកុមារ ខណៈពេលដែល 43 ភាគរយទៀត កំពុងធ្វើការងារដែរ តែពុំត្រូវបានចាត់ទុកថាជាពលករកុមារ (រូបភាព 7.3)។ ក្នុងចំណោមពលករកុមារទាំងអស់ 57 ភាគរយ ប្រឈមនឹងលក្ខខណ្ឌការងារដែលមានគ្រោះថ្នាក់ និង 95 ភាគរយ កំពុងធ្វើការងារក្នុងទម្រង់ផ្សេងទៀតនៃពលកម្មកុមារ។

**រូបភាព 7.2 របាយភាគរយនៃកុមារអាយុពី 5 ទៅ 17 ឆ្នាំទាំងអស់ បែងចែកទៅតាមស្ថានភាពការងារ**




International Labour Organization and National Institute of Statistics (ILO/NIS), 2012.

**រូបភាព 7.3 របាយភាគរយនៃកុមារធ្វើការងារ និងពលកម្មកុមារអាយុ 5 ដល់ 17 ឆ្នាំ**




ប្រភព៖ IILO/NIS, 2012

របាយការណ៍របស់អង្គការពលកម្មអន្តរជាតិ/វិទ្យាស្ថានជាតិស្ថិតិ ក៏បានផ្តល់នូវទិន្នន័យបែងចែកទៅតាមប្រភេទផងដែរ។ របាយការណ៍នេះបានបង្ហាញថាការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច និងពលកម្មកុមារមានកម្រិតទាប ក្នុងចំណោមកុមារដែលរស់នៅតាមទីប្រជុំជន បើធៀបនឹងកុមារដែលរស់នៅតាមទីជនបទ ប៉ុន្តែពុំមានភាពខុសប្លែកគ្នាបែងចែកតាមភេទនោះឡើយ (រូបភាព 7.4)។ ខេត្តកំពង់ចាម និងខេត្តបាត់ដំបង គឺជាខេត្តដែលមានកុមារធ្វើការងារ និងពលករកុមារច្រើនជាងគេ ហើយខេត្តកែបគឺជាខេត្តដែលមានចំនួនតិចជាងគេ។ ក្នុងចំណោមកុមារដែលកំពុងមានសកម្មភាពសេដ្ឋកិច្ច មានតិចជាង 1 ភាគរយ ដែលធ្វើការងារតាមផ្ទះ[38] នៅក្នុងនោះ 88 ភាគរយជាក្មេងស្រី។

ក្នុងចំណោមពលករកុមារអាយុ 5 ដល់ 17 ឆ្នាំទាំងអស់ មានប្រមាណជាពាក់កណ្តាល (ស្មើនឹង 49 ភាគរយ) គឺជាអ្នកធ្វើការងារឱ្យគ្រួសារដែលពុំបានទទួលបានប្រាក់កម្រៃ ខណៈពេលដែលពលករកុមារក្នុងភាគរយមួយខ្ពស់បំផុត ធ្វើការងារជាង 48 ម៉ោងក្នុងមួយសប្តាហ៍។ សូមមើលរូបភាព 7.5 (ក) ដល់ 7.5 (ឃ) សម្រាប់ទិន្នន័យបន្ថែមទៀតអំពីរូបភាពផ្សេងទៀតនៃពលកម្មកុមារ។

របាយការណ៍របស់អង្គការពលកម្មអន្តរជាតិ/វិទ្យាស្ថានស្ថិតិ ក៏បានរកឃើញផងដែរថា ក្នុងចំណោមកុមារអាយុ 5 ទៅ 17 ឆ្នាំសរុប (ស្មើនឹង 129106 នាក់) គឺជាកុមារចំណាកស្រុក។ ជាង 1 ភាគ 3 (38 ភាគរយ) នៃកុមារកំពុងធ្វើការងារទាំងអស់ គឺជាអ្នកធ្វើចំណាកស្រុក។

**រូបភាព 7.4 ភាគរយនៃកុមារកំពុងធ្វើការងារ និងពលករកុមារអាយុ 5 ទៅ 17 ឆ្នាំ បែងចែកតាមភេទ និងទីលំនៅ**




ប្រភព៖ ILO/NIS, 2012

**រូបភាព 7.5 (ក) របាយគិតជាភាគរយនៃពលករកុមារបែងចែកតាមក្រុមអាយុ**




ប្រភព៖ ILO/NIS, 2012

**រូបភាព 7.5 (ខ) របាយគិតជាភាគរយនៃពលករកុមារបែងចែកតាមស្ថានភាពការងារ**




ប្រភព៖ ILO/NIS, 2012

### រូបភាព 7.5 (គ) របាយគិតជាភាគរយនៃពលករកុមារបែងចែកទៅតាមវិស័យការងារ




ប្រភព៖ ILO/NIS, 2012

### រូបភាព 7.5 (ឃ) របាយគិតជាភាគរយនៃពលករកុមារបែងចែកទៅតាមចំនួនម៉ោងធ្វើការក្នុងមួយសប្តាហ៍




ប្រភព៖ ILO/NIS, 2012

ភាគរយកុមារនៅក្រៅសាលា គឺខ្ពស់បំផុតក្នុងចំណោមកុមារដែលធ្វើការងារដែលមានគ្រោះថ្នាក់ (តារាង 7.1)។

ក្នុងចំណោមកុមារអាយុ 6 ដល់ 17 ឆ្នាំ ដែលកំពុងនៅក្រៅសាលា 37 ភាគរយបានលើកឡើងពីមូលហេតុពាក់ព័ន្ធនឹងពលកម្មកុមារ (ដូចជា ភាពចាំបាច់ក្នុងការជួយរកចំណូលសម្រាប់គ្រួសារ ឬធ្វើកិច្ចការផ្ទះ) ថាជាមូលហេតុដែលធ្វើឱ្យពួកគេពុំបានទៅរៀន។ តួលេខនេះមានការកើនឡើងចាប់តាំងពីឆ្នាំ 2009 មក។[39]

### តារាង 7.1 របាយគិតជាភាគរយនៃកុមារកំពុងធ្វើការងារ ពលករកុមារ និងកុមារធ្វើការងារដែលមានគ្រោះថ្នាក់ អាយុ 5 ដល់ 17 ឆ្នាំ បែងចែកទៅតាមការចូលរៀនក្នុងសាលា

| | កុមារកំពុងធ្វើការងារ | ពលករកុមារ | កុមារដែលធ្វើការងារប្រកបដោយគ្រោះថ្នាក់ |
|---|---|---|---|
| កំពុងរៀននៅសាលា | 50% | 45% | 12% |
| បោះបង់ចោលការសិក្សា/លែងរៀនទៀត | 44% | 48% | 80% |
| មិនដែលទៅរៀន | 6% | 7% | 9% |
| សរុប | 100% | 100% | 100% |

សម្គាល់៖ តួលេខក្នុងតារាងនេះ ត្រូវបានកាត់ខ្ទង់ឱ្យគត់ និងបូកបញ្ចូលគ្នាអាចលើសពី 100 ភាគរយ

ប្រភព៖ ILO/NIS, 2012

# កុមារដែលរស់នៅ ឬធ្វើការងារតាមផ្លូវ



ផ្អែកទៅតាមការអង្កេតឆ្នាំ 2006 - 2007 ដែលធ្វើឡើងដោយអង្គការមិនមែនរដ្ឋាភិបាលមួយឈ្មោះ មិត្តសម្លាញ់ ក្រុមការងារកុមារកំព្រា និងកុមារងាយរងគ្រោះ បានប៉ាន់ប្រមាណថា ក្នុងឆ្នាំ 2007 មានកុមារចំនួន 24700 នាក់ កំពុងរស់នៅ ឬធ្វើការតាមចិញ្ចើមផ្លូវនៅកម្ពុជា ដែលភាគច្រើននៅតំបន់ប្រជុំជន។ ទីក្រុងដែលរងផលប៉ះពាល់ជាងគេរួមមាន ទីក្រុងភ្នំពេញ (ដែលមានក្មេង "អនាថា" ចំនួន 17000 នាក់) ខេត្តសៀមរាប (1500 នាក់) ប៉ៃលិន (1200) បន្ទាយមានជ័យ (1300 នាក់) និងព្រះសីហនុ (3700 នាក់)។

ការពុំមានការអង្កេតល្អិតល្អន់ថ្មីៗ អំពីកុមារទាំងនេះ ធ្វើឱ្យគេមានការពិបាកក្នុងការប៉ាន់ប្រមាណចំនួនកុមារទាំងនេះ។ តួលេខប៉ាន់ប្រមាណដែលមានអំពីក្រុមកុមារទាំងនេះ ក៏បញ្ចូលប្រភេទកុមារផ្សេងទៀត (ដូចជា កុមារដែលរស់នៅក្នុងលំនៅដ្ឋានក្រោមស្តង់ដា ឬកុមារបាត់បង់ឱកាស) ឬយុវជនដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅផងដែរ។ ឧទាហរណ៍ក្នុងឆ្នាំ 2011 ការអង្កេតវាយតម្លៃបែបរហ័ស ដែលធ្វើឡើងដោយតំណាងកុមារអនាថានៅកម្ពុជា ក្នុងទីក្រុងចំនួន 6 រាប់ឃើញមនុស្សអាយុក្រោម 24 ឆ្នាំ 4829 នាក់ ដែលភ្នាក់ងារសង្គមកិច្ចបានជួបនៅតាមផ្លូវក្នុងរយៈពេល 24 ម៉ោង (ត្រូវបានកំណត់ថាជារយៈពេលនៃការធ្វើអង្កេតនេះ)។ ការបំបែកតួលេខនេះទៅតាមទីក្រុង បង្ហាញដូចតទៅ 2184 នាក់ក្នុងទីក្រុងភ្នំពេញ 1318 នាក់ក្នុងខេត្តសៀមរាប 755 នាក់ក្នុងខេត្តព្រះសីហនុ 228 នាក់ក្នុងក្រុងប៉ោយប៉ែត 174 នាក់នៅអ្នកលឿង និង 170 នាក់ក្នុងខេត្តបាត់ដំបង។ ការអង្កេតនេះបានពង្រីកនិយមន័យកុមារអនាថាចំនួន 3 ដង ដូចដែលលើកមកពិភាក្សានៅផ្នែកដំបូងនៃផ្នែកនេះ ពោលគឺបានបញ្ចូលប្រភេទ "ដទៃទៀត" (កុមារគ្មានផ្ទះសម្បែង កុមារក្រីក្រ កុមារបាត់បង់ឱកាស និងផ្សេងទៀត) និងយុវជន (អាយុចាប់ពី 18 ឆ្នាំឡើងទៅ)។

ការសិក្សាឆ្នាំ 2015 ដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ និងសកលវិទ្យាល័យកូឡុំបៀ សហរដ្ឋអាមេរិក បានរកឃើញក្មេងប្រុសក្មេងស្រីអាយុក្រោម 18 ឆ្នាំដែលគ្មានផ្ទះសម្បែងត្រឹមត្រូវយ៉ាងហោចណាស់ 3545 ក្នុងខេត្តចំនួន 7 ទូទាំងប្រទេសកម្ពុជា ដែលគេចុះប្រមូលទិន្នន័យទាំងនេះ។[40] តួលេខប៉ាន់ប្រមាណនេះគ្របដណ្តប់ទៅលើតំបន់សំខាន់ៗទាំងអស់នៅកម្ពុជា ដែលគេដឹងថាមានកុមារអនាថាកំពុងរស់នៅ។ កុមារត្រូវបានចាត់ចំណាត់ថ្នាក់ថាជាកុមារគ្មានផ្ទះសម្បែង ប្រសិនបើពួកគេមានអាយុក្រោម 18 ឆ្នាំ ហើយដែលជានិច្ចជាកាល ឬម្តងម្កាលរស់នៅតាមចិញ្ចើមផ្លូវ ក្នុងជំរកសុវត្ថិភាពបណ្តោះអាសន្ន តាមទីសាធារណៈ ឬក្នុងលំនៅដ្ឋានដែលពុំមានសុវត្ថិភាព ឬមិនត្រឹមត្រូវ។ ទិន្នន័យនេះត្រូវបានប្រមូលក្នុងស្រុកប្រជុំជនចំនួន 15 ក្នុងខេត្តចំនួន 7 (បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម ភ្នំពេញ ព្រះសីហនុ ព្រៃវែង សៀមរាប)។ ខណៈដែលនេះគឺជាការអង្កេតលើកទីមួយបែបនេះនៅកម្ពុជា ការអង្កេតនេះពុំបានផ្តល់នូវតួលេខវាស់វែងដែលអាចជឿទុកចិត្តបានអំពីកុមារដែលរស់នៅ ឬធ្វើការងារតាមចិញ្ចើមផ្លូវឡើយ ដោយសារតែនិយមន័យដែលប្រើប្រាស់បូកបញ្ចូលកុមារគ្មានផ្ទះសម្បែងផង និងកុមាររស់នៅតាមផ្លូវផងក្រោមប្រភេទតែមួយ ដោយពុំមានការរាប់ចំនួនប្រភេទណាមួយក្នុងចំណោមប្រភេទទាំង 2 នេះឱ្យបានពេញលេញ។ ជាពិសេសការបញ្ចូលលំនៅដ្ឋានក្រោមស្តង់ដាជាលក្ខណៈវិនិច្ឆ័យសម្រាប់ការរាប់ចំនួននេះ មានលក្ខណៈទូលាយពេក ហើយអាចធ្វើឱ្យចំនួនមានការកើនឡើងខ្ពស់ប្រសិនបើលក្ខណៈវិនិច្ឆ័យនេះត្រូវបានយកទៅប្រើប្រាស់សម្រាប់ការរាប់ចំនួនទូទាំងប្រទេសកម្ពុជា ពោលគឺប្រសិនបើមិនមែនរាប់តែក្នុងទីក្រុងមួយចំនួនតូចបែបនេះ។

កុមារដែលរស់នៅ ឬធ្វើការងារតាមចិញ្ចើមផ្លូវ ត្រូវបានឱ្យនិយមន័យក្រោមប្រភេទចំនួន 3៖ ទី 1 "កុមារដែលរស់នៅតាមផ្លូវ" (កុមារដែលលែងមានទំនាក់ទំនងជាមួយគ្រួសារ ឬរស់នៅតែឯងតាមផ្លូវ), "កុមារធ្វើការងារតាមផ្លូវ" (កុមារដែលចំណាយពេលទាំងអស់ ឬពេលភាគច្រើនរបស់ខ្លួនធ្វើការងារតាមផ្លូវ ដើម្បីរកចំណូលឱ្យគ្រួសាររបស់ពួកគេ និង/ឬឱ្យខ្លួន ប៉ុន្តែត្រឡប់ទៅនៅផ្ទះរបស់អ្នកផ្តល់ការថែទាំរបស់ពួកគេវិញនៅពេលយប់), និង "កុមារដែលជាកូនរបស់គ្រួសាររស់នៅតាមផ្លូវ" (កុមារដែលរស់នៅជាមួយគ្រួសារតាមផ្លូវ)។ ក្រុមការងារកុមារកំព្រា និងងាយរងគ្រោះរបស់កម្ពុជាប្រើប្រាស់និយមន័យស្រដៀងគ្នានេះដែរ។ ពោលគឺកុមារដែលរស់នៅម្ចាស់ការខ្លួនឯងនៅតាមផ្លូវ កុមារដែលធ្វើការងារតាមផ្លូវ ប៉ុន្តែត្រឡប់មកផ្ទះវិញបើទោះជាមិនទៀងទាត់ក៏ដោយ និងកុមារដែលរស់នៅជាមួយគ្រួសារនៅតាមផ្លូវ។

# កុមាររស់នៅក្នុងភាពក្រីក្រ



ផ្អែកទៅលើទិន្នន័យជាតិ អត្រានៃភាពក្រីក្រនៅកម្ពុជាថយចុះយ៉ាងគំហុកពី 38 ភាគរយ ក្នុងឆ្នាំ 2007 មកនៅ 19 ភាគរយ ក្នុងឆ្នាំ 2012។[41] ប៉ុន្តែបើប្រើប្រាស់បន្ទាត់នៃភាពក្រីក្រអន្តរជាតិវិញ លទ្ធផលគឺនៅមានភាពមិនច្បាស់លាស់។ របាយការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងឆ្នាំ 2011 បង្ហាញថា មានប្រជាជនកម្ពុជា 10 ភាគរយ រស់នៅជាមួយនឹងចំណូលតិចជាង 1,25 ដុល្លាក្នុងមួយថ្ងៃ ដែលភាគរយនេះថយចុះពី 31 ភាគរយ កាលពីឆ្នាំ 2007។ ប៉ុន្តែក្នុងឆ្នាំ 2011 មានប្រជាជនប្រមាណជា 31 ភាគរយ (ប្រមាណជា 4 លាននាក់) ឋិតនៅចន្លោះបន្ទាត់នៃភាពក្រីក្ររវាង 1,25 ដុល្លា និង 2 ដុល្លាក្នុងមួយថ្ងៃ តួលេខនេះបង្ហាញពីកំណើននៃភាពក្រីក្របើធៀបនឹង 29 ភាគរយក្នុងឆ្នាំ 2007។[42] នេះបង្ហាញថាប្រជាជនកម្ពុជាជាច្រើននាក់ ស្ថិតនៅក្នុងស្ថានភាព "ជិតក្រ" ឬងាយធ្លាក់ចូលទៅក្នុងភាពក្រីក្រ។ អត្រាភាពក្រីក្រ 2 ដុល្លាក្នុងមួយថ្ងៃ ពុំមានការប្រែប្រួលគួរឱ្យកត់សម្គាល់ឡើយ ចន្លោះពីឆ្នាំ 2009 ដល់ 2011។

ក្នុងឆ្នាំ 2014 ធនាគារអភិវឌ្ឍន៍អាស៊ី ក៏បានរាយការណ៍ផងដែរថា ចំនួនប្រជាពលរដ្ឋក្រីក្ររស់នៅប្រមូលផ្តុំក្នុងចំនួនច្រើនលើសលុប នៅតាមតំបន់ជនបទនៅកម្ពុជា ពោលគឺក្នុងឆ្នាំ 2011 មានគ្រួសារក្រីក្រ 91 ភាគរយ រស់នៅតាមតំបន់ជនបទ។ គ្រួសារក្រីក្រមានសមាជិកកាន់តែច្រើន ពោលគឺមធ្យម 5.6 នាក់ បើធៀបនឹងចំនួនសមាជិកជាមធ្យមនៅថ្នាក់ជាតិ 4.5 នាក់។ ស្រដៀងគ្នានេះដែរ គ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងមានកូនលើសពី 2 នាក់ និងគ្មានបុរសពេញវ័យនៅជាមួយ ច្រើនតែជាគ្រួសារក្រីក្រ ហើយមានកូនស្រីទំនងជាកំពុងធ្វើការងារ។[43]

កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់រដ្ឋាភិបាលកម្ពុជា ធ្វើការប្រមូលទិន្នន័យអំពីគ្រួសារក្រីក្រ។[44] កម្មវិធីនេះបានប៉ាន់ប្រមាណថា មានប្រជាពលរដ្ឋប្រមាណ2.4លាននាក់ ត្រូវជា 575,000 គ្រួសារ ត្រូវបានដាក់ចំណាត់ថ្នាក់ថាក្រ 1 ("ក្រខ្សត់ខ្លាំង") ឬក្រ 2 ("ក្រីក្រ") ពោលគឺស្មើនឹង 19 ភាគរយនៃចំនួនប្រជាជនសរុប ដែលរស់នៅតំបន់ជនបទនៅកម្ពុជា (ប្រភព៖ ជុំ8ដល់ជុំ10 2014-2016)។ លទ្ធផលរកឃើញកាន់តែជាក់លាក់ជាងនេះទៅទៀត គឺមានកុមារកម្ពុជា 896,877 នាក់ កំពុងរស់នៅក្នុងគ្រួសារក្រីក្រ (ប្រភព៖ ជុំ7ដល់ជុំ9 2013-2015)។ ដូចបានបង្ហាញក្នុងរូបភាព ខេត្តប៉ៃលិន គឺជាខេត្តដែលមានប្រជាពលរដ្ឋក្រីក្រ ក្នុងភាគរយខ្ពស់ជាងគេ បន្ទាប់មកគឺខេត្តកោះកុង ខណៈពេលដែលរាជធានីភ្នំពេញមានភាគរយប្រជាជនក្រីក្រទាបជាងគេ (ប្រភព៖ ជុំ8ដល់ជុំ10 2014-2016)។

**រូបភាព 8.1 ភាគរយប្រជាជនដែលមានជីវភាព "ក្រីក្រខ្លាំង" ឬ "ក្រីក្រ" (ក្រ 1 ឬ ក្រ 2) បែងចែកតាមខេត្ត**




ប្រភព៖ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៃក្រសួងផែនការ ជុំ8ដល់ជុំ10 ឆ្នាំ2014 ដល់ 2016

# កុមារពិការ និងកុមារដែលរងគ្រោះដោយសារសំណល់សង្គ្រាម



ភស្តុតាងជាច្រើនបានបញ្ជាក់ថា កុមារពិការ ប្រឈមមុខខ្ពស់ទៅនឹងអំពើហិង្សា និងការរំលោភបំពានគ្រប់រូបភាព បើធៀបនឹងកុមារដែលមិនពិការ។[45] តាមពិត ការស្រាវជ្រាវបង្ហាញថាកុមារពិការ ងាយនឹងទទួលរងអំពើហិង្សា ការរំលោភបំពាន និងការទុកចោលមិនអើពើ 3 ទៅ 4.6 ដង បើធៀបនឹងកុមារមិនពិការ។[46]

ទិន្នន័យពិការភាពកន្លងមក ច្រើនតែឆ្លុះបញ្ចាំងតែពីអ្នកដែលមានកម្សោយកាយសម្បទាតែប៉ុណ្ណោះ។ វិធីសាស្ត្រដែលយូនីសេហ្វប្រើប្រាស់ ដើម្បីកំណត់ពីពិការភាព គឺស្របគ្នាជាមួយនឹងទស្សនទានទូទៅ ស្ដីពីពិការភាព ដែលគាំទ្រដោយអនុសញ្ញាសហប្រជាជាតិស្ដីពីសិទ្ធិជនពិការ។ ក្រោមក្របខ័ណ្ឌនេះ មានការផ្ដោតការយកចិត្តទុកដាក់លើទំនាក់ទំនងរវាងបុគ្គល និងមជ្ឈដ្ឋានជុំវិញ ដែលអាចជាឧបសគ្គ ឬផ្ដល់ការគាំទ្រដល់ការរស់នៅប្រចាំថ្ងៃ និងការចូលរួមក្នុងសង្គមរបស់ពួកគេ។ សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ https://data.unicef.org/topic/child-disability/overview/

ក្នុងចំណោមប្រជាជនអាយុ 5 ទៅ 14 ឆ្នាំ មាន 2 ភាគរយ ត្រូវបានគេរាយការណ៍ថា ជួបនឹងការលំបាកខ្លះ ការលំបាកច្រើន ឬមិនអាចបំពេញមុខងារអ្វីមួយ ក្នុងចំណោមយ៉ាងហោចណាស់មុខងារមួយដូចតទៅ៖ មើលឃើញ ស្ដាប់ឮ ដើរ ផ្ចង់អារម្មណ៍ ថែទាំខ្លួនឯង ឬប្រាស្រ័យទាក់ទង។ ពិការភាពទាំងនេះត្រូវបានរកឃើញថា មានការកើនឡើងទៅតាមអាយុ និងថយចុះទៅតាមកម្រិតនៃការអប់រំ ប៉ុន្តែគេពុំបានរកឃើញភាពខុសប្លែកគ្នាគួរឱ្យកត់សម្គាល់ទៅតាមភេទ ទីកន្លែងរស់នៅ និងស្ថានភាពទ្រព្យសម្បត្តិនោះឡើយ។ កម្រិតនៃការលំបាក ក្នុងការបំពេញមុខងារក្នុងចំណោមកុមារអាយុចាប់ពី 5 ឆ្នាំឡើងទៅ ត្រូវបានរកឃើញថាមានការប្រែប្រួលខុសៗគ្នាគួរឱ្យកត់សម្គាល់ពីខេត្តមួយទៅខេត្តមួយទៀត ពោលគឺពី 2 ភាគរយ ក្នុងខេត្តមណ្ឌលគិរី/រតនគិរី រហូតដល់ 20 ភាគរយក្នុងខេត្តបាត់ដំបង់/ប៉ៃលិន។ ប៉ុន្តែគួរកត់សម្គាល់ថា តួលេខទាំងនេះទំនងជាតួលេខប៉ាន់ប្រមាណមិនដល់កម្រិតជាក់ស្ដែង នៃប្រេវ៉ាឡង់ពិតប្រាកដនៃកុមារពិការនៅកម្ពុជាឡើយ ដោយសារតែសំណួរដែលប្រើប្រាស់ក្នុងការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ដើម្បីវាស់វែងពិការភាពនេះ ជាសំណួរដែលគេមិនគួរយកទៅប្រើប្រាស់ជាមួយកុមារ (សំណួរទាំងនេះត្រូវបានរៀបចំឡើង ដើម្បីវាយតម្លៃពិការភាពក្នុងចំណោមប្រជាជនពេញវ័យ)។

ប្រទេសកម្ពុជា គឺជាប្រទេសដែលសំបូរគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ជាកេរ្ដិ៍មរតកបន្សល់ពីសង្គ្រាម ដែលបន្តធ្វើឱ្យកុមារ និងមនុស្សពេញវ័យរងរបួស និងបាត់បង់ជីវិត។ ចំនួនគ្រោះថ្នាក់ដោយសារគ្រាប់មីន មានការថយចុះ ពោលគឺក្នុងឆ្នាំ 2016 មានគ្រោះថ្នាក់ 83 ករណី បើធៀបនឹង 4,320 ករណីក្នុងឆ្នាំ 1996។[47] "អ្នកទទួលរងគ្រោះថ្នាក់" សំដៅលើអ្នកដែលរងរបួស ឬបាត់បង់ជីវិត។ និន្នាការនៃគ្រោះថ្នាក់ដោយសារគ្រាប់មីន ក្នុងចំណោមកុមារ ក៏មានការថយចុះផងដែរ (រូបភាព 9.1)។ ក្នុងឆ្នាំ 2016 សរុបមានចំនួនប្រមាណជា 20 នាក់ (ស្រី 25 ភាគរយ) ទទួលរងគ្រោះថ្នាក់ដោយសារគ្រឿងផ្ទុះ ដែលជាសំណល់សង្គ្រាម ឬគ្រាប់មីន ពោលគឺស្មើនឹង 21 ភាគរយនៃចំនួនអ្នករងគ្រោះថ្នាក់សរុបដោយសារគ្រាប់មីន/សំណល់សង្គ្រាមនៅឆ្នាំនោះ។ ចាប់តាំងពីឆ្នាំ 2012 មក ភាគរយនៃកុមារ ដែលរងគ្រោះថ្នាក់ដោយសារសំណល់សង្គ្រាម មានកម្រិតខ្ពស់ជាងកុមារ ដែលរងគ្រោះដោយសារគ្រាប់មីនក្នុងចំណោមចំនួនជនរងគ្រោះសរុប។ ចន្លោះពីឆ្នាំ 2012 ដល់ឆ្នាំ 2015 ហានិភ័យនៃការរងរបួស គឺមានកម្រិតខ្ពស់ជាងហានិភ័យនៃការបាត់បង់ជីវិត៖ ក្នុងចំណោមកុមារ ដែលរងគ្រោះដោយសារគ្រាប់មីន និងសំណល់សង្គ្រាមក្នុងឆ្នាំ 2015 មាន 87 ភាគរយបានរងរបួស ហើយភាគរយដែលនៅសេសសល់គឺបាត់បង់ជីវិត។ ប៉ុន្តែក្នុងឆ្នាំ 2016 កុមារដែលរងគ្រោះដោយសារគ្រាប់មីន និងសំណល់សង្គ្រាម 55 ភាគរយបានបាត់បង់ជីវិត បើធៀបនឹងភាគរយដែលនៅសល់ ដែលត្រូវរងរបួស ឬដាច់អវយវៈ (រូបភាព 9.2)។

ក្នុងឆ្នាំ 2016 ក្នុងខេត្តក្រុងចំនួន 25 មាន 8 រងផលប៉ះពាល់ ដោយសារគ្រាប់មីន /ឬសំណល់សង្គ្រាម ដូចជាខេត្តបាត់ដំបង ប៉ៃលិន ឧត្ដរមានជ័យ ព្រះវិហារ កំពង់ធំ ក្រចេះ ព្រៃវែង និងត្បូងឃ្មុំជាដើម។

## រូបភាព 9.1 កុមាររងគ្រោះសរុបដោយសារសំណល់សង្គ្រាម និងគ្រាប់មីន




សម្គាល់៖ ក្នុងឆ្នាំ 2015 ពុំមានកុមារដែលរងគ្រោះដោយសារគ្រាប់មីនឡើយ

ប្រភព៖ អាជ្ញាធរមីនកម្ពុជា (CMAA), 2017



## រូបភាព 9.2 ចំនួនកុមាររងគ្រោះសរុប ដោយសារសំណល់សង្គ្រាម និងគ្រាប់មីន បែងចែកតាមភេទ និងប្រភេទនៃការរងរបួស




ប្រភព៖ អាជ្ញាធរមីនកម្ពុជា, 2017



# កុមារដែលមានទំនាស់ជាមួយច្បាប់

បើទោះបីជាក្រមព្រហ្មទណ្ឌឆ្នាំ 2009 ចាត់ទុកអាយុ 18 ឆ្នាំ ថាជានីតិភាពសម្រាប់ទទួលខុសត្រូវបទព្រហ្មទណ្ឌ នៅកម្ពុជាយ៉ាងណាក៏ដោយ ក៏តុលាការអាចប្រកាសផ្តន្ទាទោសបទល្មើសព្រហ្មទណ្ឌ ចំពោះអនីតិជនដែលមានអាយុតិចរហូតដល់ 14 ឆ្នាំ អាស្រ័យទៅតាមស្ថានទម្ងន់ទោស។[48] នៅកម្ពុជា ក្នុងចំណោមកុមារទាំងអស់ ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ មានរហូតដល់ពាក់កណ្តាលទទួលបានការកាត់ទោសដូចមនុស្សពេញវ័យ ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ កុមារមកពីគ្រួសារក្រីក្រ ប្រឈមមុខខ្ពស់នឹងការបំបិទសិទ្ធិសេរីភាពដែលខុសច្បាប់ ដោយសារតែពួកគេពុំមានលទ្ធភាពរកមេធាវីតំណាងផ្លូវច្បាប់ឱ្យពួកគេបាន។ របាយការណ៍នានាបង្ហាញថា កុមារប្រឈមនឹងអំពើហិង្សានៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការ នៅពេលដែលពួកគេមានទំនាស់ជាមួយច្បាប់ ចាប់ពីពេលចាប់ខ្លួនរហូតដល់ពេលឃុំខ្លួន និងបង្ហាញខ្លួននៅតុលាការ។[49]

បើតាមទិន្នន័យដែលផ្តល់ដោយក្រសួងមហាផ្ទៃ មានកុមារចំនួន 907 នាក់ កំពុងជាប់ឃុំឃាំងនាពេលបច្ចុប្បន្ននេះ។ ភាគច្រើនបំផុតនៃកុមារទាំងនេះអាចមានអាយុចន្លោះពី14ទៅ17ឆ្នាំ ព្រោះថាទំនួលខុសត្រូវព្រហ្មទណ្ឌចាប់ផ្តើមពេលកុមារមានអាយុចាប់ពី14ឆ្នាំ។ ប៉ុន្តែ តួលេខបែងចែកតាមអាយុបែបនេះមិនមានជាផ្លូវការសម្រាប់ធ្វើការបញ្ជាក់ឡើយ។។ ចន្លោះពីឆ្នាំ 2010 ដល់ 2014 ចំនួនអនីតិជនដែលត្រូវឃុំខ្លួនមានការថយចុះ 56 ភាគរយ បន្ទាប់មកមានការកើនឡើងមកវិញក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ (រូបភាព 10.1)។

ច្បាប់យុត្តិធម៌អនីតិជនថ្មី ដែលត្រូវបានអនុម័តក្នុងឆ្នាំ 2016 នឹងរួមចំណែកបង្កើតនូវយន្តការរាយការណ៍ ឆ្លើយតបចំពោះបណ្តឹង និងពិនិត្យតាមដានយ៉ាងមានប្រសិទ្ធភាព សម្រាប់ករណីកុមារដែលមានទំនាក់ទំនងជាមួយនឹងច្បាប់។

**រូបភាព** 10.1 **ចំនួនកុមារកំពុងជាប់ឃុំឃាំង**




ប្រភព៖ ក្រសួងមហាផ្ទៃឆ្នាំ 2017

# ប្រព័ន្ធការពារកុមារ



របាយការណ៍នេះបង្ហាញភស្តុតាងបញ្ជាក់ថា នៅកម្ពុជា មានកុមារក្នុងចំនួនមួយខ្ពស់គួរឱ្យព្រួយបារម្ភ ដែលរងផលប៉ះពាល់ដោយសារបញ្ហាជាច្រើន ដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ។ ការរំលោភបំពានទាំងនេះ មិនមែនជារឿងដែលថ្មីសម្រាប់សង្គមមនុស្សឡើយ អ្វីដែលសំខាន់ គឺការឆ្លើយតប។

នៅក្នុងបរិបទនេះ វាជាការសំខាន់ និងចាំបាច់ដែលគេត្រូវបង្កើតនូវប្រព័ន្ធការពារកុមារនៅថ្នាក់ជាតិ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយសម្រាប់ជូនដំណឹង និងឆ្លើយតបដោយប្រើប្រាស់វិធីសាស្ត្រ ដែលមានការសម្របសម្រួលប្រទាក់ក្រឡា និងក្នុងលក្ខណៈជាប្រព័ន្ធ ដើម្បីផ្តល់ការការពារដល់កុមារដែលងាយរងគ្រោះ។ កិច្ចការពារកុមារ ត្រូវបញ្ចូលយន្តការ និងរចនាសម្ព័ន្ធផ្លូវការផង និងមិនផ្លូវការផង ក្នុងគោលបំណងបង្កើនសុវត្ថិភាពដល់កុមារ។[50] ចំណុចចាប់ផ្តើមនៃប្រព័ន្ធទាំងនេះ គឺការផ្តល់ការការពារដល់កុមារនៅតាមសហគមន៍ និងការអនុវត្តដំណើរការ ផ្តល់ការថែទាំដល់កុមារ ដែលប្រឈមនឹងគ្រោះថ្នាក់ ឬដែលសហគមន៍របស់ពួកគេមិនសូវជាផ្តល់តម្លៃ។ ផ្នែកនេះប្រើប្រាស់សូចនាករផ្លូវការចំនួន 2 ពោលគឺថវិការបស់រដ្ឋាភិបាល និងចំនួនភ្នាក់ងារសង្គមកិច្ចរបស់រដ្ឋាភិបាល ដើម្បីបង្ហាញថា កម្ពុជាចាំបាច់ត្រូវពង្រឹងការឆ្លើយតបរបស់រដ្ឋាភិបាល ដើម្បីធានាយ៉ាងណាឱ្យប្រជាពលរដ្ឋវ័យក្មេងជាងគេរបស់ខ្លួន មានសុវត្ថិភាព និងទទួលបានការការពារ។ ការវិភាជន៍ថវិកា និងធនធានមនុស្សឱ្យបានគ្រប់គ្រាន់ ជាពិសេស ភ្នាក់ងារសង្គមកិច្ច គឺជាធាតុផ្សំសំខាន់ជាងគេ 2 នៃប្រព័ន្ធការពារកុមារ ដែលដំណើរការទៅមានប្រសិទ្ធភាព។

## ថវិកាសម្រាប់កិច្ចការពារកុមារ

រដ្ឋាភិបាលពុំបានបែងចែកថវិកា សម្រាប់ការងារការពារកុមារដោយឡែកដាច់ពីគេនោះឡើយ។ លើសពីនេះ ដោយសារតែសកម្មភាពការពារកុមារត្រូវបានធ្វើឡើងដោយក្រសួងផ្សេងៗគ្នា គេពិបាកនឹងដឹងពីចំនួនថវិកាសរុប ដែលត្រូវបានចំណាយណាស់។ ដូច្នេះ របាយការណ៍នេះប្រើប្រាស់ថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលជាសេនាធិការរបស់រដ្ឋាភិបាលទទួលបន្ទុកការការពារកុមារ ដើម្បីបង្ហាញពីភាគរយនៃថវិកាដែលចំណាយក្នុងវិស័យនេះ។

ភាគរយនៃថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងថវិកាជាតិ បានកើនឡើងពី 2 ភាគរយក្នុងឆ្នាំ 2009 ដល់ 4 ភាគរយ ក្នុងឆ្នាំ2016។ ថវិកាវិភាជន៍ជាក់ស្តែងកើនឡើងពី 45.4 លានដុល្លា ក្នុងឆ្នាំ 2009 ដល់ 178.5 លានដុល្លា ក្នុងឆ្នាំ 2016។[51] ប៉ុន្តែ ថវិកាមួយចំនួនធំត្រូវបានប្រើប្រាស់សម្រាប់ផ្តល់សេវាដល់ជនចូលនិវត្តន៍ និងអតីតយុទ្ធជន ដូច្នេះមានតែថវិកាមួយចំនួនតូចប៉ុណ្ណោះដែលត្រូវបានប្រើប្រាស់សម្រាប់សេវាកម្មផ្សេងៗ ដែលក្នុងនោះមានសេវាសម្រាប់កុមារ។

## ភ្នាក់ងារសុខមាលភាពសង្គម

ភ្នាក់ងារសង្គមកិច្ច គឺជាឆ្អឹងខ្នងនៃប្រព័ន្ធការពារកុមារ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ ខណៈពេលដែលកម្ពុជាផ្តល់ថវិកាគាំទ្រជាសាធារណៈដល់មន្ត្រីរដ្ឋាភិបាល ដែលធ្វើការងារក្នុងវិស័យសុខមាលភាពសង្គម មន្ត្រីទាំងនេះពុំត្រូវបានចាត់ជាភ្នាក់ងារសង្គមកិច្ចឡើយ។ ដើម្បីធានាភាពស្របគ្នាជាមួយនឹងនិយមន័យអន្តរជាតិនៃភ្នាក់ងារសង្គមកិច្ច[52] របាយការណ៍នេះបានឱ្យនិយមន័យបុគ្គលិករដ្ឋាភិបាលទាំងនេះថាជា "ភ្នាក់ងារសុខមាលភាពសង្គម" សម្រាប់កុមារ។

ភ្នាក់ងារសុខមាលភាពសង្គមនៅថ្នាក់ជាតិ និងថ្នាក់ស្រុករួមមាន មន្ត្រីរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទា និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលជាអ្នកផ្តល់សេវាដល់កុមារដែលងាយរងគ្រោះ ក៏ដូចជាប្រជាពលរដ្ឋដែលងាយរងគ្រោះដទៃទៀត។ ភ្នាក់ងារសុខមាលភាពសង្គម អាចទទួលបានការបណ្តុះបណ្តាលពេញលេញ ឬការបណ្តុះបណ្តាលផ្នែកណាមួយ ដើម្បីបំពេញការងារជាភ្នាក់ងារសង្គមកិច្ចនិងការងារសម្រាប់ប្រជាជនងាយរងគ្រោះផ្សេងៗផងដែរ។ នៅកម្ពុជាចំនួនភ្នាក់ងារសុខមាលភាពសង្គម ដោយទទួលបានការគាំទ្រពីថវិកាសាធារណៈ មានតិចតួចខ្លាំង ពោលគឺត្រឹមតែ 917 នាក់តែប៉ុណ្ណោះ ក្នុងឆ្នាំ 2012 ហើយពួកគេភាគច្រើនពុំបានទទួលការបណ្តុះបណ្តាលផ្លូវការ ដើម្បីបំពេញមុខងារជាភ្នាក់ងារសង្គមកិច្ចឡើយ។[53]

# បូកសរុប និងបោះជំហានទៅមុខ៖ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

របៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ 2030 បានដាក់ចេញនូវរបៀបវារៈប្រកបដោយមហិច្ឆតា សម្រាប់ការអភិវឌ្ឍសកលលោកទាំងមូល នៅក្នុងឆ្នាំបន្តបន្ទាប់ខាងមុខនេះ។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទាំង 17 ផ្តោតលើទិដ្ឋភាពសង្គម សេដ្ឋកិច្ច និងបរិស្ថាននៃការអភិវឌ្ឍប្រកបដោយចីរភាព។ មហាសន្និបាតសហប្រជាជាតិបានអនុម័តលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្នុងកិច្ចប្រជុំកំពូលស្តីពីការអភិវឌ្ឍប្រកបដោយចីរភាពនៅទីក្រុងញូយ៉ក កាលពីខែ កញ្ញា ឆ្នាំ 2015។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ពេលខ្លះបានគេហៅថារបៀបវារៈអភិវឌ្ឍន៍ក្រោយឆ្នាំ 2015 ព្រោះថាគោលដៅទាំងនេះ បន្តវេនពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលចប់អាណត្តិកាលពីឆ្នាំ 2015។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពមានចំណុចដៅសរុបចំនួន 169។ ចំណុចដៅទាំងនេះគឺជាគោលបំណងជាក់លាក់ ដែលសហគមន៍សកលលោកត្រូវសម្រេចឱ្យបាន។ ក្របខ័ណ្ឌសកលដែលមានជាង 200 សូចនាករ ត្រូវបានរៀបចំឡើង សម្រាប់ពិនិត្យតាមដាន និងរាយការណ៍វឌ្ឍនភាពក្នុងការឈានទៅសម្រេចចំណុចដៅទាំងនេះ។

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គឺជាសមិទ្ធផលធំធេងមួយ សម្រាប់ការការពារកុមារនៅទូទាំងសកលលោក។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ពុំបានចាត់ទុកកិច្ចការពារកុមារថាជាគោលដៅពិសេសដាច់ដោយឡែកពីគេមួយនោះឡើយ។ ប្រការនេះនាំឱ្យមានការមិនយកចិត្តទុកដាក់ចំពោះកិច្ចការពារកុមារនៅទូទាំងសកលលោកទាំងមូល និងបន្ថយបង្អាក់ដល់លទ្ធភាពរបស់អ្នកតាក់តែងគោលនយោបាយ និងអ្នកអនុវត្តការងារ ក្នុងការស្វែងរកការគាំទ្រ ក្នុងទម្រង់ជាថវិកាដែលចាំបាច់ និងការផ្លាស់ប្តូរគោលនយោបាយ ដើម្បីផ្តល់ការការពារពេញលេញដល់កុមារ។ ផ្ទុយទៅវិញ កិច្ចការពារកុមារ គឺជាសមាសធាតុដ៏សំខាន់ មិនអាចអត់បាននៃក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដោយសារតែមានការបញ្ជាក់យ៉ាងច្បាស់នៅក្នុងចក្ខុវិស័យនៃគោលដៅនេះ ពោលគឺពិភពលោកដែលកុមារគ្រប់រូបត្រូវចម្រើនវ័យ ដោយគ្មានអំពើហិង្សា និងការកេងប្រវ័ញ្ច និងគ្មាននរណាម្នាក់ត្រូវបានគេទុកចោល។ បន្ថែមពីលើគោលដៅ និងចំណុចដៅ ដែលមានភាពពាក់ព័ន្ធចំពោះកិច្ចការពារកុមារ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក៏បានបញ្ចូលនូវចំណុចដៅពិសេសដែលផ្តោតលើកិច្ចការពារកុមារផងដែរ ដោយមានការផ្តោតការយកចិត្តទុកដាក់លើសារៈសំខាន់នៃការឆ្លើយតបចំពោះអំពើហិង្សាលើកុមារ។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងចំណុចដៅនានា ត្រូវបានរៀបរាប់បន្ថែមទៀត តាមរយៈការដាក់ចេញនូវលទ្ធផល ដែលអាចវាស់វែងបាន ក្រោមក្របខ័ណ្ឌសូចនាករសកល ដែលអនុម័តដោយគណៈកម្មការស្ថិតិអង្គការសហប្រជាជាតិ កាលពីខែមិនា ឆ្នាំ 2017។ បន្ថែមពីលើសូចនាករសកលទាំងនេះ ប្រទេសជាច្រើនកំពុងខិតខំរៀបចំសូចនាករសម្រាប់ប្រទេសរៀងៗខ្លួន ដើម្បីធានាយ៉ាងណាឱ្យក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនេះ មានភាពពាក់ព័ន្ធទៅនឹងបរិបទក្នុងប្រទេស។

លទ្ធភាពជាសក្តានុពល ដែលគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព អាចនាំឱ្យមានការផ្លាស់ប្តូរសម្រាប់កុមារនៅកម្ពុជា និងធានាឱ្យមានការផ្តល់ការការពារដល់ពួកគេ គឺអាស្រ័យមួយផ្នែកលើការប្តេជ្ញាចិត្តរបស់ប្រទេសនេះ ក្នុងការផ្តល់ទិន្នន័យដែលមានគុណភាពខ្ពស់ ទាន់ពេលវេលា និងបែងចែកតាមប្រភេទ ដើម្បីផ្តល់លទ្ធភាពឱ្យរដ្ឋាភិបាល និងដៃគូ អាចតាមដានដឹងពីវឌ្ឍនភាព និងធ្វើការកែតម្រូវសកម្មភាពដែលខ្លួនអនុវត្តទៅតាមការចាំបាច់។ ការវិនិយោគមិនគ្រប់គ្រាន់លើការប្រមូលទិន្នន័យ អាចធ្វើឱ្យប៉ះពាល់ដល់ការប្តេជ្ញាចិត្តរបស់ប្រទេសនេះ ក្នុងការផ្តល់សេវាដល់អ្នកដែលនៅឆ្ងាយក្រោយគេ និងដោះស្រាយបញ្ហាវិសមធម៌។ ការវិនិយោគលើទិន្នន័យ ដូចជា ការប្រមូល ការវិភាគ និងការប្រើប្រាស់ទិន្នន័យជាដើម មានសារៈសំខាន់ជាពិសេស សម្រាប់ពិនិត្យតាមដានវឌ្ឍនភាពនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងធានាបាននូវគណនេយ្យភាព ក៏ដូចជាបង្កើនការយល់ដឹងអំពីបញ្ហាប្រឈម ពាក់ព័ន្ធនឹងកិច្ចការពារកុមារដែលកំពុងបន្តកើតឡើង និងដែលកើតឡើងថ្មីៗ ក៏ដូចជាការផ្លាស់ប្តូរដទៃទៀត ខណៈពេលដែលពិភពលោកមានការប្រែប្រួលចន្លោះពីពេលឥលូវនេះរហូតដល់ឆ្នាំ 2030។

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព**



## ទិន្នន័យដែលមានសម្រាប់ប្រទេសកម្ពុជាទាក់ទិននឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្រិតសកល និងចំណុចដៅ ដែលមានសូចនាករពាក់ព័ន្ធនឹងកិច្ចការពារកុមារ

| ចំណុចដៅនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | ទិន្នន័យដើមគ្រា (ប្រភព) |
|---|---|---|
| **គោលដៅទី 5 សម្រេចឱ្យបាននូវសមភាពយេនឌ័រ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងក្មេងស្រីគ្រប់រូប** | | |
| 5.1 បញ្ចប់រាល់ទម្រង់នៃការរើសអើងលើស្ត្រី និង ក្មេងស្រីនៅគ្រប់ទីកន្លែង | 5.1.1 ថាតើក្របខ័ណ្ឌច្បាប់ត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីលើកកម្ពស់ ពង្រឹង និងពិនិត្យតាមដានសមភាព និងការមិនរើសអើង ផ្អែកតាមភេទដែរឬទេ | ពុំមានទិន្នន័យ |
| 5.2 លុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីទាំងអស់នៅតាមទីសាធារណៈ និងទីកន្លែងឯកជន រាប់បញ្ចូលទាំងការជួញដូរ និងការធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចក្នុងរូបភាពផ្សេងទៀត | 5.2.1 ភាគរយនៃស្ត្រីដែលរៀបការហើយ និងក្មេងស្រីអាយុចាប់ពី 15 ឆ្នាំឡើងទៅ ដែលទទួលរងអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទ ពីសំណាក់ដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬអតីតដៃគូស្និទ្ធស្នាល ក្នុងរយៈពេល 12 ខែចុងក្រោយ បែងចែកទៅតាមទម្រង់នៃអំពើហិង្សា និងតាមភេទ | ស្ត្រី និងក្មេងស្រីដែលធ្លាប់រៀបការហើយ អាយុចន្លោះពី 15-49 ឆ្នាំ៖ 20% ( CDHS, 2014 ) |
| | 5.2.2 ភាគរយនៃស្ត្រី និងក្មេងស្រីអាយុចាប់ពី 15 ឆ្នាំឡើងទៅ ដែលទទួលរងអំពើហិង្សាផ្លូវភេទពីសំណាក់មនុស្សផ្សេងទៀត ដែលមិនមែនជាដៃគូស្និទ្ធស្នាល ក្នុងរយៈពេល 12 ខែចុងក្រោយ បែងចែកទៅតាមអាយុ និងកន្លែងដែលអំពើហិង្សាកើតមានឡើង | ក្មេងស្រី និងស្ត្រីអាយុ 15-49 ឆ្នាំ៖ 0.1% ( CDHS, 2014 ) |
| 5.3 លុបបំបាត់រាល់ការអនុវត្ត ដែលនាំឱ្យមានគ្រោះថ្នាក់ទាំងអស់ ដូចជាការរៀបអាពាហ៍ពិពាហ៍វ័យកុមារ ការឆាប់រៀបអាពាហ៍ពិពាហ៍ និងការបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ និងការកាត់ច្រឹបប្រដាប់ភេទរបស់ស្ត្រី | 5.3.1 ភាគរយនៃស្ត្រីអាយុ 20-24 ឆ្នាំ ដែលរៀបការដំបូង ឬរស់នៅជាមួយដៃគូរបស់ខ្លួនដំបូង មុនអាយុ 15 ឆ្នាំ និងមុនអាយុ 18 ឆ្នាំ | រៀបការមុនអាយុ 15 ឆ្នាំ៖ 2%<br>រៀបការមុនអាយុ១៨ឆ្នាំ៖ 19%<br>( CDHS, 2014 ) |
| **គោលដៅទី 8 លើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពបរិយាប័ន្ន និងចីរភាព ការងារ និងមុខរបរពេញលេញ និងប្រកបដោយផលិតភាព និងការងារសមរម្យសម្រាប់ទាំងអស់គ្នា** | | |
| 8.7 ចាត់វិធានការប្រកបដោយប្រសិទ្ធភាពបន្ទាន់ ដើម្បីលុបបំបាត់ពលកម្មដោយបង្ខំ បញ្ចប់អំពើទាសភាពសម័យទំនើប ក្នុងការជួញដូរមនុស្ស និងធានាឱ្យមានការហាមឃាត់ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ រាប់បញ្ចូលទាំងការជ្រើសរើស និងការប្រើប្រាស់ទាហានកុមារ និងបញ្ចប់រាល់ទម្រង់ទាំងអស់នៃពលកម្មកុមារត្រឹម 2025 | 8.7.1 ភាគរយនៃចំនួនកុមារអាយុ 5-17 ឆ្នាំ ដែលចូលរួមក្នុងពលកម្មកុមារ បែងចែកទៅតាមភេទ និងអាយុ | 11% ( ILO, 2012 ) |
| **គោលដៅទី 16 លើកកម្ពស់សង្គមប្រកបដោយសន្តិភាព និងបរិយាប័ន្ន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ផ្តល់លទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ទាំងអស់គ្នា និងកសាងនូវស្ថាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាប័ន្ននៅគ្រប់កម្រិតទាំងអស់** | | |
| 16.1 កាត់បន្ថយឱ្យបានច្រើននូវអំពើហិង្សាក្នុងគ្រប់ទម្រង់ និងអត្រាមរណភាព ដោយពាក់ព័ន្ធនឹងអំពើហិង្សានៅគ្រប់ទីកន្លែង | 16.1.1 ចំនួនជនរងគ្រោះ ដោយសារការធ្វើឃាតដោយចេតនា ក្នុងចំណោមប្រជាជន 100,000 នាក់ បែងចែកតាមភេទ និងអាយុ | កុមារ និងក្មេងជំទង់អាយុ 0-19 ឆ្នាំ៖ 0.9 ក្នុងប្រជាជន 100,000 នាក់ក្នុងឆ្នាំ 2015 ( WHO, 2016 ) |
| | 16.1.2 ករណីបាត់បង់ជីវិតពាក់ព័ន្ធនឹងជម្លោះក្នុងប្រជាជន 100,000 នាក់ បែងចែកតាមភេទ និងអាយុ និងមូលហេតុ | ពុំមានទិន្នន័យ |
| 16.2 បញ្ចប់ការរំលោភបំពាន ការកេងប្រវ័ញ្ច ការជួញដូរ និងរាល់ទម្រង់នៃអំពើហិង្សាលើកុមារ និងការធ្វើទារុណកម្មលើកុមារ | 16.2.1 ភាគរយនៃកុមារអាយុ 1-17 ឆ្នាំ ដែលទទួលរងការផ្តន្ទាទោសផ្លូវកាយ និង/ឬការធ្វើបាបផ្លូវចិត្ត ពីសំណាក់អ្នកផ្តល់ការថែទាំ ក្នុងខែកន្លងទៅនេះ | ពុំមានទិន្នន័យ |
| | 16.2.2 ចំនួនជនរងគ្រោះដោយសារការជួញដូរមនុស្ស ក្នុងប្រជាជន 100,000 នាក់ បែងចែកតាមភេទ និងអាយុ និងទម្រង់នៃការកេងប្រវ័ញ្ច | ពុំមានទិន្នន័យ |
| | 16.2.3 ភាគរយនៃស្ត្រី និងបុរសវ័យក្មេងអាយុ 18-29 ឆ្នាំ ដែលទទួលរងអំពើហិង្សាផ្លូវភេទត្រឹមអាយុ 18 ឆ្នាំ | ស្ត្រីអាយុ 18-29 ឆ្នាំ៖ 2%<br>( CDHS, 2014 ) |
| 16.9 ត្រឹមឆ្នាំ 2030 ផ្តល់អត្តសញ្ញាណស្របច្បាប់ដល់មនុស្សទាំងអស់គ្នា រាប់បញ្ចូលទាំងការចុះសំបុត្រកំណើតផង | 16.9.1 ភាគរយនៃកុមារអាយុក្រោម 5 ឆ្នាំ ដែលត្រូវបានចុះសំបុត្រកំណើតជាមួយមន្ត្រីអត្រានុកូលដ្ឋាន បែងចែកតាមអាយុ | 73% ( CDHS, 2014 ) |

# បំពេញចន្លោះខ្វះខាតសំខាន់ៗនៃទិន្នន័យ

## រៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានស្តីពីកិច្ចការពារកុមារ

ប្រទេសកម្ពុជានៅខ្វះប្រព័ន្ធគ្រប់គ្រងព័ត៌មានស្តីពីកិច្ចការពារកុមារ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ ប្រព័ន្ធបែបនេះត្រូវបញ្ចូលដំណើរការដែលមានប្រសិទ្ធភាព សម្រាប់ធ្វើការប្រមូលទិន្នន័យជាប្រចាំ វិភាគ និងបកស្រាយទិន្នន័យសំខាន់ៗរួមគ្នា ដើម្បីផ្តល់ជាព័ត៌មានដល់ប្រព័ន្ធកិច្ចការពារកុមារនៅគ្រប់កម្រិតទាំងអស់ ចាប់ពីការកំណត់រកឃើញករណីរំលោភបំពានកុមារឱ្យបានទាន់ពេលវេលា រហូតដល់ការឆ្លើយតបចំពោះករណីរំលោភបំពានទាំងនេះ។ ដើម្បីមាននិរន្តរភាព ការបង្កើត និងការថែទាំប្រព័ន្ធទាំងនេះ គួរធ្វើឡើងក្រោមការដឹកនាំរបស់រដ្ឋាភិបាល។ ព័ត៌មានតិចតួចដែលអាចរកបាននាពេលបច្ចុប្បន្ននេះ គឺមានតែក្នុងពេលខ្លះ និងដោយពុំមានការគ្រោងទុកត្រឹមត្រូវ ហើយជាធម្មតា ព័ត៌មានទាំងនេះត្រូវបានគេប្រមូល និងប្រើប្រាស់ តែសម្រាប់ក្នុងគោលបំណងជាក់លាក់មួយចំនួនតែប៉ុណ្ណោះ។ ការខ្វះព័ត៌មានដែលងាយស្រួលទទួលបានទាន់ពេលវេលា និងអាចជឿទុកចិត្តបានអំពី បញ្ហាសំខាន់ៗដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ ក៏ជាកត្តាធ្វើឱ្យរាំងស្ទះដល់ការរៀបចំផែនការ ការអនុវត្តកម្មវិធី និងការវាយតម្លៃឱ្យមានប្រសិទ្ធភាពផងដែរ។ របាយការណ៍នេះគឺជា ការខិតខំប្រឹងប្រែងដំបូង ដើម្បីប្រមូលទិន្នន័យសំខាន់ៗពាក់ព័ន្ធនឹងកិច្ចការពារកុមារ បញ្ចូលក្នុងទម្រង់រួម ដែលមានលក្ខណៈច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ។

## កែសម្រួលឧបករណ៍ដែលមានស្រាប់ ដើម្បីបំពេញចន្លោះខ្វះខាតទិន្នន័យ

ឧបករណ៍ទិន្នន័យដែលមានស្រាប់ នៅមានចន្លោះខ្វាតខាតពាក់ព័ន្ធនឹងការវាស់វែង ដែលគេអាចកែតម្រូវបានដូចតទៅ៖

*អំពើហិង្សាលើកុមារ៖* ទិន្នន័យស្តីពីអ្នកប្រព្រឹត្តអំពើហិង្សាលើកុមារ (ទាំងក្នុងការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា និងការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារនៅក្នុងកម្ពុជា) ពុំបានញែកឪពុកម្តាយពីឪពុកម្តាយចុងនោះឡើយ បើទោះបីជាឪពុកម្តាយទាំង 2 ប្រភេទនេះ នាំមកនូវប្រភេទហានិភ័យខុសៗគ្នាយ៉ាងណាក៏ដោយ។ ដោយសារតែឪពុកម្តាយចុងបង្កហានិភ័យខ្ពស់ យកល្អគឺគួរបែងចែកទិន្នន័យនេះទៅតាម ប្រភេទឪពុកម្តាយ និងឪពុកម្តាយចុង។

សូចនាករមួយ ក្នុងចំណោមសូចនាករនានា ដែលត្រូវបានជ្រើសរើសសម្រាប់ពិនិត្យតាមដានចំណុចដៅ 16.2 នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព លើកឡើងពីការដាក់វិន័យបែបហិង្សានៅក្នុងផ្ទះដែលកុមារទទួលរង។ បច្ចុប្បន្ននេះ ពុំមានទិន្នន័យតំណាងឱ្យទូទាំងប្រទេស សម្រាប់ប្រទេសកម្ពុជាសម្រាប់សូចនាករនេះឡើយ។ ប៉ុន្តែមានឧបករណ៍ដែលត្រូវបានដាក់ឱ្យអនុវត្តជាស្តង់ដា និងមានការបញ្ជាប់ផ្ទៀងផ្ទាត់ត្រឹមត្រូវមួយ ដែលមានឈ្មោះថា មាត្រដ្ឋានតាក់តិចទំនាស់ (Conflict Tactics Scale – CTS) ដែលត្រូវបានគេយកមកប្រើប្រាស់យ៉ាងទូលំទូលាយ ដើម្បីប្រមូលទិន្នន័យទាំងនេះ។ កម្មវិធីអង្កេតតាមគ្រួសារអន្តរជាតិមួយចំនួន ដូចជាការអង្កេតប្រជាសាស្ត្រ និងសុខភាព និងការអង្កេត ប្រមូលព័ត៌មាន សម្រាប់ក្រុមសូចនាករចំរុះ (Multiple Indicator Cluster Surveys – MICS) ដែលទទួលបានការគាំទ្រពីយូនីសេហ្វ បានប្រើប្រាស់ឧបករណ៍ CTS ក្នុងទម្រង់ដែលត្រូវបានកែសម្រួល ដែលគេក៏អាចយកឧបករណ៍នេះមកប្រើប្រាស់ក្នុងប្រទេសកម្ពុជាផងដែរ។

*ភាពក្រីក្រ៖* កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលអនុវត្តដោយរដ្ឋាភិបាលកម្ពុជា គឺជាមធ្យោបាយមួយ សម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ដើម្បីឱ្យពួកគេអាចទទួលបានសេវាកាន់តែល្អប្រសើរជាងមុន។ ឧបករណ៍ដែលមានស្រាប់នេះ ក៏អាចមានប្រយោជន៍សម្រាប់វិស័យកិច្ចការពារកុមារផងដែរ ដោយសារគ្រួសារក្រីក្រជាច្រើនងាយរងគ្រោះពាក់ព័ន្ធនឹងកិច្ចការពារកុមារ។ ដើម្បីឱ្យការរៀបចំផែនការ ផ្អែកតាមមូលដ្ឋានភស្តុតាងរឹងមាំអាចធ្វើទៅបាន ការតស៊ូមតិ នាពេលអនាគត គួរធានាយ៉ាងណាឱ្យទិន្នន័យដែលរកឃើញដោយប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ អំពីចំនួនកុមាររស់នៅក្នុងគ្រួសារក្រីក្រ អាចឱ្យគេងាយស្រួលប្រើប្រាស់ ដោយត្រូវរៀបចំក្នុងទម្រង់ ដែលផ្តល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់ទិន្នន័យនេះ។

*ពិការភាព៖* ការប្រើប្រាស់និយមន័យនិងសំណួរអង្កេតខុសៗគ្នាដែលពុំមានភាពសមស្របសម្រាប់ការវាយតម្លៃពិការភាពរបស់កុមារ នាំឱ្យមានការរកឃើញខុសៗគ្នា និងទំនងនាំឱ្យមានការប៉ាន់ប្រមាណចំនួនកុមារពិការទាបជាងចំនួនពិតប្រាកដ បើធៀបនឹងការរាយការណ៍ពីកម្រិតប្រេវ៉ាឡង់ពិការភាពនៅកម្ពុជា។ ក្រុមស្ថិតិពិការភាពវ៉ាស៊ីនតោន និងយូនីសេហ្វ បានរៀបចំម៉ូឌុលអង្កេតមួយ ស្តីពីការបំពេញមុខងាររបស់កុមារ ដែលអាចយកមកប្រើប្រាស់នៅកម្ពុជាបាន។ ម៉ូឌុលនេះធ្វើការវាយតម្លៃពីកម្រិតនៃការលំបាកក្នុងការបំពេញមុខងារ ពាក់ព័ន្ធនឹងផ្នែកសំខាន់ៗ ក្នុងចំណោមកុមារអាយុពី 2 ដល់ 17 ឆ្នាំ។

## បង្កើនគុណភាពទិន្នន័យ

ដូចដែលបានឃើញនៅក្នុងរបាយការណ៍នេះ ប្រទេសកម្ពុជាមានទិន្នន័យច្រើនលើសូចនាករស្តីពីកិច្ចការពារកុមារ ប៉ុន្តែគុណភាពនៃទិន្នន័យទាំងនេះមានចំណុចខ្វះខាតមួយចំនួន ដែលទាមទារឱ្យមានការកែសម្រួលវិធីសាស្ត្រប្រមូលទិន្នន័យ ដែលកំពុងប្រើប្រាស់នៅពេលបច្ចុប្បន្ន ឬរៀបចំបង្កើតវិធីសាស្ត្រប្រមូលទិន្នន័យថ្មីតែម្តង។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួនតូចដែលឆ្លុះបញ្ចាំងពីចំណុចនេះ៖



*ទិន្នន័យស្តីពីកុមាររស់នៅ ឬធ្វើការតាមផ្លូវ៖* ការប្រមូលទិន្នន័យបច្ចុប្បន្ននេះ ពុំបានបង្កើតនូវតួលេខចំនួនកុមាររស់នៅ ឬធ្វើការងារតាមផ្លូវ ដែលអាចជឿទុកចិត្តបាន មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងតំណាងឱ្យប្រទេសទាំងមូលនោះឡើយ។ នេះគឺជាចំណុចខ្វះខាតដ៏សំខាន់មួយដែលចាំបាច់ត្រូវធ្វើការឆ្លើយតបជាបន្ទាន់។

*ទិន្នន័យស្តីពីការជួញដូរកុមារ៖* ការពឹងផ្អែកលើការសិក្សាទ្រង់ទ្រាយតូច និងការពុំមានទិន្នន័យកុមារ បែងចែកទៅតាមប្រភេទ មានន័យថាចំនួនកុមារដែលរងផលប៉ះពាល់ដោយសារការជួញដូរមនុស្សនៅកម្ពុជា នៅតែជាព័ត៌មានដែលគេមិនដឹង។ គួរមានការផ្តល់ធនធានសម្រាប់រៀបចំការសិក្សា ដែលគោរពទៅតាមគោលការណ៍ស្ថិតិបានត្រឹមត្រូវ។

## ប្រមូលទិន្នន័យដើមគ្រា ស្តីពីសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

របៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ 2030 ទទួលស្គាល់ថាទិន្នន័យដើមគ្រាសម្រាប់ចំណុចដៅជាច្រើន នៅពុំទាន់មាននៅឡើយ។ របៀបវារៈនេះ ជម្រុញឱ្យមានការផ្តល់ការគាំទ្របន្ថែមទៀតសម្រាប់ពង្រឹងការងារប្រមូលទិន្នន័យ និងការកសាងសមត្ថភាពនៅតាមរដ្ឋដែលជាសមាជិករបស់អង្គការសហប្រជាជាតិ ក្នុងការរៀបចំប្រមូលទិន្នន័យដើមគ្រា នៅក្នុងករណីដែលមិនទាន់មានទិន្នន័យទាំងនេះ។ ចាំបាច់ត្រូវមានទិន្នន័យដើមគ្រាជាបន្ទាន់ ដើម្បីវាស់វែងវឌ្ឍនភាពក្នុងការឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ជាពិសេសគោលដៅទាំងឡាយដែលមានការកំណត់ចំណុចដៅឱ្យបានច្បាស់លាស់។ ដូច្នេះ ប្រទេសកម្ពុជាចាំបាច់ត្រូវប្រមូលទិន្នន័យដើមគ្រា សម្រាប់រាល់សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលប្រទេសនេះត្រូវបានជ្រើសរើសទាំងអស់ ហើយប្រើប្រាស់ទិន្នន័យទាំងនេះ ដើម្បីពិនិត្យលើវឌ្ឍនភាពក្នុងការឈានទៅសម្រេចចំណុចដៅ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្នុងឆ្នាំបន្តបន្ទាប់ខាងមុខនេះ។

## វិធីសាស្ត្រផ្សេងទៀតសម្រាប់កែលំអទិន្នន័យ ស្តីពីកិច្ចការពារកុមារនៅកម្ពុជា

- បង្កើនសមត្ថភាពជាតិ និងកែលំអប្រព័ន្ធសម្រាប់ប្រមូល វិភាគ និងផ្សព្វផ្សាយទិន្នន័យ បែងចែកតាមអាយុ ដើម្បីបង្កើនគុណភាព និងភាពអាចរកបាននៃស្ថិតិស្តីពីបញ្ហាការពារកុមារជាអាទិភាព។ ចាំបាច់ត្រូវមានការវិនិយោគ ដើម្បីកំណត់ពីប្រេវ៉ាឡង់ និងផលប៉ះពាល់ដែលបង្កឡើងដោយអំពើហិង្សា និងពង្រឹងប្រព័ន្ធចុះអត្រានុកូលដ្ឋាន និងស្ថិតិសំខាន់ៗ (ដូចជាស្ថិតិស្តីពីការថែទាំតាមមណ្ឌល ការចុះសំបុត្រកំណើត និងអាពាហ៍ពិពាហ៍វ័យកុមារ) ដែលសុទ្ធតែជាទិន្នន័យសំខាន់ៗ និងចាំបាច់។
- ពន្លឿនការអនុវត្តផែនការបច្ចុប្បន្ន ដើម្បីបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មាន ស្តីពីកិច្ចការពារកុមារនៅថ្នាក់ជាតិមួយ និងបង្កើតផ្នែកណាមួយសម្រាប់ប្រមូលទិន្នន័យ និងពិនិត្យតាមដានវឌ្ឍនភាព ក្នុងការឈានទៅសម្រេចចំណុចដៅនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។
- បែកចែកទិន្នន័យទៅតាមប្រភេទ (ដូចជា ជាតិពន្ធុ ភេទ អាយុ ទ្រព្យសម្បត្តិ ពិការភាព ទីតាំង និងស្ថានភាពទេសន្តរប្រវេសន៍ជាដើម) ដើម្បីឱ្យគេអាចកំណត់ និងស្វែងយល់កាន់តែច្បាស់ពីកុមារដែលជួបការលំបាក និងងាយរងគ្រោះជាងគេ ដែលត្រូវការកិច្ចការពារ។
- កែលំអរបៀបប្រមូលទិន្នន័យអំពីក្រុមកុមារ ដែលគេតែងរាប់ចំនួនបានតិចជាងចំនួនជាក់ស្តែង ដូចជាកុមារដែលរស់នៅតាមមណ្ឌល កុមារដែលរស់នៅ ឬធ្វើការងារតាមផ្លូវ និងកុមារដែលពុំមានទីលំនៅ ឬដែលទទួលរងការរំលោភបំពានមួយចំនួន ក្នុងចំណោមការរំលោភបំពាន ដែលមានលក្ខណៈធ្ងន់ធ្ងរបំផុត។
- វិនិយោគលើការប្រមូលទិន្នន័យពាក់ព័ន្ធជាប្រចាំ ដើម្បីអាចផលិតនូវស្ថិតិ ដែលច្បាស់លាស់ និងដែលអាចឱ្យគេធ្វើការប្រៀបធៀបបាន។
- ស្វែងយល់ពីការអនុវត្តឧបករណ៍ដែលមានស្រាប់ ដែលបានទទួលការបញ្ជាក់ផ្ទៀងផ្ទាត់ត្រឹមត្រូវសម្រាប់វាស់វែងទិដ្ឋភាពសំខាន់ៗនូវកិច្ចការពារកុមារដូចជា ការទទួលរងការដាក់វិន័យបែបហិង្សានៅផ្ទះជាដើម។
- ជម្រុញ និងលើកទឹកចិត្តឱ្យមានការវិភាគឱ្យបានស៊ីជម្រៅ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវស្ថិតិ ស្តីពីកិច្ចការពារកុមារ។
- រៀបចំពិធីសារស្តីពីក្រមសីលធម៌ និងសុវត្ថិភាពក្នុងការប្រមូលទិន្នន័យ ស្តីពីបញ្ហាកិច្ចការពារកុមារ ដើម្បីការពារកុមារពីគ្រោះថ្នាក់ ដែលអាចកើតឡើងដោយសារការចូលរួមរបស់ពួកគេ ក្នុងការប្រមូលទិន្នន័យនេះ។
- ផ្តល់ឱ្យអ្នកតាក់តែងគោលនយោបាយនូវទិន្នន័យ ដែលអាចយកទៅបំលែងជាសកម្មភាពសម្រាប់អនុវត្ត ដើម្បីឱ្យអ្នកតាក់តែងគោលនយោបាយទាំងនេះអាចធ្វើការសម្រេចចិត្ត ផ្អែកទៅតាមភស្តុតាងទាំងនេះបាន។
- រៀបចំយុទ្ធសាស្ត្រជាតិស្ថិតិ ដើម្បីធានាយ៉ាងណាឱ្យបញ្ហាសំខាន់ៗពាក់ព័ន្ធនឹងកិច្ចការពារកុមារត្រូវបានបញ្ចូលទៅក្នុងកិច្ចខិតខំប្រមូលទិន្នន័យក្នុងលក្ខណៈជាប្រព័ន្ធ និងជាប្រចាំ។

# កំណត់សម្គាល់បច្ចេកទេស ស្តីពីទិន្នន័យដែលប្រើប្រាស់ ក្នុងរបាយការណ៍នេះ

របាយការណ៍នេះបានប្រើប្រាស់ទិន្នន័យពីប្រភពជាច្រើន ដើម្បីបង្ហាញពីសូចនាករមួយចំនួន (ឧទាហរណ៍ ពលកម្មកុមារ ការរៀបចំកន្លែងរស់នៅរបស់កុមារជាដើម) ដើម្បីផ្តល់នូវទិដ្ឋភាពរួមទូទៅ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ ប៉ុន្តែការប្រៀបធៀបទិន្នន័យដែលបានពីប្រភពមួយទៅប្រភពមួយទៀត ទាមទារឱ្យមានការប្រុងប្រយ័ត្ន ដោយសារវិធីវាស់វែង និងនិយមន័យដែលប្រើប្រាស់ អាចមានលក្ខណៈខុសប្លែកពីគ្នា។

ការប្រើប្រាស់ទិន្នន័យអំពីសូចនាករមួយចំនួន អាស្រ័យទៅតាមភាពអាចរកបាននូវរបាយការណ៍អង្កេតដែលត្រូវបានបោះពុម្ពផ្សាយ និងការចូលទៅមើលទិន្នន័យក្នុងប្រព័ន្ធទិន្នន័យ។ ទិន្នន័យនេះបង្ហាញនៅក្នុងរបាយការណ៍នេះ គឺបានពីប្រភពដែលអាចរកបានចុងក្រោយសម្រាប់ប្រធានបទនីមួយៗ។ ក្នុងករណីមួយចំនួន មានលទ្ធផលខ្លះតែប៉ុណ្ណោះ ដែលត្រូវបានបោះពុម្ពផ្សាយក្នុងរបាយការណ៍នៃការអង្កេត និង/ឬពុំមានសំណុំទិន្នន័យទាំងមូលឡើយ។ ប្រការនេះធ្វើឱ្យយើងមិនអាចធ្វើការវិភាគបន្ថែមទៀត ឬធ្វើការប៉ាន់ប្រមាណនូវតួលេខសារជាថ្មី ដើម្បីឱ្យតួលេខនេះមានសង្គតិភាពជាមួយនឹងនិយមន័យ ដែលប្រើប្រាស់សម្រាប់សូចនាករនោះឡើយ។

គុណភាព និងភាពសុក្រិតនៃទិន្នន័យ ជាបញ្ហាប្រឈមសម្រាប់ការធ្វើស្ថិតិមិនថានៅវិស័យណាក៏ដោយ។ ប៉ុន្តែគុណភាព និងសុក្រិតភាពនៃទិន្នន័យរឹតតែជាបញ្ហាប្រឈមខ្លាំងសម្រាប់ប្រធានបទទាក់ទងនឹងកិច្ចការពារកុមារ ដោយសារតែតួលេខទាំងនេះងាយនឹងត្រូវបានគេរាយការណ៍មិនដល់ចំនួនជាក់ស្តែង និងដោយសារភាពលំអៀង ដែលអាចកើតមានផ្សេងទៀត។ ដូច្នេះគេចាំបាច់ត្រូវប្រុងប្រយ័ត្ននៅពេលធ្វើការបកស្រាយលទ្ធផលដែលបានរកឃើញ។ គេគួរសន្មតថាតួលេខ ដែលបង្ហាញពីប្រធានបទមួយចំនួន ជាពិសេសតួលេខស្តីពីអំពើហិង្សាលើកុមារ និងការជួញដូរកុមារ ជាតួលេខប៉ាន់ប្រមាណទាបជាងចំនួនកុមារ ដែលរងផលប៉ះពាល់ជាក់ស្តែង។

នៅពេលពិនិត្យលើនិន្នាការនានា គេគួរពិចារណាលើកត្តាជាច្រើន ដូចជា ចំនួនឆ្នាំនៅចន្លោះការអង្កេត ដែលធ្វើបន្តបន្ទាប់គ្នា ចំនួនចំណុចទិន្នន័យដែលមាន កម្រិតនៃការផ្លាស់ប្តូរភាពពាក់ព័ន្ធដែលអាចកើតឡើងដោយសារការរៀបចំកម្រងសំណួរ និង/ឬការអនុវត្ត និងភាពខុសប្លែកគ្នានៃការប៉ាន់ប្រមាណ ដែលមានទំហំធំជាងការរំពឹងទុកនៃកំហុសពីការបង្កើតសំណាក់គំរូតែម្យ៉ាងគត់។ ពាក់ព័ន្ធជាមួយនឹងចំណុចចុងក្រោយនេះ កំហុសនៃការបង្កើតសំណាក់គំរូ ជាធម្មតាត្រូវបានគេវាស់វែងជាកំហុសស្តង់ដា (standard error) សម្រាប់ស្ថិតិមួយចំនួន (មធ្យមភាគ ភាគរយ ។ល។)។ គេអាចប្រើប្រាស់កំហុសស្តង់ដាដើម្បីគណនារកចន្លោះទំនុកចិត្ត (confidence intervals) សម្រាប់តួលេខពិតប្រាកដរបស់ក្រុមប្រជាជនទាំងមូល។ ការបង្រួញចន្លោះទំនុកចិត្ត នាំឱ្យការប៉ាន់ប្រមាណកាន់តែមានលក្ខណៈជាក់លាក់។ ចន្លោះទំនុកចិត្តមិនត្រូវបានបង្ហាញនៅក្នុងតារាងទេ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការអាន។

# ប្រភពទិន្នន័យ


Asian Development Bank, Cambodia: Country Poverty Analysis, 2014, ADB, Philippines, 2014.

Cambodian Mine Action Authority, Cambodia Mine/ERW Information Management System, CMAA, Cambodia, 2017.

Cambodian Street Children Network, Cambodian Street Children Profile 2011, Phnom Penh, 2012.

ECPAT International, Global Monitoring Status of Action against Commercial Sexual Exploitation of Children: Cambodia, ECPAT International, Bangkok, 2011.

International Justice Mission, External Evaluation of International Justice Mission's Program to Combat Sex Trafficking of Children in Cambodia, 2004-2014, IJM, Washington, D.C., 2015.

International Labour Organization and National Institute of Statistics, Cambodia Labour Force and Child Labour Survey 2012, ILO/NIS, Phnom Penh, 2013.

Joint United Nations Programme on HIV/AIDS, HIV/AIDS Estimates, Spectrum, Cambodia, 2016.

Ministry of Economy and Finance, Budget Book 2009-2016, Cambodia, 2016.

Ministry of Planning, IDPoor Programme, Identification of Poor Households Programme, Cambodia, 2017 (Round 8-Round 10/2014-2016), <www.idpoor.gov.kh/en/reports>.

Ministry of Social Affairs, Veterans and Youth Rehabilitation, A Functional Review of the Ministry of Social Affairs, Veterans and Youth Rehabilitation, MoSVY, Cambodia, 2014.

Ministry of Social Affairs, Veterans and Youth Rehabilitation, Report: Mapping of Residential Care Facilities in the Capital and 24 Provinces of the Kingdom of Cambodia, MoSVY, Cambodia, 2017.

Ministry of Social Affairs, Veterans and Youth Rehabilitation, Summary Report on the Result of Inspection of Residential Care Institutions of NGOs and State Run Centres in Municipalities and Provinces, MoSVY, Cambodia, 2005–2016.

Ministry of Women's Affairs, UNICEF Cambodia, US Centers for Disease Control and Prevention, Findings from Cambodia's Violence Against Children Survey 2013, Cambodia, 2014.

National AIDS Authority, Cambodia Country Progress Report – Monitoring Progress Towards the 2011 UN Political Declaration on HIV and AIDS (2014), NAA and UNAIDS, 2015.

National Institute of Statistics, Cambodia Socio-Economic Survey 2014, National Institute of Statistics, Royal Government of Cambodia, Phnom Penh, 2015.

National Institute of Statistics and Columbia University, National Estimation of Children in Residential Care Institutions in Cambodia, Cambodia, 2016.

National Institute of Statistics and Columbia University, National Estimation of Homeless Children in Cambodia, Cambodia, 2016.

National Institute of Statistics, Directorate General for Health and ICF International, Cambodia Demographic and Health Survey 2014, National Institute of Statistics, Royal Government of Cambodia, Phnom Penh, 2015.

United Nations Children's Fund, Children and AIDS: 2015 statistical update, UNICEF, New York, 2015, <https://data.unicef.org/topic/hivaids/protection-care-and-support-for-children-affected-by-hiv-and-aids/>.

United Nations Department of Economic and Social Affairs, Population Division, World Population Prospects: The 2015 revision, DVD edition, UNDESA, New York, 2015.

World Health Organization, Global Health Estimates 2015: Deaths by Cause, Age, Sex, by Country and by Region, 2000–2015, Geneva, WHO, 2016, recalculated by UNICEF.

# ឯកសារយោងបន្ថែម

Harachi, T. W., Review of Social Work Practice: An emphasis on public social and child welfare, National Institute of Social Affairs and UNICEF, Phnom Penh, 2014.

Ministry of Social Affairs, Veterans and Youth Rehabilitation, Minimum Standards on Alternative Care for Children, MoSVY, Phonm Penh, May 2008, <www.bettercarenetwork.org/sites/default/files/Minimum%20Standards%20on%20Alternative%20Care%20for%20Children%20Cambodia.pdf>.

National Multisectoral Orphans and Vulnerable Children Task Force, Orphans, Children Affected by HIV and Other Vulnerable Children in Cambodia: A situation and response assessment, 2007, Cambodia, 2008.

United Nations General Assembly, Guidelines for the Alternative Care of Children, UN document A/RES/64/142, United Nations, Geneva, 2009, <www.unicef.org/protection/alternative_care_Guidelines-English.pdf>.

# កំណត់សម្គាល់ចុងក្រោយ

1. ទិន្នន័យនៅក្នុងផ្នែកនេះសំដៅលើទិន្នន័យឆ្នាំ 2017 លុះត្រាតែមានការបញ្ជាក់ផ្សេង។ ប្រភពទិន្នន័យទាំងអស់ ដែលត្រូវបានបញ្ចូលក្នុងផ្នែកនេះគឺ៖ ចំនួនប្រជាពលរដ្ឋក្នុងសកលលោក៖ ការកែសម្រួលឆ្នាំ 2015 សំណៅ DVD ឆ្នាំ 2015 របស់ផ្នែកប្រជាជននៃនាយកដ្ឋានសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិ។
2. ទិន្នន័យថ្នាក់ជាតិស្តីពីការរៀបចំការរស់នៅរបស់កុមារ ដែលបានពីការអង្កេតប្រជាសាស្រ្តនិងសុខភាពកម្ពុជា ពុំមានភាពពេញលេញនោះឡើយ។ ទី 1 ទិន្នន័យទាំងនេះពុំត្រូវបានបែងចែកទៅតាមប្រភេទនៃការរស់នៅជាមួយគ្រួសារចិញ្ចឹម។ ទី 2 ទិន្នន័យទាំងនេះពុំបានផ្តល់ព័ត៌មានលំអិតអំពីកុមារដែលរស់នៅ ជាមួយឪពុកឬម្តាយតែម្នាក់ (ឧទាហរណ៍ ថាតើកុមារនេះមានឪពុកម្តាយចុងដែរឬទេ)។ ទំនាក់ទំនងបែបនេះផ្សេងទៀតក៏មានសារៈសំខាន់ ដើម្បីកំណត់រកកុមារដែលប្រឈមនឹងហានិភ័យផងដែរ។
3. សន្និសិទ Leiden ស្តីពីការអភិវឌ្ឍ និងការគាំពារកុមារ ដែលពុំមានឪពុកម្តាយនៅជាមួយជាអចិន្ត្រៃយ៍ "ការអភិវឌ្ឍ និងការគាំពារកុមារដែលត្រូវបានចិញ្ចឹមតាមមណ្ឌល" ទស្សនវិស័យស្តីពីការអភិវឌ្ឍកុមារ វ៉ុលទី 6 លេខ 2 ឆ្នាំ 2012 ទំព័រ 174-180 គំរូអន្តរាគមន៍ទាន់ពេលវេលា Bucharest "ការគាំពារកុមារកំព្រា កុមារដែលត្រូវបានគេបោះបង់ចោល និងកុមារដែលត្រូវបានគេធ្វើបាប" <http://www.crin.org/docs/PPT%20BEIP%20Group.pdf> Myers, John E. B. កិច្ចការពារកុមារនៅអាមេរិក៖ អតីតកាល បច្ចុប្បន្នកាល និងអនាគតកាល សារព័ត៌មាន Oxford University ទីក្រុងញូយ៉ក ឆ្នាំ 2006 ទំព័រទី 77 ដោយលោក Williamson, John និង Aaron Greenberg "គ្រួសារ មិនមែនមណ្ឌលកុមារកំព្រា" ឯកសារពិភាក្សានៃបណ្តាញលើកកម្ពស់ការគាំពារកុមារ ខែ វិច្ឆិកា ឆ្នាំ 2010។
4. ការអង្កេតប្រជាសាស្រ្ត និងសុខភាពកម្ពុជាឱ្យនិយមន័យកុមារដែលជាកូនចិញ្ចឹម ថាជាអ្នកមានអាយុក្រោម18ឆ្នាំ រស់នៅក្នុងគ្រួសារ ដែលពុំមានវត្តមានម្តាយ ឬឪពុកបង្កើតរបស់ពួកគេ។ "ការថែទាំដោយគ្រួសារធម៌" ដែលត្រូវបានកំណត់និយមន័យនៅក្នុងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ ស្តីពីការផ្តល់ការថែទាំជំនួសដល់កុមារ គឺជាជម្រើសដាក់កុមារឱ្យទទួលបានការថែទាំតាមគ្រួសារ នៅក្នុងករណីដែលកុមារត្រូវបានរកឃើញថាពុំមានគ្រួសារបង្កើត ឬបណ្តាញសាច់ញាតិ ហើយកុមារត្រូវបានយកទៅដាក់នៅតាមគ្រួសារធម៌បែបនេះ ដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីឱ្យពួកគេទទួលបានការថែទាំជំនួសក្នុងគ្រួសារណាមួយ ក្រៅតែពីគ្រួសារផ្ទាល់ខ្លួនរបស់កុមារ ដែលត្រូវបានជ្រើសរើស បញ្ជាក់ ឯកភាព និងត្រួតពិនិត្យមុននឹងផ្តល់ការថែទាំបែបនេះ។ ប្រភព៖ មហាសន្និបាតសហប្រជាជាតិឆ្នាំ 2009។
5. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចុះត្រួតពិនិត្យជារៀងរាល់ឆ្នាំ លើគ្រប់មណ្ឌលថែទាំកុមារទាំងអស់ ដែលត្រូវបានកំណត់ថាជាមណ្ឌលផ្តល់ការថែទាំ ដោយស្តង់ដាអប្បបរមាស្តីពីការថែទាំជំនួស សម្រាប់កុមារឆ្នាំ 2008។ ខណៈពេលដែល

## Photo Credits:

Cover: © UNICEF/UNI165020/Lovell
Pg 2: ©UNICEF Cambodia/2012/Bona Khoy
Pg 5: © UNICEF/UNI165048/Lovell
Pg 7: © UNICEF/UNI165034/Lovell
Pg 8: © UNICEF/FANI LLAURADO
Pg 10: © UNICEF/UNI165015/Lovell
Pg 12: © UNICEF/UN077339/Bona
Pg 14: © UNICEF/UNI180580/Galli
Pg 16: ©UNICEF/UN077811/Llaurado
Pg 17: ©UNICEF Cambodia/2016/Ream Rin
Pg 18: © UNICEF/UNI83131/Vink
Pg 20: © UNICEF/UNI83506/Noorani
Pg 22: © UNICEF Cambodia/2016/Patricia Chourio
Pg 24: © UNICEF Cambodia/2013/Luis Barreto
Pg 25 (top): © UNICEF/UNI82910/Vink
Pg 25 (bottom): © UNICEF Cambodia/2015/Antoine Raab
Pg 26: © UNICEF/UNI165133/Lovell
Pg 30: ©UNICEF Cambodia/2010/Nicolas Axelrod
Pg 31: © UNICEF/UNI82893/Vink
Pg 32: © UNICEF/UNI180578/Galli
Pg 33: © UNICEF Cambodia/2016/Patricia Chourio
Pg 34: © UNICEF/UNI82880/Vink
Pg 35: ©CCT Cambodia2016
Pg 39: © UNICEF/UNI82915/Vink

អធិការកិច្ចទាំងនេះ បានផ្តល់ឱ្យក្រសួងនូវព័ត៌មានដ៏មានតម្លៃ អំពីសុខមាលភាពរបស់កុមារដែលរស់នៅតាមមណ្ឌល អធិការកិច្ចទាំងនេះពុំបានផ្តល់ព័ត៌មានពេញលេញឡើយ ដោយសារតែការចុះអធិការកិច្ចទាំងនេះ គ្របដណ្តប់តែលើមណ្ឌលដែលត្រូវបានគេស្គាល់ជាផ្លូវការ ឬដែលមានអនុស្សារណៈជាមួយក្រសួងតែប៉ុណ្ណោះ។ គេសន្មតថាមានកន្លែងផ្តល់ការថែទាំជាច្រើនផ្សេងទៀតនៅកម្ពុជា ដែលក្នុងនោះមានកន្លែងថែទាំខ្លះស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួងផ្សេងទៀត។ ការកំណត់ទីតាំងមណ្ឌលថែទាំទាំងនេះ ត្រូវបានធ្វើឡើងដើម្បីបំពេញចន្លោះប្រហោងព័ត៌មាននេះ។

6. ខុសពីការសិក្សាកំណត់ទីតាំងមណ្ឌលថែទាំ ដែលមានគោលបំណងរាប់ទីកន្លែងផ្តល់ការថែទាំទាំងអស់ក្នុងប្រទេស ការសិក្សាដែលធ្វើឡើងក្នុងវិទ្យាស្ថានជាតិស្ថិតិ គឺផ្អែកទៅតាមសំណាក់គំរូបែបចៃដន្យ ដែលបន្ទាប់មកលទ្ធផលដែលបានរកឃើញ ត្រូវបានប្រើប្រាស់សម្រាប់ប៉ាន់ប្រមាណតួលេខសម្រាប់ប្រទេសទាំងមូល។ លទ្ធផលរកឃើញខុសគ្នារវាងការសិក្សាទាំង 2 នេះ ទំនងជាកើតឡើងដោយសារការប្រើនិយមន័យខុសគ្នាសម្រាប់មណ្ឌលថែទាំ និងការប្រើប្រាស់វិធីសាស្ត្រផ្សេងគ្នាសម្រាប់ធ្វើការអង្កេត។ និយមន័យដែលប្រើប្រាស់ដោយវិទ្យាស្ថានជាតិស្ថិតិ មានលក្ខណៈទូលំទូលាយជាងនិយមន័យដែលប្រើប្រាស់ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ការសិក្សាដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ ត្រូវបានប្រើប្រាស់សម្រាប់ករណីមួយចំនួននៅក្នុងរបាយការណ៍នេះ ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ពីចំណុចមួយចំនួន។

7. ត្រូវបានឱ្យនិយមន័យក្នុងរបាយការណ៍កំណត់ទីតាំងមណ្ឌលថែទាំកុមារថាជា៖ "ប្រភេទកន្លែងផ្តល់ការថែទាំដែលផ្តល់សេវាដល់កុមារគ្រប់ប្រភេទទាំងអស់ ដែលត្រូវបានគេបោះបង់ចោល ឬមិនអាចរស់នៅជាមួយឪពុកម្តាយ គ្រួសារបង្កើត ឬសាច់ញាតិក្នុងសហគមន៍របស់ពួកគេបាន ដែលនិយមន័យនេះមានលក្ខណៈសមស្របទៅតាមនិយមន័យស្តង់ដានៃមណ្ឌលថែទាំកុមារ ដែលត្រូវបានកំណត់នៅក្នុងបទដ្ឋានអប្បបរមា ស្តីពីការផ្តល់ការថែទាំជំនួសដល់កុមារ។ ជាទូទៅមណ្ឌលទាំងនេះផ្តល់ការថែទាំដល់កុមារជាច្រើននាក់ ក្នុងបរិយាកាសដែលត្រូវបានរៀបចំឡើង មិនមែនជាលក្ខណៈគ្រួសារ។" ប្រភព៖ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ 2017 ទំព័រទី 6។

8. ការសិក្សារបស់វិទ្យាស្ថានជាតិស្ថិតិបង្ហាញពីតួលេខកាន់តែខ្ពស់ទៅទៀត ដោយប៉ាន់ប្រមាណថាមានមណ្ឌលថែទាំកុមារចំនួន 1,658 កន្លែងនៅកម្ពុជា។ និយមន័យនេះសំដៅទៅលើកន្លែងផ្តល់ការថែទាំកុមារគ្រប់ប្រភេទទាំងអស់។

9. ផ្ទះសំចត និងកន្លែងស្នាក់នៅបណ្តោះអាសន្នសម្រាប់ស្ថានភាពអាសន្ន៖ ការថែទាំតាមមណ្ឌលក្នុងទម្រង់មួយបែបដែលកំណត់រយៈពេលស្នាក់នៅសម្រាប់កុមារ ដែលកំពុងស្ថិតនៅក្នុងដំណើរការរៀបចំផែនការឱ្យរស់នៅជាអចិន្ត្រៃយ៍ក្នុងគ្រួសារណាមួយ ឬសម្រាប់កុមារដែលគ្រួសារជួបប្រទះនឹងវិបត្តិស្រួចស្រាវ ដែលតម្រូវឱ្យកុមារទទួលបានការស្នាក់នៅបណ្តោះអាសន្ន ទម្រាំគ្រួសារមានស្ថេរភាពឡើងវិញ។ ខណៈពេលដែលគេអាចបែងចែកភាពខុសប្លែកគ្នាបន្តទៀតរវាង ផ្ទះសំចត និងកន្លែងស្នាក់នៅបណ្តោះអាសន្នសម្រាប់ស្ថានភាពបណ្តោះអាសន្ន របាយការណ៍នេះប្រើប្រាស់ពាក្យទាំង 2 នេះជាពាក្យតែមួយ។

ផ្ទះស្នាក់នៅជាក្រុម៖ កន្លែងផ្តល់ការថែទាំដល់កុមារ ក្នុងចំនួនមួយជាក់លាក់ ក្នុងបរិយាកាសដូចគ្នានឹងគ្រួសារដែរ ដោយមានការគ្រប់គ្រងពីអ្នកផ្តល់ការថែទាំមួយក្រុមតូច ដែលពុំមែនជាសាច់ញាតិរបស់កុមារ។ ជាធម្មតាត្រូវមានអ្នកផ្តល់ការថែទាំ ដែលត្រូវបានជួលឱ្យធ្វើការងារ និងបានឆ្លងកាត់ការបណ្តុះបណ្តាលត្រឹមត្រូវ ដើម្បីផ្តល់ការថែទាំ ដែលមិនពាក់ព័ន្ធជាមួយនឹងការថែទាំវេជ្ជសាស្ត្រ និងការគ្រប់គ្រងកុមាររយៈពេល 24 ម៉ោងក្នុង 1 ថ្ងៃ ក្នុងបរិយាកាសដែលមានការរៀបចំត្រឹមត្រូវ។

វត្តអារាម និងការផ្តល់ការថែទាំ ក្នុងអគារសាសនា៖ ការថែទាំដែលផ្តល់ដល់កុមារដោយព្រះសង្ឃ ដូនជី អាចារ្យ និងអ្នកកាន់សាសនាផ្សេងទៀត ដែលគិតគូពីតម្រូវការជាមូលដ្ឋានរបស់កុមារ ក្នុងវត្តអារាម និងកន្លែងប្រតិបត្តិជំនឿសាសនាដទៃទៀត។

សាលាដែលទទួលសិស្សឱ្យស្នាក់នៅ/ផ្ទះដែលទទួលសិស្សឱ្យស្នាក់នៅ៖ ផ្ទះសម្រាប់កុមារស្នាក់នៅក្នុងរយៈពេល 1 ត្រីមាស ឬច្រើនត្រីមាសនៅពេលពួកគេទៅទទួលការអប់រំឆ្ងាយពីផ្ទះ។ សាលារៀនដែលទទួលសិស្សឱ្យស្នាក់នៅត្រូវបានបញ្ចូលទៅក្នុងការសិក្សា កំណត់ពីទីតាំងមណ្ឌលថែទាំកុមារ ដោយសារតែមានការព្រួយបារម្ភថាសាលារៀនមួយចំនួនក៏ជាមណ្ឌលថែទាំកុមារដែរ។

10. ការសិក្សារបស់វិទ្យាស្ថានជាតិស្ថិតិបានប៉ាន់ប្រមាណថា មានកុមារអាយុក្រោម 18 ឆ្នាំ ចំនួន 48,775 នាក់ (ស្រី 43 ភាគរយ) កំពុងស្នាក់នៅតាមមណ្ឌលថែទាំនៅកម្ពុជា។

11. Browne, K., The Risk of Harm to Young Children in Institutional Care, Save the Children UK and Better Care Network, London, 2009; Gudbrandsson, B., 'Rights of Children at Risk and in Care,' prepared for the Conference of European Ministers Responsible for Family Affairs, Lisbon, 16–17 May 2006

12. សេណារីយ៉ូ ធ្វើចំណោលដែលបង្ហាញក្នុងរូបភាព 3.5 ត្រូវបានគណនាតាមរយៈការអង្កេតមើលប្រវ៉ាឡង់នៃការចុះសំបុត្រកំណើតនៅក្នុងឆ្នាំកន្លងទៅនេះ និងការគណនាប្រេវ៉ាឡង់ដែលអាចកើតមាននាពេលអនាគត ប្រសិនបើការផ្លាស់ប្តូរបន្តកើតឡើងក្នុងអត្រាដូចគ្នានឹងអ្វី ដែលត្រូវបានអង្កេតឃើញកន្លងមក។ បន្ទាប់មកមានការគណនាអត្រាផ្លាស់ប្តូរជាមធ្យមប្រចាំឆ្នាំ (AARC) ផ្អែកទៅតាមកម្រិតទាំងនេះនៅពេលវេលាខុសៗគ្នា។ អត្រា (AARC) ត្រូវបានគណនាសម្រាប់រយៈពេល 4 ឆ្នាំចុងក្រោយ ពីឆ្នាំ 2010 ដល់ឆ្នាំ 2014 ព្រោះថានេះគឺជារយៈពេលដែលអត្រាចុះសំបុត្រកំណើតមានការកើនឡើង។ ការធ្វើចំណោលបង្ហាញពីការបន្តនិន្នាការដែលអង្កេតឃើញកន្លងមក ដោយប្រើប្រាស់ (AARC) ដែលបានអង្កេតឃើញក្នុងរយៈពេល 4 ឆ្នាំនេះ ដើម្បីធ្វើចំណោលកម្រិតនៃការចុះសំបុត្រកំណើតនៅពេលអនាគត។ តួលេខនេះគ្រាន់តែជាតួលេខសម្រាប់បង្ហាញតែប៉ុណ្ណោះ ពោលគឺការបង្ហាញពីសេណារីយ៉ូ ដែលអាចនឹងកើតឡើងនាពេលអនាគត ផ្អែកទៅតាមភស្តុតាងដែលមានគិតរហូតមកដល់បច្ចុប្បន្ននេះ។ អត្រានៃការប្រែប្រួលអាចបន្តផ្លាស់ប្តូរលឿន ឬយឺតជាងសេណារីយ៉ូនៃការធ្វើចំណោលនេះ។ លក្ខណៈប្រជាសាស្ត្ររបស់ប្រទេសនេះ ក៏អាចប្រែប្រួលខុសពីការរំពឹងទុកផងដែរ ជាពិសេសនៅក្នុងករណីដែលមានជម្លោះ ឬស្ថានភាពអាសន្នកើតមានឡើង។

13. សេណារីយ៉ូនៃការធ្វើចំណោល ដែលត្រូវបានបង្ហាញក្នុងរូបភាព 4.4 ត្រូវបានគណនាតាមរយៈការអង្កេតមើលនិន្នាការនៃប្រេវ៉ាឡង់អាពាហ៍ពិពាហ៍វ័យកុមារ ក្នុងឆ្នាំកន្លងទៅ និងធ្វើការគណនាប្រេវ៉ាឡង់ដែលអាចមាននាពេលអនាគត ប្រសិនបើការផ្លាស់ប្តូរបន្តកើតឡើងក្នុងអត្រាដូចគ្នានេះ ឬក្នុងអត្រាមួយលឿនជាងអត្រាដែលត្រូវបានអង្កេតឃើញកន្លងមក។ អត្រាដែលត្រូវបានអង្កេតឃើញ ដែលជាមូលដ្ឋានសម្រាប់ធ្វើចំណោលនេះ ពឹងអាស្រ័យលើការវាស់វែងពីកម្រិតអាពាហ៍ពិពាហ៍វ័យកុមារ ក្នុងចំណោមក្រុមស្ត្រីដែលត្រូវបានចងជាចង្កោមអាយុចន្លោះពីគ្នា៥ឆ្នាំ។ កម្រិតនៃអាពាហ៍ពិពាហ៍វ័យកុមារកាលពីប្រមាណទសវត្សរ៍មុន ត្រូវបានកំណត់តាមរយៈការវាស់វែងអាយុរៀបអាពាហ៍ពិពាហ៍របស់ស្ត្រី ដែលមានវ័យច្រើននាពេលបច្ចុប្បន្ននេះ ខណៈពេលដែលកម្រិតនៃអាពាហ៍ពិពាហ៍វ័យកុមារកាលពីពេលថ្មីៗនេះ ត្រូវបានកំណត់តាមរយៈអាយុរៀបអាពាហ៍ពិពាហ៍របស់ស្ត្រីដែលមានវ័យក្មេងជាង។ ផ្អែកទៅតាមកម្រិតកម្រិតទាំងនេះនៅពេលវេលាខុសៗគ្នាការគណនាអត្រា AARC ត្រូវបានធ្វើឡើង។ អត្រា AARC ត្រូវបានគណនាសម្រាប់រយៈពេល 25 ឆ្នាំ ដែលឆ្លុះបញ្ចាំងពីរយៈពេលទាំងមូលដែលបានពីការវាស់វែងស្តង់ដា។ អត្រា AARC ក៏ត្រូវបានគណនាសម្រាប់រយៈពេល 10 ឆ្នាំចុងក្រោយផងដែល សម្រាប់បង្ហាញថាតើវឌ្ឍនភាពបានសម្រេចលឿនជាងមុនដែរឬទេក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ការធ្វើចំណោលដែលបង្ហាញពីការបន្តនិន្នាការដែលអង្កេតឃើញ ប្រើប្រាស់អត្រា AARC ដែលអង្កេតឃើញ ដើម្បីធ្វើចំណោលកម្រិតទៅអនាគត។ ការធ្វើចំណោលដែលបង្ហាញពីការកើនឡើងលឿនបែបនេះប្រើប្រាស់អត្រា AARC ដែលអង្កេតឃើញដល់ទៅ 2 ដង។ តួលេខនេះគ្រាន់តែជាតួលេខសម្រាប់បង្ហាញតែប៉ុណ្ណោះ ពោលគឺការបង្ហាញពីសេណារីយ៉ូ ដែលអាចនឹងកើតឡើងនាពេលអនាគត ផ្អែកទៅតាមភស្តុតាងដែលមានគិតរហូតមកដល់បច្ចុប្បន្ននេះ។ អត្រានៃការប្រែប្រួលអាចបន្តផ្លាស់ប្តូរលឿន ឬយឺតជាងសេណារីយ៉ូនៃការធ្វើចំណោលនេះ។ លក្ខណៈប្រជាសាស្ត្ររបស់ប្រទេសនេះ ក៏អាចប្រែប្រួលខុសពីការរំពឹងទុកផងដែរ ជាពិសេសនៅក្នុងករណីដែលមានជម្លោះ ឬស្ថានភាពអាសន្នកើតមានឡើង។

14. Fall, C. H., et al., ‘Association between maternal age at childbirth and child and adult outcomes in the offspring: A prospective study in five low-income and middle-income countries (COHORTS collaboration)’, Lancet Global Health, vol. 3, no. 7, 2015, pp.e366-e377, <http://dx.doi.org/10.1016/S2214-109X(15)00038-8>

15. សេណារីយ៉ូនៃការធ្វើចំណោលដែលត្រូវបានបង្ហាញក្នុងរូបភាព 5.5 ត្រូវបានគណនា តាមរយៈការអង្កេតមើលនិន្នាការនៃប្រវ៉ាំឡង់នៃការឆាប់មានកូន ក្នុងឆ្នាំកន្លងទៅនេះ និងការគណនាប្រវ៉ាំឡង់ដែលអាចមាននាពេលអនាគត ប្រសិនបើការផ្លាស់ប្តូរនៅបន្តកើតឡើងក្នុងអត្រាដូចគ្នានេះ ឬក្នុងអត្រាលឿនជាងអត្រាដែលអង្កេតឃើញកន្លងមក។ និន្នាការដែលត្រូវបានអង្កេតឃើញ ដែលប្រើប្រាស់ជាគោលសម្រាប់គណនាចំណោលពឹងអាស្រ័យលើការវាស់វែងកម្រិតនៃការឆាប់មានកូន ក្នុងចំណោមក្រុមស្ត្រីដែលត្រូវបានចងជាចង្កោមអាយុចន្លោះពីគ្នា៥ឆ្នាំ។ កម្រិតនៃការឆាប់មានកូនកាលពីប៉ុន្មានទសវត្សរ៍មុន ត្រូវបានប្រមូលតាមរយៈការវាស់វែងអាយុសម្រាលកូនដំបូង ក្នុងចំណោមស្ត្រីចំណាស់ ខណៈពេលដែលអត្រាថ្មីៗកន្លងទៅនេះ ត្រូវបានគណនាដោយប្រើប្រាស់អាយុសម្រាលកូនដំបូងក្នុងចំណោមស្ត្រីដែលមានវ័យក្មេងជាង។ អត្រា AARC ត្រូវបានគណនាផ្អែកទៅតាមកម្រិតទាំងនេះនៅពេលវេលាខុសៗគ្នា។ អត្រា AARC ត្រូវបានគណនាសម្រាប់រយៈពេល 15 ឆ្នាំ ពី 1999 ដល់ 2014 ដោយសារតែនេះគឺជារយៈពេលដែលកម្រិតនៃការឆាប់មានកូនមានការថយចុះ។ ការធ្វើចំណោលដែលបង្ហាញការបន្តនិន្នាការ អង្កេតឃើញ ប្រើប្រាស់អត្រា AARC ដែលបានអង្កេតឃើញ ដើម្បីព្យាករណ៍ពីកម្រិតទៅអនាគត។ ការព្យាករណ៍ដែលបង្ហាញពីការកើនឡើងលឿនបែបនេះ បានប្រើប្រាស់អត្រា AARC ដែលបានអង្កេតឃើញដល់ទៅ 2 ដង។ តួលេខនេះគ្រាន់តែជាតួលេខសម្រាប់បង្ហាញតែប៉ុណ្ណោះ ពោលគឺការបង្ហាញពីសេណារីយ៉ូ ដែលអាចនឹងកើតឡើងនាពេលអនាគត ផ្អែកទៅតាមភស្តុតាងដែលមានគិតរហូតមកដល់បច្ចុប្បន្ននេះ។ អត្រានៃការប្រែប្រួលអាចបន្តផ្លាស់ប្តូរលឿន ឬយឺតជាងសេណារីយ៉ូនៃការធ្វើចំណោលនេះ។ លក្ខណៈប្រជាសាស្ត្ររបស់ប្រទេសនេះ ក៏អាចប្រែប្រួលខុសពីការរំពឹងទុកផងដែរ ជាពិសេសនៅក្នុងករណីដែលមានជម្លោះ ឬស្ថានភាពអាសន្នកើតមានឡើង។

16. ការប៉ាន់ប្រមាណសុខភាពសកលឆ្នាំ 2015៖ ករណីស្លាប់បែងចែកទៅតាមមូលហេតុ អាយុ ភេទ បែងចែកទៅតាមប្រទេស និងបែងចែកតាមតំបន់ ឆ្នាំ 2000-2015 ដោយអង្គការសុខភាពពិភពលោក ទីក្រុងហ្សឺណែវ ឆ្នាំ 2016 គណនាសារជាថ្មីដោយយូនីសេហ្វ។

17. ការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជាឆ្នាំ 2013

18. ខណៈពេលដែលការអង្កេតប្រជាសាស្ត្រ និងសុខភាពកាលពីឆ្នាំ 2014 ក៏រាយការណ៍ខ្លះផងដែរពីអំពើហិង្សាលើកុមារ (ក្នុងចំណោមក្មេងស្រីជំទង់អាយុពី 15 ដល់ 19 ឆ្នាំ) របាយការណ៍នេះប្រើប្រាស់ទិន្នន័យដែលបានពីការសិក្សាស្រាវជ្រាវស្តីពីអំពីហិង្សាលើកុមារក្នុងប្រទេសកម្ពុជាឆ្នាំ 2013 ដោយសារតែនេះជាការសិក្សាដែលផ្តោតលើអំពើហិង្សា ដូច្នេះវាឆ្លុះបញ្ចាំងពីលក្ខណៈស្មុគស្មាញនៃអំពើហិង្សាបានល្អជាង។

19. កាន់តែជាក់លាក់ជាងនេះទៅទៀត មានអំពើហិង្សា 3 ប្រភេទដែលត្រូវបានវាស់វែង៖ អំពើហិង្សា ផ្លូវកាយដែលត្រូវបានកំណត់និយមន័យថា ជាការវាយនឹងដៃ ទាត់ វាយនឹងរំពាត់ ឬវាយនឹងវត្ថុអ្វីមួយ បន្ទាប់មកគឺការប្រើប្រាស់ ឬការគម្រាមប្រើប្រាស់កាំបិទ ឬអាវុធផ្សេងទៀត ការច្របាច់ក ការខ្ទប់ដង្ហើម ព្យាយាមធ្វើឱ្យលង់ទឹក ឬដុតរលាកដោយចេតនា ទះកំផ្លៀង និងរុញ, អំពើហិង្សាផ្លូវចិត្តរួមមានការសើចចំអក ឬការមាក់ងាយការប្រាប់ថាពុំមានអ្នកស្រលាញ់ ឬមិនសមនឹងទទួលបានការស្រលាញ់ ការត្រូវបានប្រាប់ដោយមនុស្សពេញវ័យថាមិនចង់ឱ្យកើត ឬចង់ឱ្យស្លាប់ ហើយអំពើហិង្សាផ្លូវភេទត្រូវបានឱ្យនិយមន័យថាជាការប៉ះពាល់ ដែលគេមិនចង់បានជាលក្ខណៈផ្លូវភេទ ការប៉ុនប៉ងរួមភេទដោយគេមិនចង់បាន ការបង្ខំឲ្យរួមភេទ និង ការដាក់សម្ពាធផ្លូវភេទ។

20. ការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារនៅក្នុងប្រទេសកម្ពុជា សួរសំណួរអំពីអំពើហិង្សាផ្លូវចិត្ត ដែលប្រព្រឹត្តដោយឪពុកម្តាយ អ្នកផ្តល់ការថែទាំ ឬសមាជិកគ្រួសារផ្សេងទៀតតែប៉ុណ្ណោះ។ ការអង្កេតនេះពុំបានបញ្ចូលការប្រព្រឹត្តដោយសមាជិកសហគមន៍ឡើយ។

21. Wolfe, D. A., et al. ‘The Effects of Children’s Exposure to Domestic Violence: A meta-analysis and critique’, Clinical Child and Family Psychology Review, vol. 6, no. 3, pp. 171–187, 2003; Levendosky, A. A., and S. A. Graham-Bermann, ‘Parenting in Battered Women: The effects of domestic violence on women and their children’, Journal of Family Violence, vol. 16, no. 2, pp. 171–192, 2001.

22. ចំណុចនេះសំដៅលើកូនរបស់ស្ត្រី ដែលធ្លាប់រៀបការ ឬធ្លាប់រស់នៅជាមួយដៃគូ។

23. អ្នកឆ្លើយតបត្រូវបានសួរថាតើពួកគេចាត់ទុកថាការវាយដំប្រពន្ធ ឬដៃគូពីប្តី ឬដៃគូ ថាជាទង្វើសមហេតុសមផលដោយសារមូលហេតុយ៉ាងហោចណាស់មួយ ក្នុងចំណោមមូលហេតុ 6 ខាងក្រោមដែរឬទេ៖ ប្រសិនបើនាងធ្វើឱ្យម្ហូបអាហារខ្លោច តមាត់ជាមួយគាត់ ទៅក្រៅដោយមិនប្រាប់គាត់ ទុកកូនចោល បដិសេធមិនព្រមរួមភេទជាមួយគាត់ ឬឱ្យគាត់ប្រើប្រាស់ស្រោមអនាម័យ។

24. ពិធីសារទប់ស្កាត់បង្ក្រាប និងផ្តន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (2000)។

25. ECPAT, 2011។

26. ប្រេវ៉ាំឡង់ក្នុងចំណោមកុមារអាយុ 15 ឆ្នាំចុះក្រោម តិចជាង 1 ភាគរយ, អនីតិជនអាយុ 16-17 ឆ្នាំ 7 ភាគរយ។ ប្រភព៖ បេសកកម្មយុត្តិធម៌អន្តរជាតិ 2015។

27. ប្រេវ៉ាំឡង់ក្នុងចំណោមកុមារអាយុ 15 ឆ្នាំចុះក្រោម តិចជាង 1 ភាគរយ, អនីតិជនអាយុ 16-17 ឆ្នាំ 2 ភាគរយ។ ប្រភព៖ បេសកកម្មយុត្តិធម៌អន្តរជាតិ 2015។

28. របាយការណ៍ស្តីពីការជួញដូរមនុស្សរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិកឆ្នាំ 2001 ដែលត្រូវបានលើកឡើងក្នុងរបាយការណ៍នៃបេសកកម្មយុត្តិធម៌អន្តរជាតិ ឆ្នាំ 2015។

29. របាយការណ៍ស្តីពីលទ្ធផលរកឃើញអំពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារឆ្នាំ 2014 ដោយការិយាល័យពលកម្មកុមារ ពលកម្មដោយបង្ខំ និងជួញដូរមនុស្ស ផ្នែកកិច្ចការពលកម្មអន្តរជាតិ ក្រសួងការងារសហរដ្ឋអាមេរិក ទីក្រុងវ៉ាស៊ីនតោនឆ្នាំ 2014 <https://www.dol.gov/ilab/reports/child-labor/findings/2014TDA/2014TDA.pdf>

30. ការសិក្សាអំពីប្រទេសកម្ពុជា សន្ទស្សន៍ទាសភាពសកល 2016 <www.globalslaveryindex.org/country/cambodia/>

31. អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ឆ្នាំ 2015។

32. កម្មវិធីអេដស៍សហប្រជាជាតិ 2014 ការប៉ាន់ប្រមាណពីមេរោគអេដស៍ និងជម្ងឺអេដស៍ ខែកក្កដា ឆ្នាំ 2015។

33. អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ឆ្នាំ 2015។

34. សូមមើល៖ <www.ilo.org/ipec/facts/lang--en/index.htm>

35. បើតាមការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជាឆ្នាំ 2014 ប្រជាជនដែលមានសកម្មភាពសេដ្ឋកិច្ច រួមមានមនុស្សទាំងអស់ដែលផ្គត់ផ្គង់កម្លាំងពលកម្មសម្រាប់ការផលិតទំនិញ និងសេវាសេដ្ឋកិច្ច ដូចដែលត្រូវបានកំណត់និយមន័យដោយប្រព័ន្ធគណនេយ្យជាតិរបស់សហរដ្ឋអាមេរិក យ៉ាងហោចណាស់ 1 ម៉ោងក្នុងសប្តាហ៍មុនពេលដែលធ្វើការអង្កេតនេះ។

36. ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា 2014 ឆ្នាំ 2015។

37. ការអង្កេត ដែលធ្វើឡើងដោយអង្គការពលកម្មអន្តរជាតិ/វិទ្យាស្ថានជាតិស្ថិតិ ផ្តល់និយមន័យពាក្យថា "កុមារដែលកំពុងធ្វើការងារ ឬកុមារដែលមានសកម្មភាពសេដ្ឋកិច្ច" ថារួមមានកុមារដែលកំពុងធ្វើការងារប្រកបដោយគ្រោះថ្នាក់ និងកុមារដែលកំពុងចូលរួមក្នុងពលកម្មកុមារ ក្នុងទម្រង់ផ្សេងទៀត ក៏ដូចជាកុមារដែលកំពុងធ្វើការងារ ប៉ុន្តែមិនមែនជាពលករកុមារ។ ដូច្នេះពលករកុមារគឺជាអនុក្រុមនៃកុមារដែលកំពុងធ្វើការងារ ឬកុមារដែលកំពុងមានសកម្មភាពសេដ្ឋកិច្ច។ និយមន័យពលកម្មកុមារដែលប្រើប្រាស់ក្នុងការអង្កេតពលកម្មកុមារឆ្នាំ 2012 ដែលធ្វើឡើងដោយអង្គការពលកម្មអន្តរជាតិ/វិទ្យាស្ថានជាតិស្ថិតិ រួមមានកុមារអាយុ 5 ទៅ 11 ឆ្នាំ ដែលកំពុងចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចចាប់ពីមួយម៉ោងឡើងទៅ ក្នុងសប្តាហ៍កន្លងទៅ, កុមារអាយុ 12-14 ឆ្នាំ ដែលធ្វើចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច ដែលអនុញ្ញាតឱ្យបាន (ពុំមានគ្រោះថ្នាក់) រយៈពេលជាង 12

ម៉ោងក្នុង 1 សប្តាហ៍កន្លងទៅ, កុមារអាយុ 12-14 ឆ្នាំ ដែលធ្វើការងារតិចជាង 12 ម៉ោងក្នុងសប្តាហ៍កន្លងទៅ ក្នុងឧស្សាហកម្ម និងការងារ ដែលចាត់ទុកថាគ្រោះថ្នាក់, កុមារអាយុ 15-17 ឆ្នាំ ដែលចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចលើសពី 8 ម៉ោងក្នុងសប្តាហ៍កន្លងទៅ និងកុមារអាយុ 5-17 ឆ្នាំ ដែលធ្វើការងារក្នុងឧស្សាហកម្ម និងការងារដែលចាត់ទុកថាគ្រោះថ្នាក់ ក្រោម 48 ម៉ោង ក្នុងសប្តាហ៍កន្លងទៅ។

38. នេះរាប់បញ្ចូលសកម្មភាពនានាដូចជា ការចម្អិនអាហារ ឬការសំអាត ការមើលកូន ការថែទាំចាស់ជរា និងការធ្វើកិច្ចការដទៃទៀត សម្រាប់គ្រួសារណាមួយដែលមិនមែនជាគ្រួសារខ្លួនឯង។
39. ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា 2014, ឆ្នាំ 2015។
40. វិទ្យាស្ថានជាតិស្ថិតិ និងសកលវិទ្យាល័យកូឡុំប៉ៀ ឆ្នាំ 2016។
41. ធនាគារអភិវឌ្ឍន៍អាស៊ី ផ្អែកតាមបន្ទាត់ភាពក្រីក្រជាតិ ទិន្នន័យឆ្នាំ 2014 ដែលបានពីការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា។
42. ធនាគារអភិវឌ្ឍន៍អាស៊ី 2014។
43. ធនាគារអភិវឌ្ឍន៍អាស៊ី 2014។
44. កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ 2006 ក្នុងក្របខ័ណ្ឌក្រសួងផែនការ គឺជាផ្នែកមួយនៃការបន្ត កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការកាត់បន្ថយភាពក្រីក្រ និងគាំទ្រដល់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចទូទាំងប្រទេសនេះ។ ការគ្រប់គ្រង និងការអនុវត្តកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងការប្រើប្រាស់ទិន្នន័យអំពីគ្រួសារក្រីក្រ ត្រូវបានធ្វើឡើងតាមរយៈអនុក្រឹត្យលេខ 291 ស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលរដ្ឋាភិបាលបានប្រកាសដាក់ឱ្យអនុវត្តកាលពីខែ ធ្នូ ឆ្នាំ 2011 (<www.idpoor.gov.kh/en/home>)។ ពន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ធ្វើការចាត់ចំណាត់ថ្នាក់គ្រួសារទៅតាម 3 ប្រភេទ៖ ក្រ 1 (ក្រខ្សត់ខ្លាំង), ក្រ 2 (ក្រ) និងផ្សេងទៀត (មិនក្រ)។ កម្មវិធីនេះប្រើប្រាស់សំណួរស្តង់ដា ដែលមានសូចនាករតំណាងឱ្យភាពក្រីក្រមួយចំនួន ដែលបានទទួលការឯកភាពពីក្រុមការងារថ្នាក់ជាតិ កំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលភាគច្រើនសូចនាករទាំងនេះផ្អែកទៅតាមទ្រព្យសម្បត្តិ ដែលគេងាយមើលឃើញ និងងាយផ្ទៀតផ្ទាត់ដឹង ប៉ុន្តែក៏មានបញ្ចូលបញ្ហាផ្សេងទៀតជាច្រើនដូចជា អត្រានៃអ្នកក្នុងបន្ទុក ការចូលរៀន វិបត្តិ និងសមាសភាពក្នុងគ្រួសារផងដែរ។ សមាជិកក្រុមតំណាងភូមិ ជាអ្នកធ្វើការសម្ភាសន៍ ដោយសារតែការដឹងពីមូលដ្ឋានរបស់ពួកគេ ធ្វើឱ្យគេងាយស្រួលធ្វើការផ្ទៀតផ្ទាត់ ថាតើអ្នកឆ្លើយតបរាយការណ៍ពីស្ថានភាពរបស់ពួកគេបានត្រឹមត្រូវដែរឬទេ និងធ្វើការវាយតម្លៃកាលៈទេសៈពិសេសរបស់គ្រួសារទាំងនេះ។ ទោះបីជាកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រផ្តោតតែលើតំបន់ជនបទក៏ដោយ ការអនុវត្តកម្មវិធីនៅតំបន់ប្រជុំជន ត្រូវបានចាប់ផ្តើមដោយក្រសួងផែនការនៅចុងឆ្នាំ២០១៦។ ការប្រមូលទិន្នន័យនៅតំបន់ប្រជុំជននៅក្នុងខេត្ត៩កំពុងតែបន្តធ្វើ។ ខណៈពេលដែលព័ត៌មានដែលបានពីកម្មវិធីនេះ ពុំបានផ្តល់រូបភាពពេញលេញពីភាពក្រីក្រនៅកម្ពុជា ប្រជាជនកម្ពុជាភាគច្រើនលើសលុបរស់នៅតាមតំបន់ជនបទ (78 ភាគរយ) បើតាមការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា ឆ្នាំ 2015។ ដោយសារតែភាពក្រីក្រច្រើនតែប្រមូលផ្តុំខ្លាំងនៅតំបន់ជនបទ ទិន្នន័យគ្រួសារក្រីក្រគឺជាសូចនាករដ៏មានប្រយោជន៍ ដើម្បីប៉ាន់ប្រមាណពីចំនួនគ្រួសារក្រីក្រ និងប្រជាជនដែលរស់នៅក្នុងភាពក្រីក្រនៅកម្ពុជា។
45. Jones L., et al., ‘Prevalence and Risk of Violence against Children with Disabilities: A systematic review and meta-analysis of observational studies’, The Lancet, vol. 380, no. 9845, pp. 899–907, 2012។
46. Jones, et al., 2012; Sullivan, P. M. and Knutson J. F., ‘Maltreatment and Disabilities: A population-based epidemiological study’, Child Abuse & Neglect, vol. 24, no. 10, pp. 1257–1273, 2000។
47. អាជ្ញាធរមីនកម្ពុជា ឆ្នាំ 2016។
48. "របាយការណ៍ពិនិត្យឡើងវិញជាសកលតាមកាលកំណត់ លើសិទ្ធិកុមារនៅកម្ពុជា (2009-2013)៖ ការរួមចំណែកចំពោះយន្តការពិនិត្យឡើងវិញជាសកលតាមកាលកំណត់" រៀបចំដោយសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលខាងសិទ្ធិកុមារ សមាជប្រជុំទី 18 នៃក្រុមការងារពិនិត្យឡើងវិញជាសកលតាមកាលកំណត់ ប្រទេសកម្ពុជា ឆ្នាំ 2014។
49. សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលខាងសិទ្ធិកុមារ ឆ្នាំ 2014។
50. Wulczyn, Fred, et al., ‘Adapting a Systems Approach to Child Protection: Key concepts and considerations’, UNICEF Working Paper, 2010។
51. សៀវភៅថវិកាឆ្នាំ 2009-2016 រៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រទេសកម្ពុជា។
52. បើតាមសហព័ន្ធអន្តរជាតិនៃភ្នាក់ងារសង្គមកិច្ច "ការងារសង្គមកិច្ច គឺជាអាជីពអនុវត្តជាក់ស្តែង និងជាមុខវិជ្ជាសិក្សាមួយ ដែលជម្រុញឱ្យមានការផ្លាស់ប្តូរ និងមានការអភិវឌ្ឍក្នុងសង្គម ភាពចុះសម្រុងក្នុងសង្គម និងផ្តល់សិទ្ធិអំណាច សេរីភាពដល់ប្រជាពលរដ្ឋ។ គោលការណ៍យុត្តិធម៌សង្គម សិទ្ធិមនុស្ស ការទទួលខុសត្រូវរួម និងការគោរពភាពចម្រុះ គឺជាមូលដ្ឋានគ្រឹះនៃការងារសង្គម។ ដោយប្រើប្រាស់ទ្រឹស្តី ស្តីពីការងារសង្គម វិទ្យាសាស្ត្រសង្គម មនុស្សជាតិ និងចំណេះដឹងពីជនជាតិដើមភាគតិច ការងារសង្គម ជម្រុញឱ្យមានការចូលរួមពីប្រជាពលរដ្ឋ និងស្ថាប័ន ក្នុងការដោះស្រាយបញ្ហាប្រឈមក្នុងជីវិត និងកែលំអសុខមាលភាពរបស់ប្រជាពលរដ្ឋ។ និយមន័យខាងលើអាចកែសម្រួលនៅថ្នាក់ជាតិ និង/ឬថ្នាក់តំបន់" (<http://ifsw.org/get-involved/global-definition-of-social-work/>)។ ភ្នាក់ងារសង្គមកិច្ចអាជីពត្រូវមានសញ្ញាបត្រពាក់ព័ន្ធ ដូចជា សញ្ញាបត្រខាងសិក្សាសង្គមបន្ថែមពីលើបទពិសោធន៍ការងារជាក់ស្តែង។ "វិជ្ជាជីវៈសង្គមកិច្ចអាចមិនមែនត្រឹមតែជាសកម្មភាពសប្បុរសធម៌តែប៉ុណ្ណោះទេ ឬគ្រាន់តែជាការមានបំណង ប៉ុន្តែជាសកម្មភាព និងអន្តរាគមន៍ដែលប្រើប្រាស់ចំណេះដឹង និងការស្រាវជ្រាវជាមូលដ្ឋាន។ នេះគូសបញ្ជាក់ពីភាពចាំបាច់ ដើម្បីឱ្យមានការបណ្តុះបណ្តាល និងការកសាងសមត្ថភាពឱ្យបានគ្រប់គ្រាន់ ដើម្បីធ្វើការងារសង្គមប្រកបដោយលក្ខណៈវិជ្ជាជីវៈ" (Harachi, 2014)។
53. ចំនួនភ្នាក់ងារសុខមាលភាពសង្គមរបស់រដ្ឋាភិបាលសម្រាប់កុមារ យកតាមបញ្ជីឈ្មោះមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលត្រូវបានប្រមូលចងក្រងដោយរបាយការណ៍ "ការពិនិត្យមុខងារក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា" ដែលធ្វើឡើងក្នុងឆ្នាំ 2014 ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ការពិនិត្យឡើងវិញនេះ បានរកឃើញថាមានមន្ត្រីចំនួន 1,551 នាក់ ធ្វើការងារឱ្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (534 នាក់នៅថ្នាក់ជាតិ/ថ្នាក់ក្រសួង 678 នាក់នៅថ្នាក់ក្រោមជាតិ/មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង 339 នាក់នៅតាមការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា)។ ដោយសារតែការពុំមានភ្នាក់ងារសុខមាលភាពសង្គមសម្រាប់កុមារ និងការបំពេញមុខងារត្រួតគ្នា ជាពិសេសនៅថ្នាក់ក្រោមជាតិ របាយការណ៍នេះបានធ្វើការគណនាចំនួនភ្នាក់ងារសុខមាលភាពសង្គមសម្រាប់កុមារ ផ្អែកតាមចំនួនមន្ត្រីដែលបំពេញមុខងារដែលគ្របដណ្តប់ទូទៅ ឬជាក់លាក់លើសុខមាលភាពរបស់កុមារ (មិនរាប់បញ្ចូលមុខតំណែងរដ្ឋបាល និងអ្នកដែលធ្វើការងារពាក់ព័ន្ធជាមួយនឹងចាស់ជរា និងប្រាក់សោធននិវត្តន៍ឡើយ)។ ដូច្នេះមានភ្នាក់ងារសុខមាលភាពសង្គមសម្រាប់កុមារចំនួន 917 នាក់ នៅកម្ពុជាឆ្នាំ 2012 (291 នាក់នៅថ្នាក់ជាតិ/កម្រិតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា 287 នាក់ នៅថ្នាក់ក្រោមជាតិ/កម្រិតមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង 339 នាក់នៅកម្រិតការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា)។

# ឧបសម្ព័ន្ធទិន្នន័យ

| | | | |
|---|---|---|---|
| **ការចុះសំបុត្រកំណើត** | | | |
| ភាគរយនៃកុមារអាយុក្រោម 5 ឆ្នាំ ដែលត្រូវបានចុះសំបុត្រកំណើត នៅពេលដែលមានការធ្វើអង្កេត | | 73 | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ 2014 |
| ភាគរយនៃកុមារអាយុក្រោម 5 ឆ្នាំ ដែលមានសំបុត្របញ្ជាក់កំណើត | | 64 | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ 2014 |
| **កុមារដែលមិនរស់នៅជាមួយឪពុកម្តាយបង្កើតរបស់ខ្លួន** | | | |
| ភាគរយនៃកុមារអាយុក្រោម 18 ឆ្នាំ ដែលរស់នៅជាមួយឪពុក ឬម្តាយបង្កើតយ៉ាងហោចណាស់ម្នាក់ | | 89 | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ 2014 |
| ភាគរយនៃកុមារអាយុក្រោម 18 ឆ្នាំ មិនរស់នៅជាមួយឪពុកម្តាយបង្កើតរបស់ខ្លួន បើទោះបីជាឪពុកម្តាយយ៉ាងហោចណាស់ម្នាក់នៅរស់ក៏ដោយ | | 10 | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ 2014 |
| ភាគរយនៃកុមារអាយុក្រោម 18 ឆ្នាំ ដែលបានបាត់បង់ទាំងឪពុកទាំងម្តាយ | | 0.7 | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ 2014 |
| ភាគរយនៃកុមារអាយុក្រោម 18 ឆ្នាំ ដែលបានបាត់បង់ឪពុកឬម្តាយ | | 5 | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ 2014 |
| ភាគរយនៃកុមារអាយុក្រោម 18 ឆ្នាំ ដែលបានបាត់បង់ឪពុក | | 5 | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ 2014 |
| ភាគរយនៃកុមារអាយុក្រោម 18 ឆ្នាំ ដែលបានបាត់បង់ម្តាយ | | 2 | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ 2014 |
| ភាគរយនៃគ្រួសារដែលមានកូនចិញ្ចឹម | | 13 | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ 2014 |
| ចំនួនមណ្ឌលថែទាំកុមារ ( ទាំងមណ្ឌលរបស់រដ្ឋ និងមណ្ឌលដែលមិនមែនជារបស់រដ្ឋ ) | | 406 | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ 2017 |
| ចំនួនកុមារដែលរស់នៅតាមមណ្ឌលថែទាំ | | 16570 | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ 2017 |
| ចំនួនក្មេងជំទង់អាយុ 13-17 ឆ្នាំ ដែលរស់នៅតាមផ្ទះផ្តល់ការថែទាំ ដែលមានឪពុកម្តាយយ៉ាងហោចណាស់ម្នាក់នៅរស់ | | 79 | វិទ្យាស្ថានជាតិស្ថិតិ ( NIS ) 2016 |
| **អាពាហ៍ពិពាហ៍កុមារ** | | | |
| ភាគរយស្ត្រីអាយុ 20 ដល់ 24 ឆ្នាំ ដែលរៀបការដំបូង ឬរស់នៅជាមួយដៃគូមុនអាយុ 18 ឆ្នាំ | | 19 | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ 2014 |
| ភាគរយស្ត្រីអាយុ 20 ដល់ 24 ឆ្នាំ ដែលរៀបការដំបូង ឬរស់នៅជាមួយដៃគូមុនអាយុ 15 ឆ្នាំ | | 2 | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ 2014 |
| **ការមានផ្ទៃពោះរបស់ក្មេងជំទង់ និងការឆាប់មានកូន** | | | |
| ភាគរយនៃក្មេងស្រីអាយុ 15 ដល់ 19 ឆ្នាំ ដែលបានសម្រាលកូនរួច ឬមានផ្ទៃពោះជាមួយកូនដំបូង | | 12 | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ 2014 |
| ភាគរយនៃស្ត្រីអាយុ 20 ដល់ 24 ឆ្នាំ ដែលសម្រាលកូនមុនអាយុ 18 ឆ្នាំ | | 7 | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ 2014 |
| **អំពើហិង្សាលើកុមារ** | | | |
| | ស្រី | ប្រុស | |
| ភាគរយនៃកុមារអាយុ 13 ដល់ 17 ឆ្នាំ ដែលទទួលរងអំពើហិង្សាផ្លូវកាយ ក្នុងរយៈពេល 12 ខែចុងក្រោយ | 15 | 13 | ការអង្កេតអំពើហិង្សាលើកុមារនៅ កម្ពុជា ឆ្នាំ 2013 |
| ភាគរយនៃកុមារអាយុ 13 ដល់ 17 ឆ្នាំ ដែលទទួលរងអំពើហិង្សាផ្លូវភេទ ក្នុងរយៈពេល 12 ខែចុងក្រោយ | 3 | 0.1 | ការអង្កេតអំពើហិង្សាលើកុមារនៅ កម្ពុជា 2013 |
| ភាគរយនៃកុមារអាយុ 13 ដល់ 17 ឆ្នាំ ដែលទទួលរងអំពើហិង្សាផ្លូវចិត្ត ក្នុងរយៈពេល 12 ខែចុងក្រោយ | 10 | 10 | ការអង្កេតអំពើហិង្សាលើកុមារនៅ កម្ពុជា 2013 |
| ភាគរយនៃកុមារអាយុ 0 ដល់ 17 ឆ្នាំ ដែលរស់នៅជាមួយម្តាយដែលធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្ត ប្រព្រឹត្តដោយប្តី ឬដៃគូ នៅក្នុងរយៈពេល 12 ខែចុងក្រោយ | | 24 | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា 2014 មិនរាប់បញ្ចូលស្ត្រីដែលមានដែលរៀបការ |
| ភាគរយនៃកុមារអាយុ 15 ដល់ 19 ឆ្នាំ ដែលយល់ស្របថា ប្តីមានហេតុផលសមស្របក្នុងការវាយដំប្រពន្ធរបស់ខ្លួន ដោយសារមូលហេតុមួយក្នុងចំណោម មូលហេតុដែលបានលើកឡើងទាំង 6 | 46 | 26 | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា 2014 |

| | | |
|---|---|---|
| **ការជួញដូរកុមារ** | | |
| ប្រេវ៉ាឡង់នៃការធ្វើអាជីវកម្មផ្លូវភេទលើកុមារ | 2 | បេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) 2015 ផ្អែកទៅតាមកន្លែងផ្តល់សេវាផ្លូវភេទដែលបានជ្រើសរើសតាមបែបចៃដន្យចំនួន 287 កន្លែង ក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប និងក្រុងព្រះសីហនុ |
| **ពលកម្មកុមារ និងកុមារធ្វើការងារ** | | |
| ភាគរយនៃកុមារអាយុ 5 ដល់ 17 ឆ្នាំ ដែលមានសកម្មភាពសេដ្ឋកិច្ច | 19 | ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា ឆ្នាំ 2014 |
| ភាគរយនៃកុមារអាយុ 5 ដល់ 17 ឆ្នាំ ដែលធ្វើការងារជាពលករកុមារ រាប់បញ្ចូលទាំងការងារក្នុងទម្រង់គ្រោះថ្នាក់ | 11 | អង្គការពលកម្មអន្តរជាតិ/វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ 2012 |
| ភាគរយនៃពលករកុមារ ដែលកំពុងធ្វើការងារដែលមានទម្រង់គ្រោះថ្នាក់ | 55 | អង្គការពលកម្មអន្តរជាតិ/វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ2012 |
| ភាគរយនៃកុមារដែលកំពុងធ្វើការងារនៅក្នុងទម្រង់គ្រោះថ្នាក់ ហើយកំពុងចូលរៀននៅតាមសាលារៀន | 12 | អង្គការពលកម្មអន្តរជាតិ/វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ2012 |
| ភាគរយនៃកុមារធ្វើការនៅក្រៅសាលារៀន | 50 | អង្គការពលកម្មអន្តរជាតិ/វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ2012 |
| **កុមារដែលរងផលប៉ះពាល់ដោយសារមេរោគអេដស៍/ជម្ងឺអេដស៍** | | |
| ចំនួនប៉ាន់ប្រមាណនៃកុមារអាយុ 0 ដល់ 14 ឆ្នាំ ដែលរស់នៅជាមួយមេរោគអេដស៍ក្នុងឆ្នាំ 2015 | 4,061 | ការអង្កេត Spectrum ធ្វើឡើងដោយ UNAIDS ឆ្នាំ 2016 |
| ចំនួនប៉ាន់ប្រមាណនៃកុមារអាយុ 0 ដល់ 14 ឆ្នាំ ដែលទើបឆ្លងមេរោគអេដស៍ថ្មី ក្នុងឆ្នាំ 2014 | 73 | ការអង្កេត Spectrum ធ្វើឡើងដោយ UNAIDS ឆ្នាំ 2016 |
| ចំនួនប៉ាន់ប្រមាណនៃក្មេងជំទង់អាយុ 10 ដល់ 19 ឆ្នាំ ដែលរស់នៅជាមួយមេរោគអេដស៍ក្នុងឆ្នាំ 2014 | 39,000 (36,000-42,000) | ការប៉ាន់ប្រមាណពីមេរោគ និងជំងឺអេដស៍ ឆ្នាំ 2014 ធ្វើឡើងដោយ UNAIDS ខែ កក្កដា ឆ្នាំ ២០១៥ |
| ក្មេងជំទង់អាយុ 10 ដល់ 19 ឆ្នាំ រស់នៅជាមួយមេរោគអេដស៍គិតជាភាគរយនៃមនុស្សគ្រប់វ័យរស់នៅជាមួយមេរោគអេដសន៍ក្នុងឆ្នាំ 2014 | 6 | ការប៉ាន់ប្រមាណពីមេរោគ និងជំងឺអេដស៍ ឆ្នាំ 2014 ធ្វើឡើងដោយ UNAIDS ខែ កក្កដា ឆ្នាំ ២០១៥ |
| ភាគរយក្មេងជំទង់អាយុ 15 ដល់ 19 ឆ្នាំ ដែលមានចំណេះដឹងគ្រប់ជ្រុងជ្រោយអំពីមេរោគអេដស៍ | 33 (ស្រី) 42 (ប្រុស) | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា 2014 |
| **កុមាររស់នៅក្នុងភាពក្រីក្រ** | | |
| ចំនួនប៉ាន់ប្រមាណនៃកុមាររស់នៅក្នុងគ្រួសារ ដែលចាត់ទុកថាជាគ្រួសារក្រ1 និងក្រ 2 | 896,877 | ការវិភាគធ្វើឡើងដោយកម្មវិធី អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ឆ្នាំ ២០១៧ |
| ចំនួនប៉ាន់ប្រមាណនៃគ្រួសារក្រីក្រនៅកម្ពុជា (ក្រ 1 និង ក្រ 2) | 575,000 | កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ របស់ក្រសួងផែនការ ឆ្នាំ 2017 |
| ចំនួនប៉ាន់ប្រមាណនៃមនុស្សរស់នៅក្នុងគ្រួសារដែលបានដាក់ចំណាត់ថ្នាក់ថាក្រ 1 និងក្រ 2 | 2,360,000 | កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ របស់ក្រសួងផែនការ ឆ្នាំ 2017 |
| **កុមាររងគ្រោះដោយសារសំណល់សង្គ្រាម** | | |
| ចំនួនកុមារដែលរងគ្រោះដោយសារសំណល់សង្គ្រាម ឬគ្រាប់មីនក្នុងឆ្នាំ 2016 បែងចែកតាមប្រភេទនៃការរងរបួស | 9 (រងរបួស/ជាច់អវៈយវៈ)<br>11 (បាត់បង់ជីវិត) | អាជ្ញាធរមីនកម្ពុជា ឆ្នាំ 2017 |
| **ចំនួនកុមារដែលមានទំនាស់ជាមួយច្បាប់** | | |
| ចំនួនកុមារ រស់នៅក្នុងមន្ទីរឃុំឃាំង ក្នុងប្រជាជនជាកុមារ 100,000 នាក់ | 15 | ក្រសួងមហាផ្ទៃ ឆ្នាំ 2017 |
| **ប្រព័ន្ធការពារកុមារ** | | |
| ថវិកាសរុបនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់សារពើពន្ធ 2016 | 178.5 លានដុល្លា | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ 2016 |
| ភាគរយនៃថវិកានៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គិតជាភាគរយនៃថវិកាជាតិក្នុងឆ្នាំ ២០១៦ | 4 | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ 2016 |
| ចំនួនភ្នាក់ងារសុខុមាលភាពសង្គមរបស់រដ្ឋាភិបាលសម្រាប់កុមារ និងប្រជាជនងាយរងគ្រោះផ្សេងទៀត ក្នុងឆ្នាំ 2012 | 917 | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ 2014 |

ក្នុងឆ្នាំ ២០១២ ភ្នាក់ងារសុខុមាលភាពសង្គមរបស់រដ្ឋ ដែលធ្វើការងារ ដើម្បីកុមារ និងប្រជាជនងាយរងគ្រោះផ្សេងទៀត មានចំនួនតែ **៩១៧** នាក់ប៉ុណ្ណោះ ហើយភាគច្រើនពុំបានទទួលការបណ្តុះបណ្តាលការងារសង្គមកិច្ចអ្វីឡើយ។

ក្នុងចំណោមស្ត្រីអាយុ ២០ ទៅ ២៤ ឆ្នាំ **៥ នាក់ មានជិត ១ នាក់** ដែលបានរៀបការ ឬរស់នៅជាមួយដៃគូ មុនអាយុ ១៨ ឆ្នាំ។

មានមនុស្សពេញវ័យអាយុ ១០ ដល់ ១៩ ឆ្នាំ ប្រមាណជា **៣៩០០០** នាក់ កំពុងរស់នៅជាមួយមេរោគអេដស៍។

ល្បឿនវឌ្ឍនភាពនៃការចុះសំបុត្រកំណើត **មានការកើនឡើង** ចាប់តាំងពីឆ្នាំ ២០១០ មក តែទោះជាយ៉ាងណាក៏ដោយ មានកុមារអាយុក្រោម ៥ ឆ្នាំ ជាងមួយភាគបួន ដែលពុំទាន់បានចុះសំបុត្រកំណើត។

ការមានកូនក្នុងចំណោមក្មេងស្រីអាយុ ១៩ ឆ្នាំ កំពុង **មានការកើនឡើង** ជាពិសេស ក្នុងចំណោមក្មេងស្រីក្រីក្រ ក្មេងស្រីដែលរៀនបានត្រឹមបឋមសិក្សា និងក្មេងស្រីដែលរស់នៅតំបន់ជនបទ។

មានកុមារប្រហែលជា **២,៤ លាននាក់** ដែលក្នុងនោះមួយភាគបីជាកុមារ រស់នៅក្នុងគ្រួសារដែលត្រូវបានដាក់ចំណាត់ថ្នាក់ថា "ក្រីក្រ" ឬ "ក្រខ្សត់"។

ក្នុងឆ្នាំ ២០១៦ មានកុមារប្រមាណជា **១៦៥០០** នាក់ រស់នៅតាមមណ្ឌលថែទាំ ចំនួន **៤០៦** កន្លែង ទូទាំងប្រទេស។

ក្នុងចំណោមក្មេងស្រី និងស្ត្រីទាំងអស់ **មានពាក់កណ្តាល**ជឿថា ប្តីមានហេតុផលសមស្រប ក្នុងការវាយដំប្រពន្ធរបស់ខ្លួន ក្រោមកាលៈទេសៈមួយចំនួន បើធៀបនឹងមួយនាក់ ក្នុងចំណោមបួននាក់ សម្រាប់បុរស និងក្មេងប្រុស។

ក្នុងចំណោមកុមារទាំងអស់ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ មានរហូតដល់**ពាក់កណ្តាល** ត្រូវបានកាត់ទោស ដូចមនុស្សពេញវ័យដែរ ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។

ក្នុងចំណោមកុមារ **១០ នាក់ មាន ១ នាក់** មិនកំពុងរស់នៅជាមួយឪពុកម្តាយបង្កើតរបស់ខ្លួន បើទោះបីជាពួកគេមានឪពុកម្តាយដែលនៅរស់យ៉ាងហោចណាស់ម្នាក់ យ៉ាងណាក៏ដោយ។

ក្នុងចំណោមកុមារ អាយុចន្លោះពី ៥ ដល់ ១៧ ឆ្នាំ **៩ នាក់ មានប្រហែលជាម្នាក់**កំពុងប្រឡូកក្នុងពលកម្មកុមារ ដែលក្នុងនោះជាងពាក់កណ្តាលកំពុងធ្វើការងារប្រកបដោយគ្រោះថ្នាក់។

unicef

ដើម្បីកុមារគ្រប់រូប